# សេចក្តីប្រកាសស្តីពីនីតិវិធីទទួលបានការការពារ

**លេខទូរស័ព្ទទំនាក់ទំនងផ្នែកប្រឹក្សានៃការិយាល័យសំរាប់ការអប់រំពិសេស ជាជំនួយសំរាប់ឪពុកម្តាយ**
**800-879-2301**

បុគ្គលផ្នែកផ្តល់ប្រឹក្សានឹងរងចាំទទួលការទំនាក់ទំនងពី ឪពុកម្តាយ និង មេធាវីរបស់កុមារដែលមានពិការភាព ឬ កុមារដែលត្រូវបានគិតថាពិការ ដើម្បីពន្យល់អំពីច្បាប់របស់រដ្ឋ និង ច្បាប់សហព័ន្ធដែលទាក់ទងនឹងការអប់រំពិសេស ដើម្បីរៀបរាប់ពីជំរើសដែលមានសំរាប់ឪពុកម្តាយ ដើម្បីប្រាប់ឪពុកម្តាយពីនីតិវិធីទទួលបានការការពារ ដើម្បីកំណត់ពីសេវាកម្មជំនួយ ឬ ភ្នាក់ងារផ្សេងៗទៀត និងដើម្បីរៀបរាប់ពីវិធីសាស្ត្រដោះស្រាយដែលមាន និង របៀបដែលឪពុកម្តាយអាចប្តឹងតវ៉ាបាន។

ប្រភពជំនួយបន្ថែមផ្សេងទៀតមាននៅខាងចុងនៃសេចក្តីប្រកាសនេះ។

ច្បាប់ស្តីពីការអប់រំសំរាប់បុគ្គលមានពិការភាព (IDEA) ជាច្បាប់សហព័ន្ធដែលទាក់ទងនឹងការអប់រំសំរាប់សិស្សមានពិការភាព ដែលតម្រូវឱ្យភ្នាក់ងារអប់រំក្នុងតំបន់ (LEA) ផ្តល់ឱ្យឪពុកម្តាយសិស្សដែលមានពិការភាពនូវ សេចក្តីប្រកាសនេះដែលមានការពន្យល់ទាំងស្រុងអំពីនីតិវិធីទទួលការការពារដែលមាននៅក្រោម IDEA និង ច្បាប់បញ្ញត្តិរបស់ក្រសួងអប់រំនៃសហរដ្ឋអាមេរិក។ ច្បាប់ចំលងនៃសេចក្តីប្រកាសនេះត្រូវផ្តល់ឱ្យឪពុកម្តាយសិស្សតែម្តងគត់ក្នុងមួយឆ្នាំសិក្សា
ឬ:
(1) នៅពេលមានការសំអាង ឬការស្នើសុំពីដំបូងរបស់ឪពុកម្តាយ ឱ្យមានការវាយតំលៃ (2) នៅពេលឪពុកម្តាយ ដាក់ពាក្យបណ្តឹងទៅរដ្ឋ (State complaint)ជាលើកដំបូងក្រោម 34 CFR §§300.151 ដល់ 300.153 និង នៅពេលឪពុកម្តាយ ដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ (due process complaint) ជាលើកដំបូងក្រោម §300.507 ក្នុងឆ្នាំសិក្សាមួយ (3) នៅពេលការសំរេច ចិត្តត្រូវបានធ្វើឡើងដើម្បីចាត់វិធានការវិន័យដែលរួមមានការផ្លាស់ប្តូរទីកន្លែងអប់រំ និង (4) នៅពេលមានសំណើពីឪពុកម្តាយ។ [34 CFR §300.504(a)]

សេចក្តីប្រកាសស្តីពីនីតិវិធីទទួលបានការការពារត្រូវតែរួមបញ្ចូលនូវការពន្យល់ពេញលេញពីរាល់នីតិវិធីទទួលបានការការពារទាំងអស់ដែលមាននៅក្រោម §300.148 (ការរកទីកន្លែងអប់រំជាឯកតោភាគីនៅសាលាឯកជន ដោយចំណាយជារបស់រដ្ឋ), §§300.151 ដល់ 300.153 (នីតិវិធីនៃបណ្តឹងទៅរដ្ឋ), §300.300 (ការយល់ព្រម), §§300.502 ដល់ 300.503, §§300.505 ដល់ 300.518, និង §§300.530 ដល់ 300.536 (នីតិវិធីទទួលបានការការពារ នៅក្នុង ផ្នែករង E នៃច្បាប់បញ្ញត្តិក្នុងផ្នែក B), និង §§300.610 ដល់ 300.625 (ភាពសំងាត់នៃការផ្តល់ពត៌មាន នៅក្នុង ផ្នែករង F)។ ទម្រង់ឯកសារគំរូនេះផ្តល់ជា ទម្រង់ដែល LEA អាចនឹងជ្រើសរើសប្រើសំរាប់ផ្តល់ពត៌មានអំពី នីតិវិធីទទួលបានការការពារ ឱ្យឪពុកម្តាយ។

# មាតិកា


I. ពត៌មានទូទៅ ..... 1

តើឪពុក/ម្តាយជានរណា ? ..... 1

តើអ្វីជាសេចក្តីប្រកាសជាលាយលក្សណ៍អក្សរជាមុន ? ..... 1

តើអ្វីជាភាសាកំណើត? ..... 2

ការជូនដំណឹងជាសារអេឡិចត្រូនិច ..... 2

តើអ្វីជាការយល់ព្រមរបស់ឪពុកម្តាយ ? ..... 2

តើការយល់ព្រមរបស់ឪពុកម្តាយត្រូវការនៅពេលណា ? ..... 3

ការយល់ព្រមចំពោះការដាក់បង្ហាញពត៌មានដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួន ..... 6

II. ភាពជាសំងាត់នៃពត៌មាន ..... 8

តើនរណាដែលមានសិទ្ធិប្រើប្រាស់ឬមើលពត៌មានជាសំងាត់ដែលទាក់ទងនឹងកូនរបស់ខ្ញុំ ? ..... 8

និយមន័យ ..... 8

ដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួន ..... 8

សិទ្ធិប្រើប្រាស់ឬចូលមើល ..... 8

កំនត់ត្រាការអប់រំណាដែលរួមបញ្ចូលពត៌មានរបស់កុមារលើសពីម្នាក់ ..... 8

បញ្ជីនៃប្រភេទ និងទីតាំងនៃកំនត់ត្រាអប់រំទាំងឡាយ ..... 9

តម្លៃ ..... 9

ការកែប្រែកំនត់ត្រាតាមសំនូមពររបស់ឪពុកម្តាយ ..... 9

ឱកាសចំពោះសវនាការមួយស្តីពីកំនត់ត្រានានា ..... 9

នីតិវិធីនៃសវនាការ ..... 9

លទ្ធផលនៃសវនាការ ..... 10

ការការពារ ..... 10

ការបំផ្លាញពត៌មាន ..... 10

III. នីតិវិធីបណ្តឹងទៅរដ្ឋ ..... 11

ភាពខុសគ្នារវាង នីតិវិធីបណ្តឹងសវនាតាមផ្លូវច្បាប់ និង នីតិវិធីបណ្តឹងទៅរដ្ឋ ..... 11

តើខ្ញុំអាចដាក់ពាក្យបណ្តឹងទៅរដ្ឋដោយវិធីណា ? ..... 11

ការទទួលយកនៃនីតិវិធីបណ្តឹងទៅរដ្ឋ. ..... 11

អប្បបរមានៃនីតិវិធីបណ្តឹងទៅរដ្ឋ ..... 11

IV. នីតិវិធីបណ្តឹងតាមផ្លូវច្បាប់ ..... 13

តើខ្ញុំអាចស្នើសុំឱ្យមានសវនាការតាមផ្លូវច្បាប់មួយដោយរបៀបណា ? ..... 13

មាតិកានៃពាក្យបណ្តឹងតាមផ្លូវច្បាប់ ..... 13

ដំណើរការដោះស្រាយ ..... 14

V. សវនាការអំពីពាក្យបណ្តឹងតាមផ្លូវច្បាប់ ..... 17

សវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង ..... 17

សិទ្ធិសវនាការ ..... 17

សេចក្តីសំរេចរបស់សវនាការ ..... 18

ភាពជាចុងក្រោយនៃសេចក្តីសំរេច ឧទ្ធរណ៍ ការពិនិត្យឡើងវិញដោយមិនលំអៀង ..... 19

កាលវេលាកំនត់និងភាពងាយស្រួលរបស់សវនាការ ..... 19

បណ្តឹងរដ្ឋប្បវេណី រួមទាំងរយៈពេលដែលត្រូវដាក់ពាក្យប្តឹង ..... 19

ថ្លៃឈ្នួលមេធាវី ..... 20

ទម្រង់ឯកសារគំរូ ..... 21

VI. ការសម្រុះសម្រួល ..... 22

ជាទូទៅ ..... 22

តម្រូវការនៃនីតិវិធី ..... 22

អ្នកសម្រុះសម្រួលមិនលំអៀង ..... 22

VII. ទីកន្លែងសិក្សារបស់កុមារអំឡុងពេលរងចាំការសម្រុះសម្រួល និង នីតិវិធីតាមផ្លូវច្បាប់ ..... 23

ជាទូទៅ ..... 23

VIII. តើមានអ្វីកើតឡើង ប្រសិនបើកូនរបស់ខ្ញុំត្រូវបានដកចេញពីសាលាដោយសារបញ្ហាវិន័យ ? ..... 24

សិទ្ធិរបស់បុគ្គលិកសាលា ..... 24

ការផ្លាស់ប្តូរទីកន្លែងដោយសារការផ្លាស់ចេញតាមវិន័យ ..... 26

ការកំនត់ពីទីកន្លែង ..... 26

ឧទ្ធរណ៍ ..... 27

ទីកន្លែងអំឡុងពេលប្តឹងឧទ្ធរណ៍ ..... 27

ការការពារកុមារមិនទាន់ទទួលស្គាល់សំរាប់ ការអប់រំពិសេស និង សេវាកម្មទាក់ទង ..... 28

ការសំអាងទៅលើ និង សកម្មភាពដោយការពង្រឹងច្បាប់ និង អំណាចតុលាការ ..... 29

IX. តើសេវាកម្មអប់រំពិសេសអ្វីខ្លះដែលមានសំរាប់កូនរបស់ខ្ញុំ ប្រសិនបើឪពុកម្តាយបានឱ្យចូលរៀនក្នុងសាលាឯកជនមួយ ? ..... 30

វិធានច្បាប់ទូទៅ ..... 30

ការលើកលែង ..... 30

ការចូលរួមដោយស្មើភាព ..... 31

ឧបសម្ព័ន្ធ A ..... 32

ប្រភពជំនួយ ..... 32

ឧបសម្ព័ន្ធ B ..... 34

ទម្រង់ឯកសារស្នើសុំការសម្រុះសម្រួល ..... 34

សេចក្តីជូនដំណឹងពីបណ្តឹងតាមផ្លូវច្បាប់ ..... 34

## I. ពតិមានទូទៅ

### A. តើឪពុក/ម្តាយជានរណា? (34 CFR §300.30)

**ផ្នែកនេះរៀបរាប់ពីអ្នកដែលអាចដើរតួជា/ធ្វើជាឪពុក/ម្តាយសំរាប់គោលបំណងក្នុងការសំរេចចិត្តចំពោះការអប់រំពិសេស។**

ឪពុក/ម្តាយគឺជាឪពុកម្តាយបង្កើត ឬឪពុកម្តាយចិញ្ចឹមរបស់កុមារ ឪពុក/ម្តាយធម៌ អាណាព្យាបាលដែលជាទូទៅត្រូវបានផ្តល់សិទ្ធិស្របច្បាប់ឱ្យធ្វើជាឪពុក/ម្តាយរបស់កុមារ ឬត្រូវបានផ្តល់សិទ្ធិឱ្យសំរេចចិត្តលើការអប់រំរបស់កុមារ បុគ្គលដែលដើរតួនាទីជំនួសឱ្យឪពុក/ម្តាយបង្កើត ឬឪពុក/ម្តាយចិញ្ចឹម (រួមមាន ជីដូន/ជីតា ឪពុក/ម្តាយចុង ឬសាច់ញាតិដ៏ទៃទៀត) ដែលកុមាររស់នៅជាមួយ ឬបុគ្គលដែលទទួលខុសត្រូវស្របច្បាប់សំរាប់សុខុមាលភាពរបស់កុមារ ឬអ្នកជំនួសឪពុកម្តាយ/អ្នកពរពោះជំនួសម្តាយ។

អ្នកជំនួសឪពុកម្តាយ/អ្នកពរពោះជំនួសម្តាយ (surrogate parent) ត្រូវតែជ្រើសតាំងនៅពេលដែល មិនមានឪពុក/ម្តាយឬសាច់ញាតិណាម្នាក់ត្រូវបានគេដឹងនិងកំនត់អត្តសញ្ញាណបាន; ភ្នាក់ងារសាធារណៈមិនអាចរកឪពុក/ម្តាយឬសាច់ញាតិផ្សេងទៀតឃើញ បន្ទាប់ពីបានខិតខំរកអស់លទ្ធភាព; កុមារនេះស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ ក្រោមច្បាប់របស់រដ្ឋភេនស៊ីលវេនា ឬ កុមារនេះជាកុមារគ្មានផ្ទះសម្បែងនិងគ្មានអ្នកមើលការខុសត្រូវ ដូចដែលបានកំណត់ដោយច្បាប់ស្តីពីជំនួយសំរាប់ជនគ្មានផ្ទះសម្បែងរបស់ ម៉ាក់ឃីនី-វិនតូ (the McKinney-Vento Homeless Assistance Act, 42 U.S.C. Sec. 11434a(6)។ ភ្នាក់ងារសាធារណៈទាំងឡាយត្រូវធានាឱ្យបានថាមនុស្សដែលត្រូវបានជ្រើសរើសជាអ្នកជំនួសឪពុកម្តាយ មិនមែនជាបុគ្គលិករបស់ SEA, LEA ឬ ភ្នាក់ងារដ៏ទៃទៀតដែលទាក់ទងនឹងការអប់រំ ឬការថែទាំកុមារនេះ; មិនមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬជំនាញរបស់ខ្លួនដែលប្រឆាំងនឹងផលប្រយោជន៍របស់កុមារដែលអ្នកជំនួសឪពុកម្តាយតំណាងឱ្យនោះឡើយ; ព្រមទាំងមានចំណេះដឹង និង ជំនាញ ដែលធានាឱ្យមានការធ្វើជាតំណាងគ្រប់គ្រាន់សំរាប់កុមារនេះ។ អ្នកជំនួសឪពុកម្តាយ អាចជាតំណាងរបស់កុមារចំពោះ គ្រប់រឿងរ៉ាវឬបញ្ហាទាំងអស់ដែលទាក់ទងទៅនឹង អត្តសញ្ញាណ ការវាយតំលៃ និង កន្លែងសិក្សាអប់រំរបស់កុមារ ហើយនិងការផ្តល់ FAPE ទៅឱ្យកុមារ។ ភ្នាក់ងារសាធារណៈត្រូវតែប្រឹងប្រែងឱ្យបានគ្រប់គ្រាន់ដើម្បីធានាឱ្យបានថាការជ្រើសតាំងអ្នកជំនួសឪពុកម្តាយ មិនត្រូវលើសពី ៣០ថ្ងៃ បន្ទាប់ភ្នាក់ងារសាធារណៈកំណត់ថាកុមារត្រូវការអ្នកជំនួសឪពុកម្តាយ។

### B. តើអ្វីជាសេចក្តីប្រកាសជាលាយលក្សណ៍អក្សរជាមុន? (34 CFR §300.503)

**ផ្នែកនេះពន្យល់ពី អ្វី របៀបណា និងពេលណា ដែល LEA ត្រូវតែប្រាប់អ្នកពីវិធានការនានាដែល គេស្នើឡើង ឬ បដិសេធមិនធ្វើ។**

#### 1. ពេលវេលាដែលតម្រូវឱ្យមានសេចក្តីប្រកាស

ភ្នាក់ងារអប់រំក្នុងតំបន់ (LEA) របស់អ្នក - អង្គភាពដែលទទួលខុសត្រូវផ្តល់ការអប់រំជាសាធារណៈសមរម្យនិងមិនគិតថ្លៃឱ្យទៅកូនរបស់អ្នក ត្រូវតែជូនដំណឹងទៅអ្នកជាលាយលក្ខណ៍អក្សរពេលណាក៏ដោយដែលគេ :

a. ស្នើធ្វើការផ្តួចផ្តើម ឬ ផ្លាស់ប្តូរ អត្តសញ្ញាណ ការវាយតំលៃ ឬកន្លែងសិក្សាអប់រំសំរាប់កូនរបស់អ្នក ឬការផ្តល់ ការអប់រំជាសាធារណៈសមរម្យនិងមិនគិតថ្លៃ (FAPE) ទៅឱ្យកូនរបស់អ្នក **ឬ**

b. បដិសេធធ្វើការផ្តួចផ្តើម ឬ ផ្លាស់ប្តូរ អត្តសញ្ញាណ ការវាយតំលៃ ឬកន្លែងសិក្សាអប់រំសំរាប់កូនរបស់អ្នក ឬការផ្តល់ ការអប់រំជាសាធារណៈសមរម្យនិងមិនគិតថ្លៃ (FAPE) ទៅឱ្យកូនរបស់អ្នក។

c. ផ្លាស់ប្តូរទីកន្លែងដោយហេតុផលខាងវិន័យ។

d. សវនាការតាមផ្លូវច្បាប់, ឬ សវនាការតាមផ្លូវច្បាប់យ៉ាងប្រញាប់ ដែលផ្តួចផ្តើមដោយ LEA។

e. ការបដិសេធរបស់ LEA មិនយល់ព្រមចំពោះការវាយតំលៃការអប់រំដោយឯករាជ្យ (IEE) ដោយការចំណាយជារបស់រដ្ឋ។

f. ការលុបចោលការយល់ព្រមវិញរបស់ឪពុកម្តាយចំពោះការអប់រំពិសេស និងសេវាកម្មដែលទាក់ទង។

ក្នុងរដ្ឋភេស៊ីលវេនា, សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរជាមុន ត្រូវបានផ្តល់ឱ្យតាមមធ្យោបាយនៃ ទម្រង់ឯកសារសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរជាមុនរបស់ LEA (LEA Prior Written Notice)/សេចក្តីប្រកាសស្តីពីកន្លែងសិក្សាអប់រំដែលត្រូវបានណែនាំ (Notice of Recommended Educational Placement)។ អ្នកគួរតែទទួលបានសេចក្តីប្រកាសសមហេតុផលមួយពី សំណើ ឬ ការបដិសេធនេះ ដូច្នេះប្រសិនបើអ្នកមិនយល់ស្របជាមួយនឹង LEA អ្នកអាចចាត់វិធានការសមស្របណាមួយ។ សេចក្តីប្រកាសសមហេតុផល មានន័យថាក្នុងរយៈពេល ១០ថ្ងៃ។

#### 2. មាតិកានៃសេចក្តីប្រកាស

**<u>សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរជាមុន ត្រូវតែ:</u>**

1. រៀបរាប់ពីវិធានការដែល LEA របស់អ្នក ស្នើឡើង ឬ បដិសេធ នឹងធ្វើ;
2. ពន្យល់ហេតុអ្វី LEA របស់អ្នក ស្នើ ឬ បដិសេធ នឹងចាត់វិធានការ;
3. រៀបរាប់ពីរាល់នីតិវិធីវាយតំលៃ ការវាយតំលៃ កំណត់ត្រា ឬរបាយការណ៍នីមួយៗដែល LEA របស់អ្នកបានប្រើក្នុងការសំរេចចិត្ត ស្នើសុំ ឬ បដិសេធវិធានការនោះ;
4. រួមបញ្ចូលសេចក្តីថ្លែងមួយដែលបញ្ជាក់ថាអ្នកមានការការពារនៅក្រោម ខ ដែលមានចែងក្នុងនីតិវិធីទទួលបានការការពារ (procedural safeguards provisions) នៅក្នុងផ្នែក B នៃ IDEA;
5. ប្រាប់ពីរបៀបដែលអ្នកទទួលបានការពិពណ៌នាពីនីតិវិធីទទួលការការពារ ប្រសិនបើវិធានការដែល LEA របស់អ្នក ស្នើ ឬ បដិសេធនេះមិនមែនជាសំអាងពីដំបូងសំរាប់ការវាយតំលៃ;
6. រួមបញ្ចូលប្រភពជំនួយសំរាប់អ្នកដើម្បីទាក់ទងស្វែងរកជំនួយក្នុងការយល់ផ្នែក B នៃ IDEA;
7. រៀបរាប់ពីជំរើសផ្សេងដ៏ទៃទៀតដែលក្រុម IEP របស់កូនអ្នកបានពិចារណា និង ហេតុផលដែលជំរើសទាំងនោះត្រូវបានបដិសេធ **<u>និង</u>**
8. ផ្តល់ជាការពិពណ៌នាចំពោះហេតុផលដ៏ទៃទៀតដែល LEA របស់អ្នក បានស្នើ ឬ បានបដិសេធចំពោះវិធានការនោះ។

### 3. សេចក្តីប្រកាសជាភាសាដែលអាចយល់បាន

a. សេចក្តីប្រកាសនេះត្រូវតែ:
   1) សរសេរជាភាសាដែលអាចយល់បានសំរាប់សាធារណ:ជនទូទៅ; **<u>និង</u>**
   2) ផ្តល់ឱ្យជាភាសាកំណើតរបស់អ្នក ឬ វិធីទំនាក់ទំនងផ្សេងទៀតដែលអ្នកប្រើ លើកលែងតែវាច្បាស់ថាមិនអាចធ្វើទៅរួច។
   3) ប្រសិនបើភាសាកំណើតរបស់អ្នក ឬ វិធីទំនាក់ទំនងផ្សេងទៀត គឺមិនមែនជាភាសាសរសេរ LEA របស់អ្នកត្រូវធានាថា:
      a) សេចក្តីប្រកាសត្រូវបានបកប្រែផ្ទាល់មាត់សំរាប់អ្នក ឬ ដោយវិធីផ្សេងៗទៀតជាភាសាកំណើត ឬ វិធីទំនាក់ទំនងផ្សេងៗទៀតរបស់អ្នក;
      b) អ្នកយល់ពីមាតិកានៃសេចក្តីប្រកាសនោះ **<u>និង</u>**
      c) មានភស្តុតាងជាលាយលក្ខណ៍អក្សរដែលចំណុចទី ១ និង ២ ត្រូវបានបំពេញ។

## C. <u>តើអ្វីជាភាសាកំណើត? (34 CFR §300.29)</u>

1. *ភាសាកំណើត*, នៅពេលប្រើប្រាស់ជាមួយអ្នកដែលមានភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់ភាសាអង់គ្លេសមានកំណត់ មានន័យដូចខាងក្រោម:
   a. ភាសាដែលជាធម្មតាត្រូវបានប្រើដោយបុគ្គលនោះ ឬ ក្នុងករណីជាកុមារ ភាសាដែលជាធម្មតាត្រូវបានប្រើដោយឪពុកម្តាយរបស់កុមារ;
   b. ក្នុងរាល់ការទំនាក់ទំនងទាំងអស់ជាមួយនឹងកុមារ (រួមទាំង ការវាយតំលៃចំពោះកុមារ), ភាសាដែលជាធម្មតាត្រូវបានប្រើដោយកុមារនៅផ្ទះ ឬ ក្នុងបរិយាកាសសិក្សា។
   សំរាប់មនុស្សដែលថ្លង់ ឬ ពិការភ្នែក ឬ សំរាប់មនុស្សម្នាក់ដែលមិនមានភាសាសរសេរ វិធីទំនាក់ទំនងគឺជាអ្វីដែលមនុស្សនោះជាធម្មតាប្រើ (ដូចជាភាសាសញ្ញា ប្រព័ន្ធអក្សរផុសសំរាប់មនុស្សពិការភ្នែក ឬ ទំនាក់ទំនងផ្ទាល់មាត់)។

## D. <u>ការជូនដំណឹងជាសារអេឡិចត្រូនិច (34 CFR §300.505)</u>

ប្រសិនបើ LEA របស់អ្នកផ្តល់ជាជំរើសដល់ឪពុកម្តាយក្នុងការទទួលឯកសារតាមអ៊ីម៉ែល អ្នកអាចជ្រើសរើសទទួលឯកសារដូចខាងក្រោមតាមអ៊ីម៉ែល:

1. សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរជាមុន;
2. សេចក្តីប្រកាសស្តីពីនីតិវិធីទទួលការការពារ; **<u>និង</u>**
3. សេចក្តីប្រកាសនានាដែលទាក់ទងនឹង បណ្តឹងតាមផ្លូវច្បាប់។

## E. <u>តើអ្វីជាការយល់ព្រមរបស់ឪពុកម្តាយ ? (34 CFR §300.9)</u>

**ផ្នែកនេះពន្យល់ពី អ្វីជាការយល់ព្រមរបស់ឪពុកម្តាយដែលបានជូនដំណឹងរួច និងពេលណាដែលអ្នកត្រូវផ្តល់វា ដូច្នេះ LEA មួយអាចបន្តដំណើរការជាបន្តដូចដែលបានស្នើឡើង នៅក្នុងសេចក្តីប្រកាសនោះ។**

1. **តើអ្វីជាការយល់ព្រមរបស់ឪពុកម្តាយ ?**

   *ការយល់ព្រម* មានន័យថា:

   a. អ្នកត្រូវបានជំរាបជូនពេញលេញជាភាសាកំណើត ឬ វិធីទំនាក់ទំនងដ៏ទៃទៀតរបស់អ្នក (ដូចជា ភាសាសញ្ញា ប្រពន្ធ័អក្សរផុសសំរាប់មនុស្សពិការភ្នែក ឬ ទំនាក់ទំនងផ្ទាល់មាត់) ពីពត៌មានទាំងអស់អំពីវិធានការដែលត្រូវការការយល់ព្រម;

   b. អ្នកយល់ និង យល់ព្រមជាលាយលក្ខណ៍អក្សរចំពោះវិធានការនោះ និង ការយល់ព្រមនេះរៀបរាប់ពីវិធានការនោះ និងរៀបរាប់ពីកំណត់ត្រា (ប្រសិនបើមាន) ដែលនឹងត្រូវបានបង្ហាញ និង ទៅឱ្យនរណា **និង**

   c. អ្នកយល់ហើយថា ការយល់ព្រមគឺមិនប្រកែក (ធ្វើឡើងវិញ) ចំពោះវិធានការដែលបានកើតឡើងបន្ទាប់ពីអ្នកបានផ្តល់ការយល់ព្រម និងមុនពេលអ្នកបានដកវាវិញឡើយ។

2. **តើឪពុក/ម្តាយអាចលុបចោលការយល់ព្រមវិញដែរឬទេ?**

   a. ប្រាកដជាបាន។ លោកអ្នកត្រូវតែដាក់ឯកសារជាលាយល័ក្ខអក្សរទៅបុគ្គលិករបស់ LEA ដើម្បីស្នើសុំលុបចោលការយល់ព្រមវិញចំពោះការអប់រំពិសេស និងសេវាកម្មនានាដែលទាក់ទង ;

   b. នៅពេលលោកអ្នកលុបចោលការយល់ព្រមវិញចំពោះការអប់រំពិសេស និងសេវាកម្មនានាដែលទាក់ទង LEA ត្រូវតែផ្តល់ឱ្យលោកអ្នកនូវសេចក្តីប្រកាសជាលាយល័ក្ខអក្សរជាមុន (Prior Written Notice);

   c. ការអប់រំពិសេស និងសេវាកម្មនានាដែលទាក់ទងមិនអាចបញ្ឈប់រហូតដល់ LEA ផ្តល់ឱ្យលោកអ្នកនូវសេចក្តីប្រកាសជាលាយល័ក្ខអក្សរជាមុន (Prior Written Notice);

   d. សេចក្តីប្រកាសជាមុន (Prior Notice) ត្រូវបានកំណត់រយៈពេល១០ថ្ងៃតាមប្រតិទិន ;

   e. បុគ្គលិក LEA មិនអាចប្រើប្រាស់ការសម្របសម្រួល ឬដំណើរការតាមនីតិវិធី ដើម្បីបដិសេធលើការលុបចោលការយល់ព្រមរបស់លោកអ្នកបានឡើយ ;

   f. LEA នឹងមិនត្រូវបានចាត់ទុកថាល្មើសចំពោះលក្ខខណ្ឌតម្រូវក្នុងការធ្វើឱ្យ FAPE ត្រូវបានផ្តល់ឱ្យក្មេងនេះ ដោយសារការខកខានមិនបានផ្តល់ឱ្យក្មេងនេះនូវការអប់រំពិសេសបន្ថែម និងសេវាកម្មនានាដែលទាក់ទងនោះឡើយ ;

   g. LEA មិនត្រូវបានតម្រូវឱ្យធ្វើការកែប្រែកំណត់ត្រាការអប់រំរបស់ក្មេងនេះ ដើម្បីដកចេញនូវសេចក្តីបញ្ជាក់ណាមួយចំពោះការទទួលយករបស់ក្មេងនេះនូវការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានា ដោយសារការលុបចោលការយល់ព្រមវិញនោះទេ។

   h. LEA មិនត្រូវបានតម្រូវឱ្យធ្វើការរៀបចំប្រជុំក្រុម IEP ឬបង្កើត IEP សំរាប់ក្មេងនេះសំរាប់ការផ្តល់ជាបន្ថែមនូវការអប់រំពិសេស និងសេវាកម្មដែល ទាក់ទងនោះឡើយ។

## F. <u>តើការយល់ព្រមរបស់ឪពុកម្តាយត្រូវការនៅពេលណា?</u>

### 1. ការវាយតំលៃជាដំបូង (34 CFR §300.300)

a. ច្បាប់ទូទៅ: ការយល់ព្រមសំរាប់ការវាយជាដំបូង

LEA របស់អ្នកមិនអាចធ្វើការវាយតំលៃជាដំបូងណាមួយចំពោះកូនរបស់អ្នកដើម្បីកំណត់ថាតើកូនរបស់អ្នកមានសិទ្ធិនៅក្រោមផ្នែក B នៃ IDEA ដើម្បីទទួលបានការអប់រំពិសេស និង សេវាកម្មទាក់ទងផ្សេងៗទៀតនោះ ដោយគ្មានការផ្តល់ឱ្យអ្នកជាមុននូវ សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរជាមុន ពីវិធានការដែលបានស្នើឡើង និង ដោយមិនបានទទួលការយល់ព្រមរបស់អ្នកដូចដែលបានពិពណ៌នាក្រោមចំណងជើង***ការយល់ព្រមពីឪពុកម្តាយ*** (***Parental Consent***)។

LEA របស់អ្នកត្រូវតែធ្វើការប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីទទួលបានការយល់ព្រមដែលបានជូនដំណឹងរួចពីអ្នក សំរាប់ការវាយតំលៃជាដំបូង ដើម្បីសំរេចចិត្តថាតើកូនរបស់អ្នកជាកុមារមានពិការភាពឬទេ។ ការយល់ព្រមរបស់អ្នកសំរាប់ការវាយតំលៃជាដំបូង មិនមានន័យថាអ្នកក៏ផ្តល់ការយល់ព្រមឱ្យ

LEA ចាប់ផ្តើមផ្តល់ការអប់រំពិសេស និង សេវាកម្មទាក់ទងនានាទៅឱ្យកូនរបស់អ្នកនោះឡើយ ។ ប្រសិនបើកូនរបស់អ្នកចុះឈ្មោះរៀននៅក្នុងសាលារដ្ឋ ឬ អ្នកកំពុងស្វែងរកចុះឈ្មោះឱ្យកូនរបស់អ្នកនៅក្នុងសាលរដ្ឋ ហើយ អ្នកបានបដិសេធផ្តល់ការយល់ព្រម ឬមិនបានឆ្លើយតបទៅនឹងសំណើសុំការយល់ព្រម សំរាប់ការវាយតំលៃជាដំបូង LEA របស់អ្នកអាច (ប៉ុន្តែមិនចាំបាច់) ស្វះស្វែងដើម្បីធ្វើការវាយតំលៃជាដំបូងចំពោះកូនរបស់អ្នក ដោយប្រើការសម្រុះសម្រួលនៃច្បាប់ (Act's mediation) ឬ ពាក្យបណ្តឹងតាមផ្លូវច្បាប់ (due process complaint) ការប្រជុំរកដំណោះស្រាយ (resolution meeting) និង នីតិវិធីសវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង (impartial due process hearing procedures) ។ LEA របស់អ្នកនឹងមិនបំពានលើកាតព្វកិច្ចរបស់គេ ក្នុងការរកទីកន្លែង បញ្ជាក់អត្តសញ្ញាណ និង វាយតំលៃចំពោះកូនរបស់អ្នកឡើយ ប្រសិនបើគេមិនបន្តការវាយតំលៃចំពោះកូនរបស់អ្នកក្នុងកាលៈទេសៈទាំងនេះ ។

b. ច្បាប់ពិសេសសំរាប់ការវាយតំលៃជាដំបូងចំពោះមនុស្សដែលស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ

តាមច្បាប់របស់រដ្ឋ Pennsylvania ប្រសិនបើកុមារម្នាក់ត្រូវបានកំណត់ថាជាមនុស្សដែលស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ មានន័យថាទីកន្លែងរបស់ឪពុកម្តាយរបស់កុមារនេះមិនត្រូវបានគេស្គាល់ ឬ សិទ្ធិរបស់ឪពុកម្តាយត្រូវបានបញ្ឈប់ដោយអនុលោមទៅតាមច្បាប់របស់រដ្ឋ ។ ដោយហេតុនេះ នរណាម្នាក់ក្រៅពីឪពុកម្តាយ ត្រូវបានចាត់តាំងឱ្យធ្វើការសំរេចចិត្តលើការអប់រំរបស់កុមារ ។ ដូច្នេះការយល់ព្រមសំរាប់ការវាយតំលៃជាដំបូង គួរតែត្រូវបានទទួលពីបុគ្គលដែលត្រូវបានចាត់តាំងនេះ ។

*មនុស្សដែលស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ (Ward of the State)* ដូចបានប្រើនៅក្នុង IDEA, រួមមានពីរប្រភេទផ្សេងទៀត ដោយរួមបញ្ចូលដែរនូវកុមារដែលជា:

1. កូនចិញ្ចឹមដែលគ្មានឪពុកម្តាយចិញ្ចឹម
2. ត្រូវបានចាត់ទុកជាមនុស្សដែលស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ ដោយយោងតាមច្បាប់រដ្ឋ **ឬ**
3. ស្ថិតក្រោមអាណាព្យាបាលស្របច្បាប់របស់ ភ្នាក់ងារសាធារណៈផ្នែកសុខុមាលភាពរបស់កុមារ ។

## 2. ការយល់ព្រមចំពោះទីកន្លែងជាដំបូងសំរាប់ការអប់រំពិសេស (34 CFR §300.300)

*ការយល់ព្រមរបស់ឪពុកម្តាយសំរាប់សេវាកម្មនានា*

LEA របស់អ្នកត្រូវតែទទួលការយល់ព្រមដែលបានជូនជាដំណឹងរួចពីអ្នក មុនពេលផ្តល់ការអប់រំពិសេស និង សេវាកម្មទាក់ទងផ្សេងៗទៅឱ្យកូនរបស់អ្នក ជាលើកដំបូង ។ LEA របស់អ្នកត្រូវតែធ្វើការប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីទទួលបានការយល់ព្រមដែលបានជូនជាដំណឹងរួចពីអ្នក មុនពេលផ្តល់ការអប់រំពិសេស និង សេវាកម្មទាក់ទងផ្សេងៗទៅឱ្យកូនរបស់អ្នកជាលើកដំបូង ។

**<u>ប្រសិនបើ អ្នកមិនបានឆ្លើយតបទៅនឹងសំណើ ដើម្បីផ្តល់ការយល់ព្រមរបស់អ្នកដើម្បីឱ្យកូនអ្នកទទួលបានការអប់រំពិសេស និង សេវាកម្មទាក់ទងផ្សេងៗ ជាលើកដំបូង ឬ ប្រសិនបើអ្នកបដិសេធការយល់ព្រមបែបនេះ LEA របស់អ្នកអាចមិនប្រើនីតិវិធីទទួលការការពារ (ឧទាហរណ៍ ការសម្រុះសម្រួល បណ្តឹងតាមផ្លូវច្បាប់ ការប្រជុំរកដំណោះស្រាយ និង នីតិវិធីសវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង) ដើម្បីទទួលបានការព្រមព្រៀង ឬ សាលក្រមណាមួយ ដែលថាការអប់រំពិសេស និង សេវាកម្មទាក់ទងផ្សេងៗ ដូចបានណែនាំដោយក្រុម IEP របស់កូនអ្នក ប្រហែលត្រូវបានផ្តល់ទៅឱ្យកូនរបស់អ្នកដោយគ្មានការយល់ព្រមរបស់អ្នក ។</u>**

ប្រសិនបើ អ្នកបដិសេធផ្តល់ការយល់ព្រមរបស់អ្នកសំរាប់ឱ្យកូនអ្នកចាប់ផ្តើមទទួលការអប់រំពិសេស និង សេវាកម្មទាក់ទងផ្សេងៗ ឬ ប្រសិនបើអ្នកមិនឆ្លើយតបទៅនឹងសំណើដើម្បីទទួលបានការយល់ព្រមនេះ ហើយ LEA មិនផ្តល់ឱ្យកូនរបស់អ្នកនូវការអប់រំពិសេស និង សេវាកម្មទាក់ទងផ្សេងៗ ដែលគេបានស្វះស្វែងរកការយល់ព្រមរបស់អ្នកហើយនោះ LEA របស់អ្នក:

1. គឺមិនបានរំលោភបំពានលើលក្ខខណ្ឌដែលតម្រូវឱ្យផ្តល់ FAPE សំរាប់កូនរបស់អ្នក ចំពោះបរាជ័យរបស់គេក្នុងការផ្តល់សេវាកម្មទាំងនោះទៅឱ្យកូនរបស់អ្នកនោះឡើយ **<u>និង</u>**
2. មិនតម្រូវឱ្យមានការប្រជុំរបស់ IEP ឬ បង្កើត IEP សំរាប់កូនរបស់អ្នកសំរាប់ការអប់រំពិសេស និង សេវាកម្មទាក់ទងផ្សេងៗ ដែលគេបានស្នើសុំការយល់ព្រមពីអ្នកហើយនោះ ។

## 3. ការយល់ព្រមសំរាប់ការវាយតំលៃឡើងវិញ (34 CFR §300.300)

*LEA របស់អ្នកត្រូវតែទទួលការយល់ព្រមដែលបានជូនដំណឹងរួចពីអ្នក មុនពេលវាយតំលៃកូនរបស់អ្នកឡើងវិញ លើកលែងតែ LEA របស់អ្នកអាចបង្ហាញថា:*

1. គេបានអនុវត្តជំហានសមរម្យទាំងឡាយដើម្បីទទួលបានការយល់ព្រមរបស់អ្នកសំរាប់ការវាយតំលៃឡើងវិញរបស់កូនអ្នក រួចហើយ **និង**
2. អ្នកមិនបានឆ្លើយតប ។

## 4. តើអ្វីជាឯកសារនៃកិច្ចប្រឹងប្រែងសមរម្យដើម្បីទទួលបានការយល់ព្រមពីឪពុកម្តាយ ? (34 CFR §300.300)

LEA របស់អ្នកត្រូវតែធានាថែរក្សាឯកសារនៃកិច្ចប្រឹងប្រែងសមរម្យ ដើម្បីទទួលបានការយល់ព្រមពីឪពុកម្តាយសំរាប់ការវាយតំលៃជាដំបូង ដើម្បីផ្តល់នូវការអប់រំពិសេស និង សេវាកម្មទាក់ទងជាលើកដំបូង ដើម្បីធ្វើការវាយតំលៃឡើងវិញ និង រកទីតាំងឪពុកម្តាយរបស់មនុស្សដែលស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ សំរាប់ការវាយតំលៃជាដំបូង ។ ឯកសារនេះត្រូវរួមបញ្ចូលកំណត់ត្រានៃគោលបំណងរបស់ LEA ក្នុងចំណុចទាំងនេះ ដូចជា:

1. កំណត់ត្រាលម្អិតពីការទូរស័ព្ទដែលបានធ្វើឡើង ឬ ដែលបានព្យាយាមធ្វើ និង លទ្ធផលនៃការទូរស័ព្ទទាំងនោះ;
2. ច្បាប់ចំលងនៃសំបុត្រឆ្លើយឆ្លងដែលបានធ្វើទៅឪពុកម្តាយ និង ចំលើយផ្សេងទៀតដែលបានទទួល **និង**
3. កំណត់ត្រាលម្អិតពីទស្សនកិច្ច ទៅផ្ទះ និង កន្លែងធ្វើការរបស់ឪពុកម្តាយដែលបានធ្វើឡើង និង លទ្ធផលនៃការទស្សនកិច្ចទាំងនោះ ។

## 5. តើនៅពេលណាដែលការយល់ព្រមមិនតម្រូវឱ្យមាន ទាក់ទងទៅនឹងការវាយតំលៃ ?

<u>**ការយល់ព្រមរបស់អ្នកមិនតម្រូវឱ្យមាន មុនពេល LEA *របស់អ្នកអាចនឹង:***</u>

1. ពិនិត្យឡើងវិញលើទិន្នន័យដែលមានស្រាប់ ដែលជាផ្នែកនៃការវាយតំលៃរបស់កូនអ្នក ឬ ការវាយតំលៃឡើងវិញ **ឬ**
2. ឱ្យកូនរបស់អ្នកធ្វើតេស្តមួយ ឬ ធ្វើការវាយតំលៃដ៏ទៃទៀតដែលបានផ្តល់ឱ្យកុមារគ្រប់រូប លើកលែងតែ មុនពេលដែលការធ្វើតេស្ត ឬការវាយតំលៃតម្រូវឱ្យមានការយល់ព្រមពីគ្រប់ឪពុកម្តាយកុមារទាំងអស់ ។

## 6. តើនឹងមានអ្វីកើតឡើងប្រសិនបើខ្ញុំបដិសេធមិនយល់ព្រមលើការវាយតំលៃឡើងវិញ ?

ប្រសិនបើអ្នកបដិសេធមិនយល់ព្រមលើការវាយតំលៃឡើងវិញ LEA អាចនឹង (ប៉ុន្តែមិនតម្រូវឱ្យ) បន្តការវាយតំលៃឡើងវិញរបស់កូនអ្នក ដោយប្រើការសម្រុះសម្រួល បណ្តឹងតាមផ្លូវច្បាប់ ការប្រជុំរកដំណោះស្រាយ និង នីតិវិធីសវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង ដើម្បីស្វះស្វែងធ្វើការច្រានចោលការបដិសេធរបស់អ្នកដែលមិនយល់ព្រមលើការវាយតំលៃឡើងវិញរបស់កូនអ្នក ។ ដូចគ្នានឹងការការវាយតំលៃជាដំបូង LEA របស់អ្នកគឺមិនរំលោភលើកាតព្វកិច្ចរបស់ខ្លួនក្រោមផ្នែក B នៃ IDEA នោះឡើយ ប្រសិនបើគេបោះបង់ចោលមិនបន្តការវាយតំលៃឡើងវិញ ក្នុងលក្ខណៈបែបនេះ ។

LEA របស់អ្នកប្រហែលជានឹងមិនប្រើប្រាស់ការបដិសេធរបស់អ្នកដែលមិនយល់ព្រមលើសេវាកម្ម ឬ សកម្មភាពមួយ ដើម្បីបដិសេធអ្នក ឬ កូនរបស់អ្នកពីសេវាកម្ម ផលប្រយោជន៍ ឬ សកម្មភាពផ្សេងទៀតនោះឡើយ ។

ប្រសិនបើ អ្នកបានចុះឈ្មោះកូនរបស់អ្នកនៅក្នុងសាលាឯកជនមួយដោយការចំណាយជារបស់អ្នក ឬ ប្រសិនបើអ្នកឱ្យកូនរបស់អ្នករៀននៅផ្ទះ ហើយអ្នកមិនផ្តល់ការយល់ព្រមរបស់អ្នកសំរាប់ការវាយតំលៃជាដំបូងរបស់កូនអ្នក ឬ ការវាយតំលៃឡើងវិញរបស់កូនអ្នក ឬក៏ អ្នកមិនបានឆ្លើយតបទៅនឹងសំណើសុំការយល់ព្រមរបស់អ្នកនោះ LEA ប្រហែលជានឹងមិនប្រើនីតិវិធីរបស់ខ្លួនក្នុងការច្រានចោលការយល់ព្រម (ឧទាហរណ៍ ការសម្រុះសម្រួល បណ្តឹងតាមផ្លូវច្បាប់ ការប្រជុំរកដំណោះស្រាយ និង នីតិវិធីសវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង) និង មិនតម្រូវឱ្យកំណត់ថាកូនរបស់អ្នកមានសិទ្ធិទទួលសេវាកម្មដែលស្មើភាពនោះឡើយ (សេវាកម្មនានាដែលមានសំរាប់កុមារពិការដែលឪពុកម្តាយឱ្យរៀននៅសាលាឯកជន) ។

## 7. តើអ្វីនឹងកើតឡើងប្រសិនបើខ្ញុំមិនយល់ស្របនឹងការវាយតំលៃ ?

### a. ការវាយតំលៃការអប់រំដោយឯករាជ្យ (34 CFR §300.502)

#### 1) ទូទៅ

ដូចបានពិពណ៌នាខាងក្រោម អ្នកមានសិទ្ធិទទួលបានការវាយតំលៃការអប់រំដោយឯករាជ្យ (IEE) សំរាប់កូនរបស់អ្នក ប្រសិនបើអ្នកមិនយល់ព្រមនឹងការវាយតំលៃដែលត្រូវបានទទួលដោយ LEA របស់អ្នក ។ ប្រសិនបើអ្នកស្នើសុំឱ្យមាន IEE, LEA ត្រូវតែផ្តល់ឱ្យអ្នកនូវពត៌មានអំពីទីកន្លែងដែលអ្នកទទួលបាន IEE និង អំពីលក្ខខណ្ឌវិនិច្ឆ័យរបស់ LEA ដែលអនុវត្តចំពោះ IEEs ។

#### 2) និយមន័យ

a) *ការវាយតំលៃការអប់រំដោយឯករាជ្យ* មានន័យថាជាការវាយតំលៃដែលត្រូវបានធ្វើឡើងដោយអ្នកពិនិត្យវាយតំលៃដែលមានសមត្ថភាព ហើយដែលមិនមែនបំរើការឱ្យ LEA ដោយទទួលខុសត្រូវលើការអប់រំរបស់កូនអ្នក ។

b) *ការចំណាយជារបស់រដ្ឋ* មានន័យថា LEA បង់ថ្លៃទាំងអស់លើការវាយតំលៃ ឬ ធានាថាការវាយតំលៃត្រូវបានផ្តល់ឱ្យអ្នកដោយមិនគិតថ្លៃ ស្របតាម ៦ ដែលមានចែងក្នុងផ្នែក B នៃ IDEA ដែលអនុញ្ញាតឱ្យរដ្ឋនីមួយៗប្រើប្រាស់ ប្រភពនៃជំនួយឯកជន សហព័ន្ធ តំបន់ និង រដ្ឋ មួយណាក៏ដោយដែលមាននៅក្នុងរដ្ឋនោះដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃផ្នែក B នៃច្បាប់ ។

**3) សិទ្ធិរបស់ឪពុកម្តាយដើម្បីទទួលការវាយតំលៃ ដោយការចំណាយជារបស់រដ្ឋ**

អ្នកមានសិទ្ធិទទួលបាន IEE សំរាប់កូនរបស់អ្នកដោយការចំណាយជារបស់រដ្ឋ ប្រសិនបើ អ្នកមិនយល់ស្របនឹងការវាយតំលៃចំពោះកូនរបស់អ្នកដែលទទួលបានដោយ LEA របស់អ្នក គោរពតាមលក្ខខណ្ឌដូចខាងក្រោម:

a) ប្រសិនបើអ្នកស្នើសុំ IEE សំរាប់កូនរបស់អ្នកដោយការចំណាយជារបស់រដ្ឋ LEA របស់អ្នក (ដោយគ្មានការពន្យាពេលដែលមិនចាំបាច់) ត្រូវតែ: (a) ដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ ស្នើសុំឱ្យមានសវនាការមួយ ដើម្បីបង្ហាញថាការវាយតំលៃរបស់ IEE ចំពោះកូនអ្នកគឺសមស្រប ឬក៏ (b) ផ្តល់ IEE ដោយការចំណាយជារបស់រដ្ឋ លើកលែងតែ LEA បង្ហាញនៅក្នុងសវនាកាថា ការវាយតំលៃចំពោះកូនអ្នកដែលអ្នកបានទទួលនោះ មិនបំពេញលក្ខខណ្ឌវិនិច្ឆ័យរបស់ LEA ។

b) ប្រសិនបើ LEA របស់អ្នកស្នើឱ្យមានសវនាការមួយ ហើយ ការសំរេចចុងក្រោយគឺថាការវាយតំលៃរបស់ LEA ចំពោះកូនរបស់អ្នកគឺសមស្រប អ្នកនៅតែមានសិទ្ធិទទួល IEE ប៉ុន្តែមិនមែនដោយការចំណាយជារបស់រដ្ឋនោះឡើយ ។

c) ប្រសិនបើអ្នកស្នើសុំ IEE សំរាប់កូនអ្នក LEA ប្រហែលជានឹងសួរពីហេតុផលដែលអ្នកបដិសេធនឹងការវាយតំលៃចំពោះកូនរបស់អ្នកដែលទទួលបានដោយ LEA របស់អ្នក ។ ប៉ុន្តែ LEA របស់អ្នកប្រហែលជានឹងមិនត្រូវការការពន្យល់ និងប្រហែលនឹងមិនពន្យាពេលដោយគ្មានហេតុផល មិនថាក្នុងការផ្តល់ IEE សំរាប់កូនរបស់អ្នក ដោយចំណាយជារបស់រដ្ឋ ឬក្នុងការដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ដើម្បីស្នើសុំឱ្យមាន សវនាការតាមផ្លូវច្បាប់ ដើម្បីការពារការវាយតំលៃរបស់ LEA ចំពោះកូនរបស់អ្នក ។

d) អ្នកត្រូវបានផ្តល់សិទ្ធិឱ្យទទួល IEE សំរាប់កូនរបស់អ្នកតែមួយគត់ដោយការចំណាយជារបស់រដ្ឋ រាល់ពេលដែល LEA របស់អ្នកធ្វើការវាយតំលៃចំពោះកូនអ្នក ដែលអ្នកមិនយល់ស្រប ។

e) លក្ខខណ្ឌវិនិច្ឆ័យរបស់ LEA

ប្រសិនបើ IEE គឺជាការចំណាយរបស់រដ្ឋ លក្ខខណ្ឌវិនិច្ឆ័យដែលការវាយតំលៃត្រូវបានទទួល តាមលក្ខខណ្ឌនេះ រួមទាំងទីកន្លែងនៃការវាយតំលៃ និង សមត្ថភាពរបស់អ្នកពិនិត្យការវាយតំលៃ ត្រូវតែដូចនឹងលក្ខខណ្ឌវិនិច្ឆ័យដែល LEA ប្រើនៅពេលគេផ្តួចផ្តើមការវាយតំលៃ (នៅកំរិតដែលលក្ខខណ្ឌទាំងនោះស្របជាមួយនឹងសិទ្ធិរបស់អ្នកក្នុងការទទួល IEE) ។ លើកលែងចំពោះលក្ខខណ្ឌវិនិច្ឆ័យដែលបានពិពណ៌នាខាងលើ LEA ប្រហែលជានឹងមិនដាក់លក្ខខណ្ឌ ឬ កាលវេលាកំណត់ទាក់ទងនឹងការទទួលបាន IEE ដោយការចំណាយរបស់ជារដ្ឋឡើយ ។

**b. ការវាយតំលៃដែលផ្តួចផ្តើមដោយឪពុកម្តាយ**

ប្រសិនបើ អ្នកទទួលបាន IEE សំរាប់កូនរបស់អ្នកដោយការចំណាយជារបស់រដ្ឋ ឬ អ្នកចែករំលែករួមជាមួយ LEA ចំពោះការវាយតំលៃលើកូនរបស់អ្នក ដែលអ្នកទទួលបានដោយការចំណាយជារបស់អ្នក:

1) LEA របស់អ្នកត្រូវតែពិនិត្យពិចារណាលើលទ្ធផលនៃការវាយតំលៃរបស់កូនអ្នក ប្រសិនបើវាបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យរបស់ LEA ចំពោះ IEEs ក្នុងការសំរេចចិត្តមួយណាក៏ដោយដែលបានធ្វើឡើងដោយគោរពតាមការផ្តល់ FAPE ឱ្យកូនរបស់អ្នក **និង**

2) អ្នក ឬ LEA របស់អ្នកប្រហែលជានឹងបង្ហាញការវាយតំលៃនោះ ជាភស្តុតាងនៅក្នុង សវនាការតាមផ្លូវច្បាប់ទាក់ទងនឹងកូនរបស់អ្នក ។

**c. ការស្នើសុំការវាយតំលៃដោយមន្ត្រីសវនាការ**

ប្រសិនបើមន្ត្រីសវនាការស្នើសុំ IEE សំរាប់កូនរបស់អ្នក ជាផ្នែកមួយនៃសវនាការតាមផ្លូវច្បាប់ តំលៃនៃការវាយតំលៃនោះ ត្រូវតែជាការចំណាយរបស់រដ្ឋ ។

## G. ការយល់ព្រមចំពោះការដាក់បង្ហាញពត៌មានដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួន (34 CFR §300.622)

លុះត្រាណា ពតិមានមាននៅក្នុងកំណត់ត្រាការអប់រំ និង ការដាក់បង្ហាញត្រូវបានផ្តល់សិទ្ធិ ដោយគ្មានការយល់ព្រមរបស់ឪពុកម្តាយក្រោម FERPA ការយល់ព្រមរបស់អ្នកត្រូវតែបានទទួល មុនពេលពតិមានដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួនត្រូវបានបង្ហាញឱ្យភាគីដទៃទៀត ក្រៅពីមន្ត្រីនៃភ្នាក់ងារចូលរួម ។ លើកលែងតែស្ថិតក្រោមកាលៈទេសៈដែលបានបញ្ជាក់ខាងក្រោម ការយល់ព្រមរបស់អ្នកគឺមិនតម្រូវឱ្យមាន មុនពេលពតិមានដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួនត្រូវបានផ្សាយចេញទៅមន្ត្រីនានានៃភ្នាក់ងារចូលរួម សំរាប់គោលបំណងបំពេញតាលក្ខខណ្ឌតម្រូវការនៃផ្នែក B នៃ IDEA ។

ការយល់ព្រមរបស់អ្នក ឬ ការយល់របស់កុមារដែលមានសិទ្ធិ ដែលឈានដល់អាយុពេញវ័យតាមច្បាប់រដ្ឋ ត្រូវតែបានទទួល មុនពេលពតិមានដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួនត្រូវបានផ្សាយចេញទៅមន្ត្រីនានានៃភ្នាក់ងារចូលរួមដែលផ្តល់ ឬ ចំណាយលើសេវាកម្មផ្លាស់ប្តូរ ។

ប្រសិនបើ កូនរបស់អ្នកស្ថិតនៅក្នុង ឬ នឹងចូលរៀនក្នុងសាលាឯកជនណាមួយ ដែលមិនស្ថិតនៅក្នុង LEA ដូចដែលអ្នកស្នាក់នៅ ការយល់ព្រមរបស់អ្នក ត្រូវតែបានទទួល មុនពេលពតិមានដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួនទាំងឡាយរបស់កូនអ្នកត្រូវបានផ្សាយចេញរវាង មន្ត្រីនានានៅក្នុង LEA កន្លែងដែលសាលាឯកជននោះស្ថិតនៅ និង មន្ត្រីនានានៅក្នុង LEA កន្លែងដែលអ្នករស់នៅ ។

## II. ភាពជាសំងាត់នៃពតិមាន

### A. តើនរណាដែលមានសិទ្ធិប្រើប្រាស់ឬមើលពតិមានជាសំងាត់ដែលទាក់ទងនឹងកូនរបស់ខ្ញុំ ? (34 CFR §300.611)

#### 1. ទាក់ទងនឹងភាពជាសំងាត់នៃពតិមាន និយមន័យខាងក្រោមត្រូវអនុវត្ត:

a. *ការបំផ្លាញ (Destruction)* មានន័យថា ការបំផ្លាញជារូបវ័ន្ត ឬ ការដកចេញនូវលក្ខណៈអត្តសញ្ញាណផ្ទាល់ខ្លួនពីពតិមាន ដូច្នេះ ពតិមាននោះ មិនមានលក្ខណៈអាចកំនត់អត្តសញ្ញាណផ្ទាល់ខ្លួនតទៅទៀតឡើយ ។

b. *កំនត់ត្រាការអប់រំ (Education records)* មានន័យថា ជាប្រភេទកំនត់ត្រានានាដែលគ្របដណ្តប់ក្រោមនិយមន័យនៃ “កំនត់ត្រាការអប់រំ” នៅក្នុង 34 CFR ផ្នែក 99 (ជាច្បាប់បញ្ញត្តិដែលអនុវត្តសិទ្ធិទទួលការអប់រំសំរាប់គ្រួសារ និងច្បាប់ឯកជនភាព នៅឆ្នាំ 1974, 20 U.S.C. 1232g (FERPA)) ។

c. *ភ្នាក់ងារចូលរួម (Participating agency)* មានន័យថា ជាភ្នាក់ងារអប់រំក្នុងតំបន់ (LEA) ណាមួយ ភ្នាក់ងារឬស្ថាប័ន ដែលប្រមូល ថែរក្សា ឬក៏ ប្រើប្រាស់ពតិមានដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួន ឬក៏ កន្លែងដែលពតិមានត្រូវបានទទួលពី នៅក្រោមផ្នែក B នៃ IDEA ។

d. ***ដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួន (Personally identifiable)*** **(34 CFR §300.32)** មានន័យថា ជាពតិមានដែលមាន:

1) ឈ្មោះរបស់កូនអ្នក ឈ្មោះអ្នកដែលជាឪពុកម្តាយ ឬ ឈ្មោះរបស់សមាជិកគ្រួសារណាម្នាក់ផ្សេងទៀត;
2) អាស័យដ្ឋានរបស់កូនអ្នក;
3) លក្ខណៈអត្តសញ្ញាណផ្ទាល់ខ្លួនមួយ ដូចជា លេខសន្តិសុខសង្គមរបស់កូនអ្នក ឬក៏ អត្តលេខសិស្ស; **ឬ**
4) បញ្ជីនៃអត្តចរិតផ្ទាល់ខ្លួន ឬ ពតិមានផ្សេងៗទៀតដែលអាចឱ្យគេកំណត់អត្តសញ្ញាណរបស់កូនអ្នក ដោយភាពប្រាកដសមស្របមួយ ។

#### 2. សិទ្ធិប្រើប្រាស់ឬចូលមើល (34 CFR §300.613)

##### a. សិទ្ធិប្រើប្រាស់ឬចូលមើលរបស់ឪពុកម្តាយ (Parent Access)

ភ្នាក់ងារអប់រំក្នុងតំបន់ (LEA) ត្រូវតែអនុញ្ញាតឱ្យអ្នក ធ្វើអធិការកិច្ច និងពិនិត្យសារឡើងវិញ នូវកំនត់ត្រាអប់រំនានាដែលទាក់ ទងនឹងកូនរបស់អ្នក ដែលត្រូវបានប្រមូល ថែរក្សា ឬប្រើប្រាស់ ដោយភ្នាក់ងារអប់រំក្នុងតំបន់(LEA)របស់អ្នក នៅក្រោមផ្នែក B នៃ IDEA ។ ភ្នាក់ងារចូលរួម ត្រូវតែប្រតិបត្តិតាមសំនូមពររបស់អ្នកដើម្បីធ្វើអធិការកិច្ច និងពិនិត្យសារឡើងវិញនូវកំនត់ត្រាការអប់រំនានា លើ កូនរបស់អ្នក ដោយគ្មានការពន្យាពេលដែលមិនចាំបាច់ ឬក៏មុនពេលប្រជុំណាមួយទាក់ទងនឹង IEP ឬក៏ សវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង ណាមួយ (រួមបញ្ចូលការប្រជុំមួយរកដំណោះស្រាយ ឬ សវនាការទាក់ទងនឹងវិន័យ) ហើយដោយគ្មានករណីដែលលើសពី ៤៥ថ្ងៃ បន្ទាប់ពីអ្នកបាន ធ្វើសំនូមពរ ។

1) សិទ្ធិរបស់អ្នកក្នុងការធ្វើអធិការកិច្ច និងត្រួតពិនិត្យសារឡើងវិញ នូវកំនត់ត្រាការអប់រំនានា ដែលរួមបញ្ចូល:
2) សិទ្ធិរបស់អ្នកក្នុងការទទួលបានការឆ្លើយតបពីភ្នាក់ងារចូលរួម ចំពោះសំនូមពរដែលសមរម្យរបស់អ្នក ឱ្យមានការពន្យល់ និង ការបកប្រែឬបកស្រាយនៃកំនត់ត្រានានា;
3) សិទ្ធិរបស់អ្នកដើម្បីសំនូមពរភ្នាក់ងារចូលរួម ផ្តល់ឯកសារថតចំលងនៃកំនត់ត្រានានា ប្រសិនបើ អ្នកមិនអាចធ្វើអធិការកិច្ច និងត្រួត ពិនិត្យសារឡើងវិញកំណត់ត្រាទាំងនោះដោយមានប្រសិទ្ធិភាព លុះត្រាតែអ្នកទទួលបានឯកសារថតចំលងទាំងនោះ; **និង**
4) សិទ្ធិរបស់អ្នកដើម្បីមានអ្នកសំណាងក្នុងការធ្វើអធិការកិច្ច និងត្រួតពិនិត្យកំនត់ត្រានានាឡើងវិញ ។
   a) ភ្នាក់ងារចូលរួមអាចសន្មត់ថាអ្នកមានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យសារឡើងវិញនូវកំនត់ត្រានានា ដែលទាក់ទងនឹង កូនរបស់អ្នក លុះត្រាតែត្រូវបានឱ្យដំបូន្មានថា អ្នកមិនមានសិទ្ធិនៅក្រោមច្បាប់រដ្ឋជាធរមាន ដែលគ្រប់គ្រងបញ្ហាទាំងនោះ ដូចជា ភាពជាអាណាព្យាបាល ឬ ការបែកបាក់ និង ការលែងលះ ។
   b) ប្រសិនបើ**កំនត់ត្រាការអប់រំណាដែលរួមបញ្ចូលពតិមានរបស់កុមារលើសពីម្នាក់** អាព្យាបាលនៃកុមារទាំងនោះមានសិទ្ធិ ធ្វើអធិការកិច្ច និងត្រួតពិនិត្យសារឡើងវិញតែចំពោះពតិមានដែលទាក់ទងនិងកូនរបស់ពួកគេប៉ុណ្ណោះ ឬក៏ ទទួលដំណឹង អំពីពតិមានជាក់លាក់នោះ ។

c) ផ្អែកលើសំនូមពរ ភ្នាក់ងារចូលរួមនានា ត្រូវតែផ្តល់ឱ្យអ្នកនូវ **បញ្ជីនៃប្រភេទ និងទីតាំងនៃកំនត់ត្រាអប់រំទាំងឡាយ** ដែលត្រូវបានប្រមូល ថែរក្សា ឬប្រើប្រាស់ដោយភ្នាក់ងារនោះ។

### b. សិទ្ធិប្រើប្រាស់ឬចូលមើលដែលត្រូវបានផ្តល់ផ្សេងទៀត (34 CFR §300.614)

ភ្នាក់ងារចូលរួមនីមួយៗ ត្រូវតែរក្សាទុកកំនត់ត្រាមួយពី ភាគីទាំងឡាយដែលទទួលបានសិទ្ធិប្រើប្រាស់ឬចូលមើលកំនត់ត្រាអប់រំនានា ដែលត្រូវបានប្រមូល ថែរក្សា ឬប្រើប្រាស់ ក្រោមផ្នែក B នៃ IDEA (លើកលែងតែ ការប្រើប្រាស់ឬពិនិត្យមើល ដោយឪពុកម្តាយ និងបុគ្គលិកដែលមានសិទ្ធិនៃភ្នាក់ងារចូលរួម) រួមបញ្ចូល ទាំងឈ្មោះរបស់ភាគីនេះ កាលបរិច្ឆេទផ្តល់សិទ្ធិប្រើប្រាស់ឬចូលមើល ហើយនិងគោលបំនងដែលអនុញ្ញាតឱ្យភាគីនោះមានសិទ្ធិប្រើប្រាស់កំនត់ត្រាទាំងនោះ។

## 3. តម្លៃ

ភ្នាក់ងារចូលរួមនីមួយៗអាចនឹងគិតថ្លៃលើឯកសារថតចំលងនៃកំនត់ត្រានានា (34 CFR §300.617) ដែលគេបានធ្វើឱ្យអ្នកក្រោមផ្នែក B នៃ IDEA ប្រសិនបើតម្លៃនោះមិនរារាំងដោយប្រសិទ្ធិភាពចំពោះការដែលអ្នកអនុវត្តសិទ្ធិរបស់អ្នកដើម្បីធ្វើអធិការកិច្ច និងត្រួតពិនិត្យសារឡើងវិញលើកំនត់ត្រាទាំងនោះ។

ភ្នាក់ងារចូលរួមមួយ អាចនឹងមិនគិតថ្លៃក្នុងការស្រាវជ្រាវរក ឬ ទាញយកពត៌មាន ក្រោមផ្នែក B នៃ IDEA។

## 4. ការកែប្រែកំនត់ត្រាតាមសំនូមពររបស់ឪពុកម្តាយ (34 CFR §300.618)

ប្រសិនបើអ្នកជឿជាក់ថា ពត៌មាននៅក្នុងកំនត់ត្រាការអប់រំដែលទាក់ទងនឹងកូនរបស់អ្នក ដែលត្រូវបានប្រមូល ថែរក្សា ឬក៏ប្រើប្រាស់ នៅក្រោមផ្នែក B នៃ IDEA គឺមិនត្រឹមត្រូវ នាំឱ្យយល់ខុស ឬ បំពានលើសិទ្ធិឯកជន ឬ សិទ្ធិដទៃរបស់កូនអ្នក អ្នកអាចសំនូមពរឱ្យភ្នាក់ងារចូលរួមដែលថែរក្សាពត៌មាននោះ ធ្វើការផ្លាស់ប្តូរពត៌មាននោះវិញ។

ភ្នាក់ងារចូលរួមត្រូវតែសំរេចចិត្តថាតើត្រូវផ្លាស់ប្តូរពត៌មាននោះដោយអនុលោមតាមការស្នើសុំរបស់អ្នកឬក៏យ៉ាងណា នៅក្នុងរយ:ពេលសមរម្យមួយ បន្ទាប់ពីទទួលបានសំណើរបស់អ្នក។

ប្រសិនបើភ្នាក់ងារចូលរួមបដិសេធធ្វើការផ្លាស់ប្តូរពត៌មានដោយអនុលោមទៅតាមសំនូមពររបស់អ្នក ភ្នាក់ងារនោះត្រូវតែផ្តល់ពត៌មានដល់អ្នកពីការបដិសេធ និងផ្តល់ដំបូន្មានដល់អ្នកពីសិទ្ធិចូលទៅសវនាការសំរាប់គោលបំនងនេះ។

## 5. ឱកាសចំពោះសវនាការមួយស្តីពីកំនត់ត្រានានា (34 CFR §300.619)

ផ្អែកលើសំនូមពរ ភ្នាក់ងារអប់រំក្នុងតំបន់(LEA) ត្រូវតែផ្តល់ឱ្យអ្នកនូវឱកាសចំពោះសវនាការដើម្បីតវ៉ាពីពត៌មាននៅក្នុងកំនត់ត្រាអប់រំ ដែលទាក់ទងនឹងកូនអ្នក ដើម្បីធានាថាកំណត់ត្រានោះមិនមាន ភាពមិនត្រឹមត្រូវ នាំឱ្យយលខុស ឬ បើមិនដូច្នេះ បំពានសិទ្ធិឯកជន ឬ សិទ្ធិដទៃរបស់កូនអ្នក។

### a. នីតិវិធីនៃសវនាការ (34 CFR §300.621)

សវនាការមួយ ដើម្បីតវ៉ាពីពត៌មាននៅក្នុងកំនត់ត្រាអប់រំ ត្រូវតែប្រព្រឹត្តឡើងដោយស្របទៅតាមនីតិវិធីខាងក្រោម សំរាប់សវនាការបែបនេះ នៅក្រោមសិទ្ធិទទួលការអប់រំសំរាប់គ្រួសារ និងច្បាប់ឯកជនភាពឆ្នាំ ១៩៧៤ (the Family Educational Rights and Privacy Act of 1974), 20 U.S.C. Section 1233g (FERPA):

1) ភ្នាក់ងារអប់រំ ឬស្ថាប័នអប់រំ ត្រូវរៀបចំសវនាការនោះ នៅក្នុងរយ:ពេលសមរម្យមួយ បន្ទាប់ពីភ្នាក់ងារ ឬស្ថាប័នអប់រំនេះបានទទួលនូវសំនូមពរឱ្យមានសវនាការពីឪពុកម្តាយ ឬ សិស្សដែលមានសិទ្ធិ។
2) ភ្នាក់ងារអប់រំ ឬស្ថាប័នអប់រំ ត្រូវផ្តល់ឱ្យឪពុកម្តាយ ឬ សិស្សដែលមានសិទ្ធិ នូវសេចក្តីជូនដំណឹងពីកាលបរិច្ឆេទ ពេលវេលា និង ទីតាំងឱ្យបានសមស្របមុនពេលសវនាការ។
3) សវនាការអាចត្រូវបានធ្វើឡើងដោយ បុគ្គលណាម្នាក់ រួមបញ្ចូលមន្ត្រីនៃភ្នាក់ងារអប់រំ ឬស្ថាប័នអប់រំ ដែលមិនមានផលប្រយោជន៍ដោយផ្ទាល់ ពីលទ្ធផលនៃសវនាការនោះ។
4) ភ្នាក់ងារអប់រំ ឬស្ថាប័នអប់រំ ត្រូវផ្តល់ឱ្យឪពុកម្តាយ ឬ សិស្សដែលមានសិទ្ធិនូវ ឱកាសពេញលេញ និង ស្មើភាព ដើម្បីបង្ហាញនូវភស្តុតាងក្នុងការតវ៉ាទៅលើ មាតិកានៃកំនត់ត្រាការអប់រំរបស់សិស្ស ដោយផ្អែកលើហេតុផលថា ពត៌មានដែលមាននៅក្នុងកំនត់ត្រាការអប់រំនេះ

មិនត្រឹមត្រូវ នាំឱ្យយល់ខុស ឬក៏ បំពានទៅលើសិទ្ធិឯកជនរបស់សិស្ស។ ឪពុកម្តាយ ឬ សិស្សដែលមានសិទ្ធិអាចត្រូវបានជួយ ឬក៏ធ្វើជាតំណាងឱ្យ ដោយបុគ្គលម្នាក់ ឬច្រើតាមជំរើសរបស់ខ្លួន រួមទាំងមេធាវី ដោយការចំណាយផ្ទាល់ខ្លួន។

5) ភ្នាក់ងារអប់រំ ឬស្ថាប័នអប់រំ ត្រូវធ្វើការសំរេចចិត្តរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ក្នុងកំឡុងពេលសមរម្យមួយ បន្ទាប់ពីសវនាការនេះ។

6) ការសំរេចចិត្តត្រូវតែធ្វើឡើងដោយផ្អែកទាំងស្រុងលើភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការ ហើយ ត្រូវតែរួមបញ្ចូលនូវសេចក្តីសង្ខេបនៃភស្តុតាង និង មូលហេតុសំរាប់ការសំរេចចិត្តនោះ។

**b. លទ្ធផលនៃសវនាការ (34 CFR §300.620)**

ជាលទ្ធផលនៃសវនាការ ប្រសិនបើភ្នាក់ងារចូលរួមសំរេចចិត្តថា ពត៌មាននោះមិនត្រឹមត្រូវ នាំឱ្យយល់ច្រឡំ ឬ បើមិនដូច្នេះបំពានលើសិទ្ធិឯកជន ឬសិទ្ធិផ្សេងៗរបស់កុមារ ភ្នាក់ងារនោះត្រូវតែធ្វើការផ្លាស់ប្តូរពត៌មានតាមការគួរ និងផ្តល់ពត៌មានដល់អ្នកជាលាយលក្ខណ៍អក្សរ។ ជាលទ្ធផលនៃសវនាការ ប្រសិនបើភ្នាក់ងារចូលរួមសំរេចចិត្តថាពត៌មាននោះ ត្រឹមត្រូវ មិននាំឱ្យយល់ច្រឡំ ឬ បើមិនដូច្នេះបំពានលើសិទ្ធិឯកជន ឬ សិទ្ធិដទៃទៀតរបស់កូនអ្នក អ្នកអាចកត់ត្រាចូលក្នុងកំនត់ត្រាដែលរក្សាកំនត់ត្រាពីកូនរបស់អ្នក នូវសេចក្តីថ្លែងមួយដែលផ្តល់មតិយោបល់លើ ពត៌មាននោះ ឬក៏ផ្តល់មូលហេតុផ្សេងៗ ដែលអ្នកមិនយល់ស្របជាមួយនឹងការសំរេចចិត្តរបស់ភ្នាក់ងារចូលរួមនោះ។

ការពន្យល់បែបនេះដែលត្រូវបានកត់ត្រាក្នុងកំនត់ត្រាកូនអ្នកត្រូវតែ:

1. ត្រូវបានថែរក្សាដោយភ្នាក់ងារចូលរួម ជាផ្នែកមួយនៃកំនត់ត្រារបស់កូនអ្នក ដរាបណាកំនត់ត្រា ឬ ចំណែកដែលបានប្រកែកតវ៉ានោះត្រូវបានថែរក្សាដោយភ្នាក់ងារចូលរួម; **<u>និង</u>**
2. ប្រសិនបើភ្នាក់ងារចូលរួម បង្ហាញនូវកំនត់ត្រារបស់កូនអ្នក ឬក៏ផ្នែកដែលប្រកែកតវ៉ា ទៅកាន់ភាគីណាមួយ ការពន្យល់ក៏ត្រូវតែបង្ហាញទៅភាគីនោះផងដែរ។

**c. ការការពារ (34 CFR §300.623)**

**<u>ភ្នាក់ងារចូលរួមនីមួយៗ ត្រូវតែការពារភាពសំងាត់នៃពត៌មានដែលអាចកំណត់ពីអត្តសញ្ញាណផ្ទាល់ខ្លួន ក្នុងដំណាក់កាល ប្រមូលផ្តុំ រក្សាទុក បង្ហាញ និង បំផ្លាញចោល។</u>**

មន្ត្រីម្នាក់នៃភ្នាក់ងារចូលរួមនីមួយៗ ត្រូវតែទទួលទំនួលខុសត្រូវ ក្នុងការធានាភាពជាសំងាត់នៃពត៌មានដែលអាចកំណត់ពីអត្តសញ្ញាណផ្ទាល់ខ្លួន។

គ្រប់បុគ្គលទាំងអស់ ដែលប្រមូល ឬ ប្រើប្រាស់ ពត៌មានដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួន ត្រូវតែទទួលការបណ្តុះបណ្តាល ឬក៏ ការណែនាំទាក់ទងនឹង គោលនយោបាយ និង នីតិវិធីនៃរដ្ឋរបស់អ្នកដែលទាក់ទងនឹងភាពជាសំងាត់ ក្រោមផ្នែក B នៃ IDEA និង FERPA។

ភ្នាក់ងារចូលរួមនីមួយៗត្រូវតែ (សំរាប់ការធ្វើអធិការកិច្ចរបស់រដ្ឋ) ថែរក្សាបញ្ជីបច្ចុប្បន្នមួយដែលមានឈ្មោះ និង មុខតំនែងរបស់បុគ្គលិកទាំងនោះនៅក្នុងភ្នាក់ងារនេះ ដែលពួកគេអាចមានសិទ្ធិប្រើប្រាស់ឬមើលយកពត៌មានដែលអាចកំណត់ពីអត្តសញ្ញាណផ្ទាល់ខ្លួន។

**6. ការបំផ្លាញពត៌មាន (34 CFR §300.624)**

**<u>ភ្នាក់ងារអប់រំក្នុងតំបន់ (LEA) របស់អ្នក ត្រូវតែផ្តល់ពត៌មានដល់អ្នក នៅពេលដែលពត៌មានដែលអាចកំនត់ពីអត្តសញ្ញាណផ្ទាល់ខ្លួនដែលត្រូវបានប្រមូល ថែរក្សា ឬក៏ប្រើប្រាស់នោះ លែងត្រូវការចាំបាច់ ដើម្បីផ្តល់សេវាកម្មអប់រំសំរាប់កូនរបស់អ្នក ហើយពត៌មាននោះត្រូវតែបំផ្លាញទៅតាមសំនូមពររបស់អ្នក។</u>**

**ទោះបីជាយ៉ាងនេះ កំនត់ត្រាអចិន្ត្រៃយ៍នៃឈ្មោះ អាស័យដ្ឋាន ហើយ លេខទូរស័ព្ទ កំរិតអប់រំ កំនត់ត្រាវត្តមាន ថ្នាក់ដែលបានចូលរៀន កំរិតថ្នាក់ដែលបានបញ្ចប់ និង ឆ្នាំសិក្សាដែលបានបញ្ចប់របស់កូនអ្នក អាចត្រូវបានថែរក្សាដោយគ្មានពេលវេលាកំនត់។**

## III. នីតិវិធីបណ្តឹងទៅរដ្ឋ (34 CFR §§300.151-153)

### A. ភាពខុសគ្នារវាង នីតិវិធីបណ្តឹងសវនាតាមផ្លូវច្បាប់ និង នីតិវិធីបណ្តឹងទៅរដ្ឋ

ច្បាប់បញ្ញត្តិនានារបស់ផ្នែក B នៃ IDEA ពន្យល់ពីនីតិវិធីដោយឡែក១ ចំពោះបណ្តឹងទៅរដ្ឋ ហើយនិង ចំពោះបណ្តឹងតាមផ្លូវច្បាប់ និង សវនាការតាមផ្លូវច្បាប់នានា។ ដូចដែលបានពន្យល់ខាងក្រោម បុគ្គល ឬ អង្គភាពណាមួយ អាចដាក់ពាក្យបណ្តឹងទៅរដ្ឋមួយ ដោយចោទប្រកាន់ពីការបំពានលើលក្ខខណ្ឌតម្រូវណាមួយរបស់ផ្នែក B ធ្វើឡើងដោយភ្នាក់ងារអប់រំក្នុងតំបន់ (LEA) ភ្នាក់ងារអប់រំរបស់រដ្ឋ (SEA) ឬក៏ ភ្នាក់ងារសាធារណៈផ្សេងទៀត។ មានតែអ្នក ឬក៏ ភ្នាក់ងារអប់រំក្នុងតំបន់ (LEA)មួយ អាចនឹងដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់មួយ លើបញ្ហាណាមួយដែលទាក់ទងទៅនឹង សំណើ ឬ ការបដិសេធ ធ្វើការផ្តួចផ្តើម ឬ ផ្លាស់ប្តូរអត្តសញ្ញាណ ការវាយតំលៃ ឬក៏ ទីតាំងអប់រំរបស់កុមារពិការ ឬក៏ ការផ្តល់នៃ FAPE ដល់កុមារ។ ខណៈពេលដែលបុគ្គលិករបស់ភ្នាក់ងារអប់រំរដ្ឋ ជាទូទៅ ត្រូវតែដោះស្រាយពាក្យបណ្តឹងទៅរដ្ឋមួយ ក្នុងកាលវេលាកំនត់ ៦០ថ្ងៃ លើកលែងតែកាលវេលាកំនត់នេះ ត្រូវបានពន្យាពេលដោយត្រឹមត្រូវ មន្ត្រីសវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង ត្រូវតែស្តាប់ពាក្យបណ្តឹងតាមផ្លូវច្បាប់នេះ (ប្រសិនបើមិនមានដំណោះស្រាយតាមរយៈ ការប្រជុំរកដំណោះស្រាយមួយ ឬក៏ តាមការសម្រុះសម្រួល) ហើយចេញនូវសេចក្តីសំរេចចិត្តជាលាយលក្ខណ៍អក្សរមួយ ក្នុងអំឡុងពេល ៤៥ថ្ងៃ បន្ទាប់ពីការបញ្ចប់នៃរយៈពេលដំណោះស្រាយ ដូចដែលបានពិពិណនានៅក្នុងឯកសារនេះ ក្រោមចំណងជើង ដំនើរការនៃដំណោះស្រាយ (Resolution Process) លើកលែងតែមន្ត្រីសវនាការ អនុញ្ញាតឱ្យមានការពន្យាពេលច្បាស់លាស់មួយ ចំពោះកាលវេលាកំនត់នេះ ទៅតាមសំនូមពររបស់អ្នក ឬ សំនូមពររបស់ភ្នាក់ងារអប់រំក្នុងតំបន់។ ពាក្យបណ្តឹងទៅរដ្ឋ ឬ ពាក្យបណ្តឹងតាមផ្លូវច្បាប់ និង នីតិវិធីសវនាការ ត្រូវបានពិពិណនាយ៉ាងពេញលេញបន្ថែមទៀតខាងក្រោម។

### B. តើខ្ញុំអាចដាក់ពាក្យបណ្តឹងទៅរដ្ឋដោយវិធីណា ? (34 CFR §300.153)

អង្គភាពមួយ ឬ បុគ្គលម្នាក់ អាចដាក់ពាក្យបណ្តឹងទៅរដ្ឋជាលាយលក្ខណ៍អក្សរ និង មានចុះហត្ថលេខា។

ពាក្យបណ្តឹងទៅរដ្ឋត្រូវតែរួមបញ្ចូល:

1. សេចក្តីថ្លែងមួយដែលថាភ្នាក់ងារអប់រំក្នុងតំបន់មួយ ឬ ភ្នាក់ងាររដ្ឋដទៃទៀត បានបំពានលើលក្ខខណ្ឌតំរូវនៃផ្នែក B របស់ IDEA ឬក៏បញ្ញត្តិនានារបស់វា;
2. ការពិតដែលសេចក្តីថ្លែងនេះត្រូវបានលើកជាសំអាង;
3. ហត្ថលេខា និង ពត៌មានសំរាប់ទាក់ទងរបស់អ្នកដាក់ពាក្យបណ្តឹង; និង
4. ប្រសិនបើចោទប្រកាន់ពីការបំពានដែលទាក់ទងនឹងកុមារម្នាក់ច្បាស់លាស់ ឈ្មោះ និង អាស័យដ្ឋានស្នាក់នៅរបស់កុមារនោះត្រូវតែផ្តល់;
5. ឈ្មោះរបស់សាលារៀនដែលកុមារនោះកំពុងតែសិក្សា;
6. ក្នុងករណីរបស់ កុមារ ឬ យុវជនដែលគ្មានផ្ទះសម្បែង ពត៌មានសំរាប់ទាក់ទង និង ឈ្មោះសាលារៀនដែលកុមារកំពុងសិក្សាដែលអាចមាន ត្រូវតែផ្តល់;
7. សេចក្តីពិពិណនាមួយពី ចរិតលក្ខណៈនៃបញ្ហារបស់កុមារ រួមបញ្ចូលទាំង ការពិតដែលពាក់ព័ន្ធនិងបញ្ហានោះ; **និង**
8. ដំណោះស្រាយដែលបានស្នើឡើងចំពោះបញ្ហា ក្នុងកំរិតដែលបានដឹង និងមានសំរាប់ភាគីដែលដាក់ពាក្យបណ្តឹង នៅខណៈពេលដែលពាក្យបណ្តឹងនោះត្រូវបានដាក់។

ពាក្យបណ្តឹងត្រូវតែអះអាងពីការបំពានមួយដែលបានកើតឡើង មិនលើសពីមួយឆ្នាំមុនកាលបរិច្ឆេទដែលពាក្យបណ្តឹងនោះត្រូវបានទទួល ដូចដែលបានពិពិណនានៅក្រោមចំណងជើង ***ការទទួលយកនៃនីតិវិធីបណ្តឹងទៅរដ្ឋ (Adoption of State Complaint Procedures)***.

ភាគីដែលដាក់ពាក្យបណ្តឹងទៅរដ្ឋ ត្រូវផ្ញើបន្តនូវឯកសារថតចំលងមួយនៃពាក្យបណ្តឹង ទៅភ្នាក់ងារអប់រំក្នុងតំបន់ (LEA) ឬក៏ ភ្នាក់ងាររដ្ឋដទៃទៀតដែលបំរើកុមារ នៅពេលដូចគ្នា ដែលភាគីនេះដាក់ពាក្យបណ្តឹងជាមួយនឹងភ្នាក់ងារអប់រំរបស់រដ្ឋ(SEA)។

ពាក្យបណ្តឹងគួរតែបានផ្ញើទៅ:

ប្រធាននៃផ្នែកអនុវត្តច្បាប់ ការត្រួតពិនិត្យ និង ធ្វើផែនការ (Chief, Division of Compliance, Monitoring and Planning)
ការិយាល័យនៃការអប់រំពិសេស (Bureau of Special Education)
ក្រសួងអប់រំនៃរដ្ឋភេនស៊ីលវេនា (Pennsylvania Department of Education)
333 Market Street, 7th Floor
Harrisburg, PA 17126-0333

## a. នីតិវិធី

### 1) កាលវេលាកំនត់រយៈពេល ៦០ថ្ងៃ បន្ទាប់ពីពាក្យបណ្តឹងមួយត្រូវបានដាក់ទៅ:

1. ធ្វើការស៊ើបអង្កេតនៅនឹងកន្លែងដោយឯករាជ្យមួយ ប្រសិនបើភ្នាក់ងារអប់រំរដ្ឋកំនត់ថា ការស៊ើបអង្កេតនេះ គឺចាំបាច់;
2. ផ្តល់ឱ្យអ្នកដាក់ពាកបណ្តឹង នូវឱកាសដើម្បីប្រគល់ពត៌មានបន្ថែម ដោយផ្ទាល់មាត់ ឬជាលាយល័ក្ខអក្សរ អំពីការអះអាងនៅក្នុងពាក្យបណ្តឹង;
3. ផ្តល់ឱ្យភ្នាក់ងារអប់រំក្នុងតំបន់ ឬក៏ ភ្នាក់ងាររដ្ឋផ្សេងៗ នូវឱកាសដើម្បីឆ្លើយតបទៅនឹងពាក្យបណ្តឹង រួមបញ្ចូល នៅ**កិរិត អប្បបរមា**: (a) តាមជំរើសរបស់ភ្នាក់ងារនោះ សំណើសុំដើម្បីដោះស្រាយពាក្យបណ្តឹង ហើយ (b) ឱកាសមួយសំរាប់ឱ្យឪពុកម្តាយដែលដាក់ពាក្យបណ្តឹង និងភ្នាក់ងារនេះ ព្រមព្រៀងគ្នាដោយស្ម័គ្រចិត្តដើម្បីចូលរួមការសម្រុះសម្រួល
4. ត្រួតពិនិត្យសារឡើងវិញនូវពត៌មានដែលទាក់ទងទាំងអស់ និង រៀបចំការកំនត់ដោយឯករាជ្យមួយ អំពីថាតើភ្នាក់ងារអប់រំក្នុងតំបន់ ឬក៏ ភ្នាក់ងាររដ្ឋផ្សេងៗទៀត កំពុងតែបំពានលើលក្ខខណ្ឌតំរូវណាមួយនៃផ្នែក B របស់ IDEA ឬទេ ហើយ
5. ចេញសេចក្តីសំរេចចិត្តជាលាយលក្ខណ៏អក្សរ ទៅឱ្យអ្នកដាក់ពាក្យបណ្តឹង ដែលដោះស្រាយការចោទប្រកាន់នីមួយៗនៅក្នុងពាក្យបណ្តឹង ហើយរួមទាំង: (a) ការរកឃើញការពិត និងសេចក្តីសន្និដ្ឋាន និង (b) ហេតុផលនៃសេចក្តីសំរេចចុងក្រោយរបស់ភ្នាក់ងារអប់រំរដ្ឋ។

### 2) ការពន្យាពេលវេលា ការសំរេចចុងក្រោយ  និង ការអនុវត្ត

a) ការពន្យាពេលនៃកាលវេលាកំនត់ ៦០ថ្ងៃ អាចត្រូវបានអនុញ្ញាត ប្រសិនបើ: (a) កាលៈទេសៈលើកលែងនានាកើតមានដោយគោរពទៅតាមពាក្យបណ្តឹងទៅរដ្ឋជាក់លាក់ណាមួយ ឬក៏ (b) ឪពុកម្តាយ ឬ ភ្នាក់ងារអប់រំក្នុងតំបន់ ឬ ភ្នាក់ងាររដ្ឋផ្សេងៗទៀតដែលពាក់ព័ន្ធ បានព្រមព្រៀងគ្នាដោយស្ម័គ្រចិត្តក្នុងការពន្យាពេលវេលា ដើម្បីដោះស្រាយបញ្ហាតាមរយៈការសម្រុះសម្រួល ឬក៏ មធ្យោបាយដទៃទៀតក្នុងការដោះស្រាយជំលោះ ប្រសិនបើមាននៅក្នុងរដ្ឋនេះ។

b) សេចក្តីសំរេចចិត្តចុងក្រោយរបស់ភ្នាក់ងារអប់រំរដ្ឋ ត្រូវរួមបញ្ចូលនូវនីតិវិធីអនុវត្តដ៏មានប្រសិទ្ធិភាព ប្រសិនបើត្រូវការ រួមទាំង: (a) សកម្មភាពជំនួយបច្ចេកទេសនានា (b) ការចរចារនានា និង (c) វិធានការកែតម្រូវនានាដើម្បីសំរេចបានការគោរពតាម។

### 3) វិធីសាស្រ្តផ្សេងៗសំរាប់ការបដិសេធចំពោះសេវាកម្មសមស្របផ្សេងៗ

ក្នុងការដោះស្រាយពាក្យបណ្តឹងទៅរដ្ឋមួយ ដែលក្នុងនោះ ភ្នាក់ងារអប់រំរដ្ឋបានរកឃើញ ភាពបរាជ័យក្នុងការផ្តល់សេវាកម្មសមស្របនានា ភ្នាក់ងារអប់រំរដ្ឋត្រូវតែដោះស្រាយនូវ:

a) ការបរាជ័យក្នុងការផ្តល់សេវាកម្មសមស្របនានា រួមបញ្ចូលទាំង វិធានការកែតម្រូវ ដែលសមស្របក្នុងការដោះស្រាយតំរូវការរបស់កុមារ; <u>និង</u>

b) ការផ្តល់ដែលសមស្របនៅពេលអនាគត នូវសេវាកម្មផ្សេងៗសំរាប់កុមារទាំងអស់ដែលមានភាពពិការ។

### 4) ពាក្យបណ្តឹងទៅរដ្ឋ និង សវនាការតាមផ្លូវច្បាប់

ប្រសិនបើពាក្យបណ្តឹងទៅរដ្ឋជាលាយលក្ខណ៏អក្សរត្រូវបានទទួល ដែលវាក៏ជាប្រធានបទនៃសវនាការតាមផ្លូវច្បាប់មួយ ដូចដែលបានពិពណ៌នាក្រោមសវនាការស្តីពី ***ការពាក្យបណ្តឹងតាមផ្លូវច្បាប់*** ឬក៏ ពាក្យបណ្តឹងទៅរដ្ឋ ដែលរួមមានបញ្ហាច្រើនជំពូក ដែលក្នុងនោះមានផ្នែកមួយ ឬក៏ច្រើន នៃសវនាការបែបនេះ  រដ្ឋត្រូវតែដកពាក្យបណ្តឹងទៅរដ្ឋនោះទៅម្ខាង ឬក៏ ផ្នែកណាមួយនៃពាក្យបណ្តឹងទៅរដ្ឋ ដែលកំពុងត្រូវបានដោះស្រាយនៅក្នុងសវនាការតាមផ្លូវច្បាប់ រហូតដល់សវនាការនោះត្រូវបានបញ្ចប់។ បញ្ហាណាមួយនៅក្នុងពាក្យបណ្តឹងទៅរដ្ឋ ដែលមិនមែនជាផ្នែកមួយនៃសវនាការតាមផ្លូវច្បាប់ ត្រូវតែបានដោះស្រាយដោយប្រើកាលវេលាកំនត់ និង នីតិវិធីនានាដែលបានពិពណ៌នាខាងលើ។ ប្រសិនបើបញ្ហាណាមួយដែលលើកឡើងនៅក្នុងពាក្យបណ្តឹងទៅរដ្ឋត្រូវបានសំរេចពីពេលមុនរួច នៅក្នុងសវនាការតាមផ្លូវច្បាប់ ដោយជាប់ពាក់ព័ន្ធនឹងភាគីដដែល (អ្នក និងភ្នាក់ងារអប់រំក្នុងតំបន់) បន្ទាប់មក សេចក្តីសំរេចនៃសវនាការតាមផ្លូវច្បាប់ នឹងត្រូវចងភ្ជាប់នឹងបញ្ហានោះ ហើយ ភ្នាក់ងារអប់រំរដ្ឋត្រូវតែផ្តល់ជាពត៌មានដល់អ្នកដាក់បណ្តឹងថា ការសំរេចចិត្តនោះនឹងត្រូវចងភ្ជាប់។

**ពាក្យបណ្តឹងមួយ ដែលចោទប្រកាន់ពីភាពបរាជ័យរបស់ភ្នាក់ងារអប់រំក្នុងតំបន់ ឬ ភ្នាក់ងាររដ្ឋផ្សេងទៀតក្នុងការអនុវត្ត សេចក្តីសំរេចនៃសវនាការតាមផ្លូវច្បាប់ ត្រូវតែបានដោះស្រាយដោយភ្នាក់ងារអប់រំរដ្ឋ ដោយយោងទៅ នីតិវិធីដែលបានពិពណ៌នាខាងលើ។**

# IV. នីតិវិធីបណ្តឹងតាមផ្លូវច្បាប់

## A. តើខ្ញុំអាចស្នើសុំឱ្យមានសវនាការតាមផ្លូវច្បាប់មួយដោយរបៀបណា ?

### 1. ការដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ (34 CFR §300.507)

**ជាទូទៅ**

**អ្នក ឬក៏ ភ្នាក់ងារអប់រំក្នុងតំបន់ អាចដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ ពីបញ្ហាអ្វីមួយ ដែលទាក់ទងនឹង សំណើសុំមួយ ឬ ការបដិសេធមួយ ក្នុងការផ្តួចផ្តើម ឬក៏ ផ្លាស់ប្តូរអត្តសញ្ញាណ ការវាយតំលៃ ឬ ទីតាំងអប់រំរបស់កូនអ្នក ឬ ការផ្តល់ FAPE ដល់កូនរបស់អ្នក។**

**ពាក្យបណ្តឹងតាមផ្លូវច្បាប់ ត្រូវតែអះអាងពីការបំពានដែលបានកើតឡើង មិនលើសពី ២ឆ្នាំ មុនកាលបរិច្ឆេទដែលអ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់ បានដឹង ឬ គួរតែបានដឹងអំពី វិធានការដែលបានអះអាង ដែលបង្កើតជាមូលដ្ឋាននៃពាក្យបណ្តឹងតាមផ្លូវច្បាប់នេះ។**

កាលវេលាកំនត់ខាងលើ មិនមែនអនុវត្តចំពោះអ្នកឡើយ ប្រសិនបើអ្នកមិនអាចដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ ក្នុងកាលវេលាកំនត់ ពីព្រោះ:

1. ភ្នាក់ងារអប់រំក្នុងតំបន់ បានធ្វើឱ្យយល់ខុសយ៉ាងជាក់លាក់ ថាភ្នាក់ងារនេះបានដោះស្រាយបញ្ហានានា ដែលបានកំនត់នៅក្នុងពាក្យបណ្តឹង។ **ឬ**
2. ភ្នាក់ងារអប់រំក្នុងតំបន់ បានដកហូតពតិមានពីអ្នក ដែលតំរូវឱ្យផ្តល់ដល់អ្នក ក្រោមផ្នែក B របស់ IDEA។

**ពតិមានសំរាប់ឪពុកម្តាយ**

ភ្នាក់ងារអប់រំរដ្ឋត្រូវតែផ្តល់ពតិមានដល់អ្នក ពីសេវាកម្មផ្នែកច្បាប់ និងសេវាកម្មពាក់ព័ន្ធផ្សេងៗទៀតដែលឥតគិតថ្លៃ ឬ មានតំលៃទាប ដែលអាចរកបាននៅក្នុងតំបន់ ប្រសិនបើអ្នកស្នើសុំពតិមាន **ឬ** ប្រសិនបើ អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់ ដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់នោះ។.

## B. មាតិកានៃពាក្យបណ្តឹងតាមផ្លូវច្បាប់ (34 CFR §300.508)

### 1. ជាទូទៅ

ដើម្បីស្នើសុំឱ្យមានសវនាការមួយ អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់ (ឬក៏មេធាវីរបស់អ្នក ឬ មេធាវីរបស់ភ្នាក់ងារអប់រំក្នុងតំបន់) ត្រូវ តែប្រគល់ពាក្យបណ្តឹងតាមផ្លូវច្បាប់ទៅភាគីផ្សេងទៀត។ ពាក្យបណ្តឹងនោះត្រូវតែរួមមានសេចក្តីលំអិតទាំងអស់ (មាតិកា) ដែលរៀបរាប់ខាងក្រោមនេះ និង ត្រូវបានទុកជាការសំងាត់។ ខណ:ពេលដូចគ្នា អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់ (អ្នកណាក៏ដោយដែលដាក់ពាក្យបណ្តឹង) ផ្តល់ពាក្យបណ្តឹងតាមផ្លូវច្បាប់ទៅឱ្យភាគីម្ខាងទៀត ឯកសារថតចំលងត្រូវតែដាក់ទៅ ការិយាល័យដោះស្រាយជំលោះ (ODR).

### 2. មាតិកានៃពាក្យបណ្តឹង

**ពាក្យបណ្តឹងតាមផ្លូវច្បាប់ ត្រូវតែរួមបញ្ចូល:**

a. ឈ្មោះរបស់កុមារ;
b. អាស័យដ្ឋានស្នាក់នៅរបស់កុមារ;
c. ឈ្មោះសាលារៀនរបស់កុមារ;
d. ប្រសិនបើកុមារនេះ គឺជាកុមារ ឬ យុវជនគ្មានផ្ទះសម្បែង ពតិមានសំរាប់ទាក់ទង និង ឈ្មោះនៃសាលារៀនរបស់កុមារ ត្រូវតែផ្តល់;
e. សេចក្តីពិពិណនាមួយពី ចរិតលក្ខណ:នៃបញ្ហារបស់កុមារដែលទាក់ទងនឹង វិធានការដែលបានស្នើសុំ និង បានបដិសេធ រួមបញ្ចូលទាំង ការពិតដែលពាក់ព័ន្ធនិងបញ្ហានោះ; **និង**
f. ដំណោះស្រាយដែលបានស្នើឡើងចំពោះបញ្ហា ក្នុងកំរិតដែលបានដឹង និងមានសំរាប់ភាគីដែលដាក់ពាក្យបណ្តឹង នៅខណ:ពេលដែលពាក្យបណ្តឹងនោះត្រូវបានដាក់។

### 3. សេចក្តីជូនដំណឹងដែលត្រូវការ មុនពេលសវនាការស្តីពីពាក្យបណ្តឹងតាមផ្លូវច្បាប់

អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់ អាចនឹងមិនមានសវនាការតាមផ្លូវច្បាប់ រហូតដល់ពេលអ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់ (ឬមេធាវីរបស់អ្នក ឬ មេធាវីរបស់ភ្នាក់ងារអប់រំក្នុងតំបន់) ដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ ដែលរួមបញ្ចូលពតិមានដែលបានរៀបរាប់ខាងលើ។

### 4. ភាពគ្រប់គ្រាន់នៃពាក្យបណ្តឹង

**<u>ដើម្បីដំណើរការសវនាការតាមផ្លូវច្បាប់ ពាក្យបណ្តឹងត្រូវតែបានពិចារណាថាមានលក្ខណៈគ្រប់គ្រាន់។ ពាក្យបណ្តឹងតាមផ្លូវច្បាប់ នឹងត្រូវបានពិចារណាថាមានលក្ខណៈគ្រប់គ្រាន់ (ដោយបំពេញតាមមាតិកាដែលតម្រូវឱ្យមានខាងលើ) លើកលែងតែ ភាគីដែលទទួលពាក្យបណ្តឹងតាមផ្លូវ (អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់) ផ្តល់ពតិមានដល់មន្ត្រីសវនាការ និង ភាគីម្ខាងទៀត ជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ១៥ថ្ងៃនៃការទទួលបានពាក្យបណ្តឹង ថាភាគីដែលទទួលនោះ ជឿថាពាក្យបណ្តឹងតាមផ្លូវច្បាប់នោះ មិនបំពេញទៅតាមតម្រូវការដែលរៀបរាប់ខាងលើ។</u>**

ក្នុងរយៈពេល ១៥ថ្ងៃនៃការទទួលបានការផ្តល់ពតិមាន ភាគីដែលទទួលពតិមាន (អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់) គិតពិចារណាលើពាក្យបណ្តឹងតាមផ្លូវច្បាប់ថាមិនគ្រប់គ្រាន់ មន្ត្រីសវនាការត្រូវតែសំរេចចិត្ត ប្រសិនបើពាក្យបណ្តឹងតាមផ្លូវច្បាប់នោះ បំពេញតំរូវការដែលបានរៀបរាប់ខាងលើឬយ៉ាងណា និង ផ្តល់ពតិមានដល់អ្នក និង ភ្នាក់ងារអប់រំក្នុងតំបន់ជាលាយល័ក្ខអក្សរភ្លាម១។

### 5. ការកែតម្រូវពាក្យបណ្តឹង

អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់ អាចធ្វើការផ្លាស់ប្តូរលើពាក្យបណ្តឹង តែក្នុងករណីៈ

a. ភាគីម្ខាងទៀតយល់ព្រមលើការផ្លាស់ប្តូរជាលាយល័ក្ខអក្សរ ហើយនិងត្រូវបានផ្តល់ឱកាសដើម្បី ដោះស្រាយ ពាក្យបណ្តឹងតាមផ្លូវច្បាប់ តាមរយៈការប្រជុំរកដំណោះស្រាយ ដែលបានពិពិណនាខាងក្រោម **<u>ឬ</u>**

b. នៅពេលណាក៏បាន តែមិនឱ្យលើសពី ៥ថ្ងៃ មុនពេលសវនាការតាមផ្លូវច្បាប់ចាប់ផ្តើម មន្ត្រីសវនាការផ្តល់ការអនុញ្ញាត សំរាប់ការផ្លាស់ប្តូរទាំងនេះ។

ប្រសិនបើភាគីដែលប្តឹងតវ៉ា (អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់) ធ្វើការផ្លាស់ប្តូរលើពាក្យបណ្តឹងតាមផ្លូវច្បាប់ កាលវេលាកំនត់សំរាប់ការប្រជុំរកដំណោះស្រាយ (ក្នុងរយៈពេល ១៥ថ្ងៃនៃការទទួលពាក្យបណ្តឹង) ហើយនិងអំឡុងពេលសំរាប់ដំណោះស្រាយ (ក្នុងរយៈពេល ៣០ថ្ងៃនៃការទទួលពាក្យបណ្តឹង) ចាប់ផ្តើមម្តងទៀត នៅកាលបរិច្ឆេទដែលពាក្យបណ្តឹងដែលបានផ្លាស់ប្តូរត្រូវបានដាក់។

### 6. ភ្នាក់ងារអប់រំក្នុងតំបន់ ឆ្លើយតបទៅនឹង ពាក្យបណ្តឹងតាមផ្លូវច្បាប់មួយ

ប្រសិនបើ ភ្នាក់ងារអប់រំក្នុងតំបន់ មិនបានធ្វើ ការសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរជាមុនដល់អ្នក ដូចដែលបានពិពណ៌នាក្រោមចំណងជើង ***សេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរជាមុន (Prior Written Notice)*** ទាក់ទងនឹងប្រធានបទនៃបញ្ហាដែលមានក្នុងពាក្យបណ្តឹងតាមផ្លូវច្បាប់របស់អ្នក ភ្នាក់ងារអប់រំក្នុងតំបន់ (ក្នុងរយៈពេល ១០ថ្ងៃនៃការទទួលបានពាក្យបណ្តឹងតាមផ្លូវច្បាប់) ត្រូវតែធ្វើការឆ្លើយតបទៅអ្នកវិញដោយរួមបញ្ចូលៈ

a. ការពន្យល់មួយពីមូលហេតុដែល ភ្នាក់ងារអប់រំក្នុងតំបន់ ស្នើសុំ ឬក៏ បដិសេធ ក្នុងការចាត់វិធានការ ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងតាមផ្លូវច្បាប់;

b. ការពិពិណនាមួយពីជំរើសដទៃទៀត ដែលក្រុម IEP របស់កូនអ្នក បានពិចារណា និង ហេតុផលផ្សេង១ ដែលជំរើសទាំងនោះត្រូវបានជំនាស់;

c. ការពិពណ៌នាពីរាល់នីតិវិធីវាយតំលៃ ការវាយតំលៃ កំណត់ត្រា ឬរបាយការណ៍និមួយ១ដែល LEA បានប្រើជាមូលដ្ឋានសំរាប់វិធានការដែលបានស្នើឡើង ឬបានបដិសេធ ; **<u>និង</u>**

d. ការពិពិណនាមួយពីកត្តានានាដែលទាក់ទងនឹងវិធានការដែលត្រូវបានស្នើឡើង ឬបដិសេធរបស់ LEA។

ការផ្តល់ជាពតិមាននៅក្នុងចំនុច 1 ដល់ 4 ខាងលើ មិនបានរារាំង ភ្នាក់ងារអប់រំក្នុងតំបន់ ពីការពោលអះអាងថា ពាក្យបណ្តឹងតាមផ្លូវច្បាប់របស់អ្នក មិនមានលក្ខណៈគ្រប់គ្រាន នោះឡើយ។

### 7. ភាគីម្ខាងទៀត ឆ្លើយតបទៅនឹងពាក្យបណ្តឹងតាមផ្លូវច្បាប់មួយ

លើកលែងតែករណី ដូចដែលបានចែងក្រោម អនុចំនងជើងខាងលើផ្ទាល់នេះ (***ភ្នាក់ងារអប់រំក្នុងតំបន់ឆ្លើយតបទៅនឹងពាក្យបណ្តឹងតាមផ្លូវច្បាប់មួយ***) ក្នុងរយៈពេល ១០ថ្ងៃនៃការទទួលពាក្យបណ្តឹង ភាគីដែលទទួលបានពាក្យបណ្តឹងតាមផ្លូវច្បាប់ ត្រូវធ្វើការឆ្លើយតបទៅឱ្យភាគីម្ខាងទៀត ដែលដោះស្រាយយ៉ាងជាក់លាក់ចំពោះបញ្ហានានានៅក្នុងពាក្យបណ្តឹងនោះ។

## C. <u>ដំណើរការដោះស្រាយ (34 CFR §300.510)</u>

### 1. ការប្រជុំរកដំណោះស្រាយ

**ក្នុងរយៈពេល ១៥ថ្ងៃនៃការទទួលបានសេចក្តីជូនដំណឹងអំពីពាក្យបណ្តឹងតាមផ្លូវច្បាប់របស់អ្នក និង មុនពេលដែល សវនាការតាមផ្លូវច្បាប់ចាប់ផ្តើម ភ្នាក់ងារអប់រំក្នុងតំបន់ត្រូវតែរៀបចំការប្រជុំជាមួយ អ្នក និង សមាជិកដែលពាក់ព័ន្ធ ឬ សមាជិកនៃក្រុម IEP ដែលមានចំណេះដឹងច្បាស់លាស់ ពីការពិតនានាដែលបានបញ្ជាក់នៅក្នុងពាក្យបណ្តឹងតាមផ្លូវច្បាប់របស់អ្នក ។ ការប្រជុំ :**

a. ត្រូវតែរួមបញ្ចូល អ្នកតំណាងម្នាក់របស់ភ្នាក់ងារអប់រំក្នុងតំបន់ ដែលមានសិទ្ធិធ្វើសេចក្តីសំរេចចិត្ត ជំនួសឱ្យ ភ្នាក់ងារនេះ **និង**

b. អាចមិនរួមបញ្ចូល មេធាវីម្នាក់របស់ភ្នាក់ងារអប់រំក្នុងតំបន់ លើកលែងតែអ្នកត្រូវបានអមមកជាមួយមេធាវីម្នាក់ដែរ ។ អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់ កំនត់នូវសមាជិកដែលទាក់ទងរបស់ក្រុម IEP ដែលអាចចូលរួមការប្រជុំ ។ គោលបំណងនៃការប្រជុំ គឺសំរាប់ឱ្យអ្នកពិភាក្សាពី ពាក្យបណ្តឹងតាមផ្លូវច្បាប់របស់អ្នក និង ការពិតនានាដែលបង្កើតជាមូលដ្ឋាននៃពាក្យបណ្តឹងនេះ ដូច្នេះ ភ្នាក់ងារអប់រំក្នុងតំបន់ មានឱកាសដើម្បី ដោះស្រាយពាក្យបណ្តឹងនោះ ។

c. ការប្រជុំរកដំណោះស្រាយ គឺមិនចាំបាច់ឡើយ ប្រសិនបើ:

   1) អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់យល់ព្រមជាលាយល័ក្ខអក្សរ ក្នុងការបោះបង់ចោលការប្រជុំ; **ឬ**

   2) អ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់យល់ព្រមប្រើប្រាស់ដំណើរការសម្រុះសម្រួល ដូចដែលបានពិពណ៌នាក្រោមចំណងជើង ការសម្រុះសម្រួល ***(Mediation)*** ។

## 2. រយៈពេលនៃដំណោះស្រាយ

**ប្រសិនបើភ្នាក់ងារអប់រំក្នុងតំបន់ មិនបានដោះស្រាយពាក្យបណ្តឹងតាមផ្លូវច្បាប់ បានជាទីពេញចិត្តរបស់អ្នក ក្នុងរយៈពេល ៣០ ថ្ងៃនៃការទទួលបានពាក្យបណ្តឹងតាមផ្លូវច្បាប់ (អំឡុងពេលនៃរយៈពេលសំរាប់ដំនើរការរកដំណោះស្រាយ) សវនាការតាមផ្លូវច្បាប់ អាចនឹងកើតឡើង.**

កាលវេលាកំនត់ ៤៥ថ្ងៃ សំរាប់ការចេញនូវសេចក្តីសំរេចចុងក្រោយ ចាប់ផ្តើមពីពេលហួសកំណត់ ៣០ថ្ងៃនៃរយៈពេលរកដំណោះស្រាយ ជាមួយនឹងការលើកលែងមួយចំនួន សំរាប់ការកែតម្រូវផ្សេងៗដែលត្រូវបានធ្វើឡើងចំពោះ រយៈពេលរកដំណោះស្រាយដែលមានពេល ៣០ថ្ងៃនេះ ដូចដែលរៀបរាប់ខាងក្រោម ។

លើកលែងតែ ករណីដែលអ្នក និង ភ្នាក់ងារអប់រំក្នុងតំបន់ បានព្រមព្រៀងគ្នាក្នុងការបោះបង់ដំនើរការរកដំណោះស្រាយ ឬក៏ ក្នុងការប្រើការសម្រុះសម្រួល ការខកខានរបស់អ្នកក្នុងការចូលរួមការប្រជុំរកដំណោះស្រាយ នឹងពន្យាកាលវេលាកំនត់សំរាប់ដំនើរការដំណោះស្រាយ និង សវនាការតាមផ្លូវច្បាប់ រហូតដល់អ្នកយល់ស្របចូលរួមនៅក្នុងការប្រជុំ ។ ប្រសិនបើបន្ទាប់ពីការខំប្រឹងប្រែងព្យាយាមដែលសមរម្យ និង ការកត់ត្រាជាឯកសារនៃការប្រឹងប្រែងទាំងនោះ ភ្នាក់ងារអប់រំក្នុងតំបន់មិនអាចទទួលបានការចូលរួមពីអ្នកក្នុងការប្រជុំរកដំណោះស្រាយ ភ្នាក់ងារអប់រំក្នុងតំបន់អាច (ក្នុងរយៈពេល ៣០ថ្ងៃនៃរយៈពេលរកដំណោះស្រាយ) ស្នើសុំដល់មន្ត្រីសវនាការ ដើម្បីបដិសេធចោលពាក្យបណ្តឹងតាមផ្លូវច្បាប់របស់អ្នក ។ ការកត់ត្រាឯកសារពីការប្រឹងប្រែងបែបនេះ ត្រូវតែរួមបញ្ចូលក្នុងកំនត់ត្រានៃការប្រឹងប្រែងរបស់ភ្នាក់ងារអប់រំក្នុងតំបន់ ដើម្បីរៀបចំ ពេលវេលា និង ទីកន្លែង ដែលភាគីទាំងពីរបានយល់ព្រម ដូចជា :

1. កំនត់ត្រាលំអិតនៃការទូរស័ព្ទ ដែលភ្នាក់ងារនោះបានធ្វើ និង បានព្យាយាមធ្វើ ហើយនិង លទ្ធផលនៃការទូរស័ព្ទ ទាំងនោះ;
2. ឯកសារចតចំលងនៃសំបុត្រឆ្លើយឆ្លងដែលបានផ្ញើទៅអ្នក និង ការឆ្លើយតបនានាដែលបានទទួល ។ និង
3. កំនត់ត្រាលំអិតនៃការធ្វើទស្សនកិច្ចទៅគេហដ្ឋាន និង កន្លែងធ្វើការរបស់អ្នក ហើយនិង លទ្ធផលនៃការទៅទស្សនកិច្ចទាំងនោះ

ប្រសិនបើភ្នាក់ងារអប់រំក្នុងតំបន់ បរាជ័យក្នុងការរៀបចំការប្រជុំរកដំណោះស្រាយ ក្នុងរយៈពេល ១៥ថ្ងៃនៃការទទួលបានសេចក្តីជូនដំណឹងអំពីបណ្តឹងតាមផ្លូវច្បាប់ **ឬ** ខកខានក្នុងការចូលរួមការប្រជុំរកដំណោះស្រាយ អ្នកអាចនឹងស្នើសុំមន្ត្រីសវនាការ ឱ្យបញ្ជាថា កាលវេលាកំនត់ នៃសវនាការតាមផ្លូវច្បាប់ដែលមានរយៈពេល ៤៥ថ្ងៃ អាចចាប់ផ្តើម ។

## 3. ការកែតម្រូវចំពោះរយៈពេលរកដំណោះស្រាយដែលមានពេល ៣០ថ្ងៃ

ប្រសិនបើ អ្នក និង ភ្នាក់ងារអប់រំក្នុងតំបន់ យល់ព្រមជាលាយល័ក្ខអក្សរ ដើម្បីបោះបង់ការប្រជុំរកដំណោះស្រាយ ដូចច្នេះកាលវេលាកំនត់៤៥ថ្ងៃ សំរាប់សវនាការតាមផ្លូវច្បាប់ ត្រូវចាប់ផ្តើមនៅថ្ងៃបន្ទាប់ ។

បន្ទាប់ពីចាប់ផ្តើម ការសំរុះសំរួល ឬ ការប្រជុំរកដំណោះស្រាយ និងមុនពេលបញ្ចប់កាលវេលាកំនត់នៃដំនើរការរកដំណោះស្រាយដែលមានរយៈពេល ៣០ថ្ងៃ ប្រសិនបើអ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់ យល់ព្រមជាលាយល័ក្ខអក្សរថា គ្មានកិច្ចព្រមព្រៀងណាដែលអាចធ្វើទៅរួចទេនោះ ពេលនោះកាលវេលាកំនត់សំរាប់សវនាការតាមផ្លូវច្បាប់ដែលមានរយៈពេល ៤៥ថ្ងៃ ត្រូវចាប់ផ្តើមនៅថ្ងៃបន្ទាប់ ។

ប្រសិនបើអ្នក ឬ ភ្នាក់ងារអប់រំក្នុងតំបន់ យល់ព្រមប្រើប្រាស់ដំនើរការសម្រុះសម្រួល នៅពេលបញ្ចប់នៃរយៈពេលរកដំណោះស្រាយ ដែលមានពេល ៤៥ថ្ងៃនោះ ភាគីទាំងពីរអាចយល់ព្រមព្រៀងគ្នាជាលាយល័ក្ខអក្សរ ដើម្បីបន្តការសម្រុះសម្រួល រហូតដល់កិច្ចព្រមព្រៀងមួយត្រូវបានសំរេច ។ ទោះជាយ៉ាងណា ប្រសិនបើអ្នក ឬភ្នាក់ងារអប់រំក្នុងតំបន់ ដកប្រព័ន្ធខ្លួនពីដំនើរការសម្រុះសម្រួលនេះ ពេលនោះកាលវេលាកំនត់សំរាប់សវនាការដែលមានរយៈពេល ៤៥ថ្ងៃ ត្រូវចាប់ផ្តើមនៅថ្ងៃបន្ទាប់ ។

## 4. កិច្ចព្រមព្រៀងលើដំណោះស្រាយជាលាយល័ក្ខអក្សរ

ប្រសិនបើ ដំណោះស្រាយមួយចំពោះបញ្ហាជំលោះ ត្រូវបានសំរេចនៅក្នុងការប្រជុំរកដំណោះស្រាយ  អ្នក និងភ្នាក់ងារអប់រំក្នុងតំបន់ ត្រូវតែព្រមព្រៀងលើកិច្ចព្រមព្រៀងចចងភ្ជាប់ស្របច្បាប់មួយដែល:

a. ត្រូវបានចុះហត្ថលេខាដោយ អ្នក និង អ្នកតំណាងរបស់ភ្នាក់ងារអប់រំក្នុងតំបន់ ដែលមានសិទ្ធិតំណាងឱ្យ ភ្នាក់ងារអប់រំក្នុងតំបន់ និង

b. ក្នុងអំឡុងពេលសំរាប់ពិនិត្យឡើងវិញលើកិច្ចព្រមព្រៀង  ប្រសិនបើ អ្នក និងភ្នាក់ងារអប់រំក្នុងតំបន់បានសំរេចធ្វើកិច្ចព្រមព្រៀង ដែលជាលទ្ធផលនៃការប្រជុំរកដំណោះស្រាយ ភាគីទាំងពីរ ( អ្នក និង ភ្នាក់ងារអប់រំក្នុងតំបន់) អាចទុកកិច្ចព្រមព្រៀងនោះជាមោឃៈ ក្នុងរយៈពេល ៣ ថ្ងៃធ្វើការចាប់ពីពេលដែលភាគីទាំងពីរចុះហត្ថលេខាលើកិច្ចព្រមព្រៀង.

# V. សវនាការអំពីពាក្យបណ្តឹងតាមផ្លូវច្បាប់

## A. <u>សវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង (34 CFR §300.511)</u>

### 1. ជាទូទៅ

នៅពេលណាដែលពាក្យបណ្តឹងតាមផ្លូវច្បាប់ត្រូវបានដាក់ អ្នក ឬ LEA ដែលទាក់ទងនឹងបញ្ហាជំម្លោះ ត្រូវតែមានឱកាសសំរាប់ចូលរួមក្នុង សវនាការមិនលំអៀង ដូចដែលបានពិពណ៌នានៅក្នុងផ្នែក ***ពាក្យបណ្តឹងតាមផ្លូវច្បាប់*** និង ***ដំណើរការដោះស្រាយ***។ នៅក្នុងរដ្ឋភេនសិលវេនា ប្រព័ន្ធដោះស្រាយតាមផ្លូវច្បាប់គឺ ត្រូវបាន ធ្វើឡើងដោយការិយាល័យដោះស្រាយជម្លោះ (ODR) ។ (រាយឈ្មោះនៅទំព័រ ***ប្រភពជំនួយ***)

### 2. មន្ត្រីសវនាការមិនលំអៀង

<u>**នៅកំរិតអប្បបរមា មន្ត្រីសវនាការម្នាក់:**</u>

a. ត្រូវតែមិនមែនជាបុគ្គលិករបស់ភ្នាក់ងារអប់រំរដ្ឋ ឬ LEA ដែលជាប់ទាក់ទងនៅក្នុងការអប់រំ ឬការថែរក្សាក្មេង ។ ក៏ប៉ុន្តែបុគ្គលិកនោះ មិនមែនជា បុគ្គលិកនៃភ្នាក់ងារទាំងស្រុងនោះទេ ព្រោះគាត់ត្រូវបានផ្តល់ប្រាក់ឱ្យដោយភ្នាក់ងារដើម្បីបំរើការជាមន្ត្រីសវនាការ

b. ត្រូវតែមិនមានផលប្រយោជន៍ផ្នែកជំទាញ ឬផ្ទាល់ខ្លួនដែលប្រឆាំងជាមួយនិងកម្មវត្ថុរបស់មន្ត្រីសវនាការនៅក្នុងសវនាការ

c. ត្រូវតែមានចំនេះដឹង និងយល់ពីខ ទាំងឡាយដែលមានចែងក្នុង IDEA និងបទបញ្ជារបស់រដ្ឋនិងសហព័ន្ធដែលទាក់ទងនិង IDEA នឹងការបកស្រាយ តាមផ្លូវច្បាប់នៃ IDEA ដោយតុលាការរដ្ឋ និងសហព័ន្ធ <u>**និង**</u>

d. ត្រូវតែមានចំនេះដឹង និងសមត្ថភាពដើម្បីរៀបចំដំណើរការសវនាការ ហើយនិងធ្វើការសំរេចចិត្ត និងសរសេរសេចក្តីសំរេចទានាស្របនឹង ស្តង់ដារការអនុវត្តន៏តាមផ្លូវច្បាប់សមរម្យ ។

SEA និមួយៗត្រូវតែទុកបញ្ជីឈ្មោះបុគ្គលិកទាំងឡាយដែលបំរើការជាមន្ត្រីសវនាការ រួមទាំងសេចក្តីថ្លែងការណ៏នៃសមត្ថភាពរបស់មន្ត្រីសវនាការម្នាក់ៗ ។

### 3. ប្រធានបទនៃបញ្ហានៃសវនាការតាមផ្លូវច្បាប់

ភាគី(អ្នក ឬ LEA) ដែលស្នើសុំឱ្យមានសវនាការតាមផ្លូវច្បាប់ មិនអាចនឹងលើកឡើងនូវបញ្ហានានានៅក្នុងសវនាការ ដែលមិនបានបង្ហាញនៅក្នុងពាក្យប្តឹង តាមផ្លូវច្បាប់នេះឡើយ លុះត្រាតែភាគីម្ខាងទៀតយល់ព្រម ។

### 4. កាលវេលាកំណត់សំរាប់ស្នើសុំសវនាការ

a. **ពេលវេលាមានកំនត់**

<u>**អ្នក ឬ LEAត្រូវតែស្នើសុំសវនាការមិនលំអៀងមួយស្តីពីពាក្យប្តឹងតាមផ្លូវច្បាប់ នៅក្នុងរយៈពេលពីរឆ្នាំនៃកាលបរិច្ឆេទដែលអ្នក ឬ LEA បានដឹង ឬ គួរតែបានដឹងពីបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យប្តឹង ។ ពាក្យបណ្តឹងតាមផ្លូវច្បាប់ ត្រូវតែអះអាងពីបទល្មើសដែលបានកើតឡើង មិនយូរ ជាងពីរឆ្នាំមុនថ្ងៃដែលអ្នក ឬ LEA បានដឹង ហើយគួរបានដឹងពីវិធានការដែលអះអាងនោះដែលបង្កើតជាមូលដ្ឋាននៃពាក្យប្តឹងតាមផ្លូវច្បាប់ ។**</u>

**ការលើកលែងចំពោះកាលវេលាកំនត់**

កាលវេលាកំនត់ខាងលើមិនអនុវត្តចំពោះអ្នក ប្រសិនបើអ្នកមិនអាចដាក់បណ្តឹងតាមផ្លូវច្បាប់ ដោយសារ:

1. LEA បានធ្វើឱ្យយល់ខុសយ៉ាងជាក់លាក់ ថាភ្នាក់ងារនេះបានដោះស្រាយបញ្ហានានា ដែលបានបញ្ជាក់នៅក្នុងពាក្យបណ្តឹង **ឬ**
2. LEA បានដកហូតពតិមានពីអ្នក ដែលតំរូវឱ្យផ្តល់ដល់អ្នក ក្រោមផ្នែក B របស់ IDEA ។

## B. <u>សិទ្ធិសវនាការ (34 CFR §300.512)</u>

### 1. ជាទូទៅ

***ភាគីណាដែលត្រូវចូលសវនាការតាមផ្លូវច្បាប់ (រួមទាំងសវនាការទាក់ទងនឹងនីតិវិធីផ្នែកវិន័យ) ឬការកោះហៅ ដូចដែលបានពិពណ៌នានៅខាងក្រោមអនុ-ចំនង ជើង*** *ការកោះហៅការសំរេច ការពិនិត្យឡើងវិញដោយមិនលំអៀង* **មានសិទ្ធិ:**

a. ទទួលការជួយ និងការផ្តល់ប្រឹក្សាដោយមេធាវី និង/ ឬបុគ្គលិកមានចំនេះដឹង ឬការបណ្តុះបណ្តាលពិសេសទាក់ទងនឹងបញ្ហារបស់កុមារពិការ ។

b. បង្ហាញភស្តុតាងនិងប្រឈមមុខ សួរសំនួរអំពីភស្តុតាង និងទាមទារឱ្យមានការចូលរួមពីសាក្សីផ្សេងៗ

c. ហាមឃាត់ការបង្ហាញភស្តុតាងណានៅក្នុងសវនាការ ដែលមិនទាន់បានផ្តល់ឱ្យភាគីម្ខាង ទៀតយ៉ាងហោចណាស់ប្រាំថ្ងៃធ្វើការ មុនថ្ងៃសវនាការ

d. ទទួលបានឯកសារជាលាយលក្សណ៍អក្សរ ឬ តាមជំរើសរបស់អ្នក ជាកំនត់ត្រាមួយពាក្យៗ ជាកំនត់ត្រាបែបអេឡិចត្រូនិចនៃសវនាការ **និង**
e. ទទួលបានការរកឃើញការពិត និងសេចក្ដីសំរេចជាលាយលក្សណ៍អក្សរ ឬតាមជំរើសរបស់អ្នក ជាលក្ខណៈអេឡិចត្រូនិច ។

2. **ពតិមានបង្ហាញបន្ថែម**

**យ៉ាងហោចណាស់៥ថ្ងៃធ្វើការ មុនថ្ងៃសវនាការ អ្នក និង LEA ត្រូវតែបង្ហាញរាល់ការវាយតំលៃដែលបានបំពេញទាំងអស់ ទៅភាគីទាំងអស់ផ្សេងទៀត ត្រឹមកាលបរិច្ឆេទនោះ និងបង្ហាញអនុសាសន៍ដែលយោងតាមការវាយតំលៃទាំងអស់នោះ ដែលអ្នក ឬ LEA ចង់ប្រើនៅក្នុងសវនាការ ។**

មន្ត្រីសវនាការម្នាក់អាចហាមឃាត់ភាគីណាមួយដែលខកខានមិនបានធ្វើតាមលក្ខខណ្ឌតំរូវនេះ ពីការបង្ហាញការវាយតំលៃដែលទាក់ទង ឬអនុសាសន៍នៅក្នុងសវនាការ ដោយមិនមានការយល់ព្រមពីភាគីម្ខាងទៀតឡើយ ។

3. **សិទ្ធិរបស់ឪពុកម្ដាយនៅក្នុងសវនាការ**

អ្នកត្រូវតែបានទទួលសិទ្ធិ:

a. ក្នុងការឱ្យកុមារដែលជាប្រធានបទនៃសវនាការ បង្ហាញមុខ
b. បើកចំហរសវនាការទៅសាធារណៈជន **និង**
c. ទទួលបានកំនត់ត្រានៃសវនាការ ការរកឃើញការពិត និងសេចក្ដីសំរេចផ្សេងៗ ដោយមិនបង់ប្រាក់ ។

## C. <u>សេចក្ដីសំរេចរបស់សវនាការ (34 CFR §300.513)</u>

1. ***សេចក្ដីសំរេចរបស់មន្ត្រីសវនាការ***

a. សេចក្ដីសំរេចចិត្តរបស់មន្ត្រីសវនាការ ចំពោះថាតើកូនរបស់អ្នកបានទទួល FAPE ត្រូវតែយោងទៅលើហេតុផលប្រកបដោយនិរន្តរភាព ។
b. នៅក្នុងបញ្ហានានាដែលអះអាងពីការល្មើសនីតិ មន្ត្រីសវនាការអាចនឹងរកឃើញថាកូនរបស់អ្នកមិនបានទទួល FAPE តែក្នុងករណីបើភាពខ្វះចន្លោះនៃនីតិវិធី:
    1) បានជ្រៀតជ្រែកជាមួយសិទ្ធិរបស់កូនអ្នកក្នុងការទទួលបាន FAPE
    2) បានជ្រៀតជ្រែងយ៉ាងសំខាន់ជាមួយនឹងឱកាសរបស់អ្នកក្នុងការចូលរួមនៅក្នុងដំណើរការសំរេចចិត្ត ទាក់ទងនឹងការផ្ដល់ FAPE ទៅឱ្យកូនរបស់អ្នក **ឬ**
    3) បានបង្កឱ្យមានការខាតបង់ផលប្រយោជន៍នៃការអប់រំ ។
c. ការបកស្រាយប្រយោគ

គ្មាន ខ ណាមួយដែលបានពិពណ៌នាខាងលើ អាចនឹងបកស្រាយដើម្បីរារាំងមិនឱ្យមន្ត្រីសវនាការ បញ្ជាឱ្យ LEA ណាមួយ គោរពតាមលក្ខខណ្ឌតម្រូវនៅក្នុងផ្នែកនៃ នីតិវិធីទទួលបានការការពារ នៃបទបញ្ញត្តិរបស់សហព័ន្ធនៅក្រោមផ្នែក B នៃ IDEA (34 CFR §§300.500 ដល់ 300.536) ។ គ្មាន ខ ណាមួយ នៅក្រោមចំនងជើង: ***ការដាក់ពាក្យបណ្ដឹងតាមផ្លូវច្បាប់ បណ្ដឹងតាមផ្លូវច្បាប់ ទម្រង់ឯកសារគំរូ ដំណើរការដោះស្រាយសវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង សិទ្ធិសវនាការ និង សេចក្ដីសំរេចរបស់សវនាការ*** (34 CFR §§300.507 ដល់ 300.513) អាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់អ្នកក្នុងការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ចំពោះសេចក្ដីសំរេចរបស់សវនការតាមផ្លូវច្បាប់ ទៅតុលាការមួយដែលមានសមត្ថកិច្ច ។

2. ***សំណើដោយឡែកសំរាប់សវនាការតាមផ្លូវច្បាប់***

គ្មានអ្វីនៅក្នុងផ្នែកនៃនីតិវិធីទទួលបានការការពារនៃបទបញ្ញត្តិរបស់សហព័ន្ធ នៅក្រោមផ្នែក B នៃ IDEA (34 CFR §§300.500 ដល់ 300.536) អាចត្រូវបានបកស្រាយដើម្បីរារាំងអ្នកមិនឱ្យដាក់ពាក្យបណ្ដឹងតាមផ្លូវច្បាប់ដោយឡែកមួយទៀត ចំពោះបញ្ហាណាមួយ ដែលដាច់ដោយឡែកពី ពាក្យបណ្ដឹងតាមផ្លូវច្បាប់ដែលបានដាក់រួចហើយនោះ ។

3. ***ការរកឃើញនិងសេចក្ដីសំរេចដែលផ្ដល់ឱ្យក្រុមអ្នកផ្ដល់ប្រឹក្សានិងមហាជនទូទៅ***

បន្ទាប់ពីបានលុបចោលនូវពតិមានដែលអាចកំនត់អត្តសញ្ញាណផ្ទាល់ខ្លួន SEA ត្រូវតែ:

a. ផ្ដល់ការរកឃើញនិងសេចក្ដីសំរេចទាំងឡាយនៅក្នុងសវនាការតាមផ្លូវច្បាប់ ឬឧទ្ធរណ៍ ទៅឱ្យក្រុមប្រឹក្សាផ្នែកអប់រំពិសេសរបស់រដ្ឋ (State Special Education Advisor Panel - SEAP) **និង**
b. ផ្ដល់លក្ខណៈអាចរកបាន ចំពោះការរកឃើញនិងសេចក្ដីសំរេចទាំងនោះ សំរាប់សាធារណៈជនទូទៅ

## D. <u>ភាពជាចុងក្រោយនៃសេចក្តីសំរេច ឧទ្ធរណ៍ ការពិនិត្យឡើងវិញដោយមិនលំអៀង (34 CFR §300.514)</u>

***ភាពជាចុងក្រោយនៃសេចក្តីសំរេចរបស់សវនាការ***

សេចក្តីសំរេចដែលបានធ្វើឡើងនៅក្នុងសវនាការតាមផ្លូវច្បាប់ (រួមទាំងសវនាការទាក់ទងនឹងនីតិវិធីផ្នែកវិន័យ) គឺជាការសំរេចចុងក្រោយ លើកលែងតែភាគីណាមួយដែលជាប់ពាក់ព័ន្ធនៅក្នុងសវនាការ (អ្នក ឬ LEA) អាចនឹងប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសំរេចនេះ ទៅតុលាការមួយដែលមានសមត្ថកិច្ច ។

## E. <u>កាលវេលាកំនត់និងភាពងាយស្រួលរបស់សវនាការ (34 CFR §300.515)</u>

### 1. កាលវេលាកំណត់

SEA ត្រូវតែធានាថា មិនយូរជាងរយៈពេល៤៥ថ្ងៃ បន្ទាប់ពីការហួសកាលបរិច្ឆេទនៃរយៈពេល ៣០ថ្ងៃសំរាប់ការប្រជុំរកដំណោះស្រាយ **<u>ឬ</u>** ដូចដែលបានពិពណ៌នានៅក្រោមអនុ-ចំនងជើង ***ការកែតំរូវចំពោះរយៈពេលរកដោះស្រាយដែលមានពេល៣០ថ្ងៃ***

a. សេចក្តីសំរេចចុងក្រោយមួយ ត្រូវបានធ្វើឡើងនៅក្នុងសវនាការ **<u>និង</u>**

b. ច្បាប់ចំលងនៃការសំរេច ត្រូវបានផ្ញើទៅអ្នក និង LEA ។

### 2. <u>*ការពន្យាពេល*</u>

មន្ត្រីសវនាការ ឬមន្ត្រីពិនិត្យឡើងវិញ អាចផ្តល់ការពន្យាលពេលជាក់លាក់ណាមួយលើសរយៈពេលដែលបានពិពណ៌នាខាងលើ (រយៈពេល៤៥ថ្ងៃសំរាប់ការសំរេចរបស់សវនាការ និង រយៈពេល៣០ថ្ងៃសំរាប់ការពិនិត្យឡើងវិញនៃសេចក្តីសំរេច) ប្រសិនបើអ្នក ឬ LEA ធ្វើការស្នើសុំសំរាប់ការពន្យាកាលវេលាកំណត់ជាក់លាក់ណាមួយ ។ រាល់សវនាការនីមួយៗដែលរួមមានការជជែកប្រកែកគ្នាដោយផ្ទាល់មាត់ ត្រូវតែបានធ្វើឡើងនៅពេលនិងកន្លែងមួយ ដែលមានភាពងាយស្រួលសំរាប់អ្នកឬកូនរបស់អ្នក ។

## F. <u>បណ្តឹងរដ្ឋប្បវេណី រួមទាំងរយៈពេលដែលត្រូវដាក់ពាក្យប្តឹង (34 CFR §300.516)</u>

### 1. ជាទូទៅ

ភាគីណាមួយ (អ្នក ឬ LEA) ដែលមិនយល់ស្របជាមួយនិងការរកឃើញ និងសេចក្តីសំរេច នៅក្នុងការសំរេចរបស់ SEA មានសិទ្ធិលើកបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបញ្ហានោះដែលជាប្រធានបទនៃសវនាការតាមផ្លូវច្បាប់ (រួមទាំងសវនាការទាក់ទងនឹងនីតិវិធីខាងវិន័យ) ។ បណ្តឹងនេះអាចត្រូវបានដាក់ទៅតុលាការសង្កាត់ (District Court) នៃសហរដ្ឋអាមេរិក ដោយមិនទាក់ទងនឹងចំនួនក្នុងជំលោះ ឬទៅក្នុងតុលាការរដ្ឋដែលមានសមត្ថកិច្ច (តុលាការរដ្ឋដែលមានសិទ្ធិអំណាចស្តាប់ រឿងក្តីប្រភេទនេះ) ។ នៅក្នុងរដ្ឋភេនសិលវេនា តុលាការដែលមានសមត្ថកិច្ចគឺជាតុលាការប្រជាពលរដ្ឋ (Commonwealth Court) ។

### 2. ការកំនត់ពេល

ភាគី (អ្នក ឬ LEA) ដែលបានយកសំនុំរឿងទៅកាន់តុលាការសង្កាត់នៃសហរដ្ឋអាមេរិច ត្រូវមានរយៈពេល៩០ថ្ងៃបន្ទាប់ពីថ្ងៃនៃការសំរេចចិត្តរបស់ SEA ដើម្បីដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ។ ភាគីដែលយកសំនុំរឿងទៅកាន់តុលាការប្រជាជន ត្រូវមានរយៈពេល៣០ថ្ងៃបន្ទាប់ពីថ្ងៃនៃការសំរេចចិត្តរបស់ SEA ដើម្បីដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ។

### 3. នីតិវិធីបន្ថែម

**<u>នៅក្នុងបណ្តឹងរដ្ឋប្បវេណី តុលាការ:</u>**

1. ទទួលកំនត់ត្រានៃចំណាត់ការផ្នែករដ្ឋបាល
2. ស្តាប់ភស្តុតាងបន្ថែមតាមសំនូមពររបស់អ្នក ឬ តាមសំនូមពររបស់ LEA **<u>និង</u>**
3. យោងតាមការសំរេចរបស់ខ្លួន តាមភស្តុតាងជាច្រើនប្រភេទនិងផ្តល់ការឧបត្ថម្ភដែលតុលារការកំណត់ថាសមរម្យ ។

### 4. ក្បួនច្បាប់នៃការបកស្រាយ

គ្មានអ្វីនៅក្នុងផ្នែក B របស់ IDEA ហាមឃាត់ឬ ការកំណត់សិទ្ធិ នីតិវិធី និង វិធីសាស្ត្រដោះស្រាយ ដែលមាននៅក្នុងរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក ច្បាប់ស្តីពីសិទ្ធិជនពិការជាជនជាតិរដ្ឋអាមេរិក ឆ្នាំ១៩៩០ ចំណងជើង V នៃច្បាប់ស្តារនីតិសម្បទា នៅឆ្នាំ១៩៧៣ (ផ្នែក ៥០៤) ឬច្បាប់សហព័ន្ធផ្សេងទៀតដែលការពារសិទ្ធិកុមារមានពិការភាព លើកលែងតែមុននឹងការដាក់ពាក្យ**បណ្តឹងរដ្ឋប្បវេណី** នៅក្រោមច្បាប់ទាំងអស់នេះ ក្នុងការស្វែងរកការឧបត្ថម្ភដែលអាចរកបាននៅក្រោមផ្នែក B នៃ IDEA នីតិវិធីតាមផ្លូវច្បាប់ដែលបានពិពណ៌នាខាងលើ ត្រូវតែបានប្រើទាំងស្រុងទៅតាមកំរិតដូចគ្នា ដូចដែលនឹងត្រូវតម្រូវឱ្យធ្វើ

ប្រសិនបើភាគីនោះបានដាក់ពាក្យប្ដឹង នៅក្រោមផ្នែក B នៃ IDEA ។ នេះមានន័យថាអ្នកអាចមានវិធីសាស្ត្រដោះស្រាយ ដែលផ្ដល់ឱ្យ ក្រោមច្បាប់ផ្សេងៗទៀត ដែលជាន់គ្នាជាមួយនិងច្បាប់ទាំងឡាយដែលមានស្រាប់នៅ ក្រោម IDEA ក៏ប៉ុន្តែជាទូទៅ ដើម្បីទទួលបានការឧបត្ថម្ភនៅក្រោមច្បាប់ផ្សេងៗទាំងនោះ ជាដំបូង អ្នកត្រូវតែប្រើឱ្យអស់វិធីសាស្ត្រដោះស្រាយតាមរបៀបរដ្ឋបាលដែលមាន នៅក្រោម IDEA (ឧទាហរណ៍ បណ្ដឹងតតាមផ្លូវច្បាប់ ការប្រជុំរកដំណោះស្រាយ និង សវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង) មុននឹងឡើងទៅតុលាការ លុះត្រាតែមានការលើកលែងផ្នែកវិនិច្ឆ័យជាក់លាក់ខ្លះៗ ដែលធ្វើឱ្យការប្រើគ្រប់វិធីសាស្ត្រ ដោះស្រាយតាមរបៀបរដ្ឋបាលទាំងនោះអស់ប្រយោជន៍ ។

## G. <u>ថ្លៃឈ្នួលមេធាវី (34 CFR §300.517)</u>

### 1. ជាទូទៅ

នៅក្នុងបណ្ដឹង ឬចំណាត់ការតាមច្បាប់ណាក៏ដោយដែលបានលើកឡើងនៅក្រោមផ្នែក B នៃ IDEA តុលាការ (នៅក្នុងការសំរេចរបស់ខ្លួន) អាចផ្ដល់ថ្លៃឈ្នួល មេធាវីសមរម្យ ជាចំនែកនៃតំលៃចំណាយ:

a. ឱ្យទៅអ្នកប្រសិនបើអ្នកត្រូវបានគេគិតថាជាផ្នែកមានប្រៀបលើ ។

b. ឱ្យទៅភ្នាក់ងារអប់រំរដ្ឋ ឬ LEA ដែលមានប្រៀប ដែលនឹងត្រូវបានបង់ឱ្យដោយមេធាវីរបស់អ្នក ប្រសិនបើមេធាវីនោះ: (a) បានដាក់ពាក្យប្ដឹងតវ៉ា ឬរឿងក្ដីតុលាការ ដែលតុលាការរកឃើញថាមិនសំខាន់ មិនសមហេតុផល ឬគ្មានមូលដ្ឋានច្បាស់លាស់ **ឬ** (b) នៅតែបន្តប្ដឹង បន្ទាប់ពីការប្ដឹងបាន ប្រែជាយ៉ាងច្បាស់ថាមិនសំខាន់ មិនសមហេតុផល ឬគ្មានមូលដ្ឋានច្បាស់លាស់ **ឬ**

c. សំរាប់ភ្នាក់ងារអប់រំរដ្ឋ ឬ LEA ដែលមានប្រៀបលើ ដែលនឹងត្រូវបានបង់ប្រាក់ឱ្យដោយអ្នក ឬមេធាវីរបស់អ្នក ប្រសិនបើការស្នើសុំរបស់អ្នកសំរាប់ សវនាការតាមផ្លូវច្បាប់ ឬរឿងក្ដីតុលាការក្រោយមកទៀត ត្រូវបានបង្ហាញសំរាប់គោលបំណងមិនត្រឹមត្រូវណាមួយ ដូចជាធ្វើការរំខាន បង្កឱ្យមាន ការពន្យាពេលមិនចាំបាច់ ឬ បង្កើនថ្លៃចំណាយដោយមិនចាំបាច់នៃបណ្ដឹង ឬចំណាត់ការតាមផ្លូវច្បាប់ ។

### 2. ថ្លៃឈ្នួលសមហេតុផល

តុលាការនឹងផ្ដល់ថ្លៃឈ្នួលមេធាវីសមហេតុផល ដែលសមស្របនឹងកត្តាដូចខាងក្រោម:

a. ថ្លៃឈ្នួលត្រូវតែយោងតាមតំលៃធម្មតានៅក្នុងសហគមន៍ដែលបណ្ដឹង ឬសវនាការនោះកើតឡើងសំរាប់ប្រភេទ និង គុណភាពសេវាដែលបាន បញ្ចប់ ។ គ្មានប្រាក់បន្ថែម ឬមេគុណអ្វីអាចត្រូវបានប្រើនៅក្នុងការគណនាថ្លៃឈ្នួលដែលបានផ្ដល់ឱ្យនោះឡើយ ។

b. ថ្លៃឈ្នួលអាចនឹងមិនត្រូវបានផ្ដល់ និង តំលៃចំណាយពាក់ព័ន្ធអាចនឹងមិនបានសងមកវិញ ចំពោះបណ្ដឹង ឬនីតិប្ដឹងណាមួយ នៅក្រោមផ្នែក B នៃ IDEA សំរាប់សេវាកម្មនានាដែលបានធ្វើឡើងបន្ទាប់ពីការផ្ដល់កិច្ចព្រមព្រៀងជាលាយលក្សណ៍អក្សរ ឱ្យទៅអ្នក ប្រសិនបើ:

   1) ការផ្ដល់ឱ្យនោះគឺត្រូវបានធ្វើឡើងនៅក្នុងពេលដែលបានបង្គាប់ដោយវិធាន ៦៨ នៃច្បាប់សហព័ន្ធស្ដីពីនីតិវិធីរដ្ឋប្បវេណី ឬ នៅក្នុងករណី នៃសវនាការតាមផ្លូវច្បាប់ ឬការពិនិត្យឡើងវិញនៅថ្នាក់រដ្ឋ នៅពេលណាមួយច្រើនជាង ១០ថ្ងៃ មុនពេលនីតិប្ដឹងចាប់ផ្ដើម

   2) ការផ្ដល់ឱ្យនោះមិនត្រូវបានទទួលយកនៅក្នុងរយ:ពេល១០ថ្ងៃ **<u>និង</u>**

   3) តុលាការ ឬមន្ត្រីរដ្ឋបាលសវនាការរកឃើញថា ជាចុងក្រោយការឧបត្ថម្ភដែលត្រូវបានទទួលយកដោយអ្នក គឺមិនសមស្របសំរាប់អ្នក ជាងការផ្ដល់កិច្ចព្រមព្រៀងនោះឡើយ ។

   4) ថ្វីបើមានការហាមឃាត់ទាំងនេះ ការផ្ដល់ថ្លៃឈ្នួលសំរាប់មេធាវី និងតំលៃចំណាយពាក់ព័ន្ធអាចត្រូវបានធ្វើឡើងចំពោះអ្នក ប្រសិនបើ អ្នកមានប្រៀបលើ ហើយអ្នកត្រូវបានផ្ដល់យុត្តិធមិជាទូទៅ ក្នុងការបដិសេធការផ្ដល់ឱ្យជាកិច្ចព្រមព្រៀងនោះ ។

c. ថ្លៃឈ្នួលអាច<u>មិន</u>ត្រូវបានផ្ដល់ឱ្យ ទាក់ទងនឹងការប្រជុំរបស់សមាជិក IEP លុះត្រាតែការប្រជុំត្រូវបានធ្វើឡើងជាលទ្ធផលនៃការនីតិវិធីប្ដឹងតាម របៀបរដ្ឋបាល ឬ វិធានការរបស់តុលាការ ។ កិច្ចប្រជុំរកដំណោះស្រាយ ដូចដែលបានពិពណ៌នាក្រោមប្រធានបទ ***កិច្ចប្រជុំរកដំណោះស្រាយ*** គឺមិនត្រូវបានគិតថាជាការប្រជុំមួយ ដែលត្រូវបានរៀបចំឡើង ដែលជាលទ្ធផលនៃសវនាការរដ្ឋបាល ឬ វិធានការរបស់តុលាការ ហើយក៏មិនត្រូវ បានគិតថាជាសវនាការរដ្ឋបាល ឬវិធានការរបស់តុលាការ សំរាប់គោលបំណងនៃការបែងចែកថ្លៃឈ្នួលរបស់មេធាវីទាំងនេះ ។

d. ថ្លៃឈ្នួលអាចត្រូវបានផ្ដល់ឱ្យសំរាប់កិច្ចសម្រុះសម្រួលដូចដែលបានពិពណ៌នានៅក្រោមចំនងជើង ការសម្រុះសម្រួល ។

### 3. ការបន្ថយថ្លៃឈ្នួល

តុលាការកាត់បន្ថយ តាមការសមរម្យ នូវចំនួនថ្លៃឈ្នួលរបស់មេធាវី ដែលត្រូវបានផ្ដល់នៅក្រោមផ្នែក B នៃ IDEA ប្រសិនបើតុលាការរកឃើញថា:

a. អ្នក ឬមេធាវីរបស់អ្នក នៅក្នុងអំឡុងពេលដំណើរការការប្តឹង ឬនីតិវិធីប្តឹង បានពន្យាពេលដោយមិនសមហេតុផលពីដំណោះស្រាយជាចុងក្រោយចំពោះជម្លោះនោះ
b. ម្យ៉ាងវិញទៀតតំលៃថ្លៃឈ្នួលរបស់មេធាវីត្រូវបានផ្តល់សិទ្ធិដើម្បីទទួលរង្វាន់ដោយមិនសមហេតុផល ហួសតំលៃធម្មតាប្រចាំម៉ោងនៅក្នុងសហមគមន៍សំរាប់សេវាមេធាវីស្រដៀងគ្នាយ៉ាង ជំនាញស្រដៀងគ្នាសមហេតុផល កេរ្តិ៍ឈ្មោះ និងបទពិសោធន៍
c. ពេលវេលាដែលបានចំណាយនិងសកម្មភាពផ្លូវច្បាប់ដែលបានផ្តត់ផ្គង់គឺហួសពីការគិត ពីប្រភេទនៃសកម្មភាព ឬ នីតិវិធីប្តឹង **ឬ**
d. មេធាវីតំនាងឱ្យអ្នកមិនបានផ្តល់ពតិមានសមរម្យទៅ LEA នៅក្នុងសេចក្តីប្រកាសពីនីតិវិធីស្នើសុំដូចដែលបានពិពណ៌នានៅក្រោមចំនងជើង ***ពាក្យប្តឹងតាមផ្លូវច្បាប់*** ។

ក៏ប៉ុន្តែតុលាការអាចមិនកាត់បន្ថយថ្លៃឈ្នួល ប្រសិនបើតុលាការរកឃើញថា រដ្ឋ ឬ LEA បានពន្យាការសំរេចចុងក្រោយដោយមិនសមហេតុផលពីសកម្មភាព ឬ ការប្តឹង ឬ វាការបំពាន់នៅក្រោមការសំរេចពីនីតិវិធីការពារនៃ ផ្នែក B នៃ IDEA ។

## H. <u>ទម្រង់ឯកសារគំរូ(34 CFR §300.509)</u>

ខណៈពេលដែលភ្នាក់ងារអប់រំរដ្ឋ (SEA) បានបង្កើតទម្រង់ឯកសារគំរូដើម្បីជួយអ្នកដាក់ពាក្យប្តឹងតវ៉ាតាមផ្លូវច្បាប់ និង ពាក្យប្តឹងទៅរដ្ឋ ។ SEA ឬ LEA អាចមិនស្នើសុំឱ្យអ្នកប្រើទម្រង់ឯកសារទាំងនេះ ។ តាមពិត អ្នកអាចប្រើទម្រង់ឯកសារនេះ ឬ ទម្រង់ឯកសារផ្សេង ទៀតដែលសមរម្យ ឱ្យតែឯកសារនោះមានផ្ទុកពតិមានស្នើសុំសំរាប់ពាក្យបណ្តឹងដោះស្រាយតាមផ្លូវច្បាប់ ឬការប្តឹងទៅរដ្ឋ ។

## VI. **ការសម្រុះសម្រួល** (34 CFR §300.506)

### A. **ជាទូទៅ**

SEA ត្រូវតែបង្កើតការសម្រុះសម្រួលឱ្យមាន ដើម្បីអនុញ្ញាតឱ្យអ្នកនិង LEA ដោះស្រាយភាពមិនយល់ស្របគ្នានានាដែលជាប់ទាក់ទងនិងបញ្ហាណា នៅក្រោមផ្នែក B នៃ IDEA រួមទាំងបញ្ហានានាដែលបានកើតឡើងមុនពេលដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ ។ ដូច្នេះ ការសម្រុះសម្រួលគឺមានដើម្បីដោះស្រាយជម្លោះ នៅក្រោមផ្នែក B នៃ IDEA ទោះជាអ្នក ឬ LEA បានដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ ឬមិនបានដាក់ ដើម្បីស្នើសុំតាមសវនាការតាមផ្លូវច្បាប់ដូចដែលបាន ពិពណ៌នានៅក្រោមចំនងជើង ***ការដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់*** ។

### B. **តម្រូវការនៃនីតិវិធី**

**នីតិវិធីត្រូវតែធានាពីថាវិធីសម្រុះសម្រួល:**

1. គឺការស្មគ្រ័ចិត្តលើផ្នែករបស់អ្នក និងរបស់ LEA
2. គឺមិនប្រើសំរាប់បដិសេធ ឬពន្យាពេលសិទ្ធិរបស់អ្នកដើម្បីរកសវនាការតាមផ្លូវច្បាប់ ឬ ដើម្បីបដិសេធពីសិទ្ធិដទៃទៀតដែលអ្នកមាននៅក្រោមផ្នែក B នៃ IDEA **និង**
3. គឺត្រូវបានធ្វើឡើងដោយអ្នកសម្រុះសម្រួលជំនាញនិងមិនលំអៀងដែលត្រូវបានបង្រៀនពីវិធីសាស្រ្តសម្រុះសម្រួលដែលមានប្រសិទ្ធភាព ។
4. SEA ត្រូវតែរក្សាទុកបញ្ជីបុគ្គលិកដែលខ្លួន ជាអ្នកសម្រុះសម្រួលមានសមត្ថភាព និងមានចំនេះដឹងផ្នែកច្បាប់និងបទបញ្ញត្តិនានាទាក់ទងការសំរេចនៃការផ្តល់សេវាកម្មការអប់រំពិសេស និងសេវាពាក់ព័ន្ធ ។ SEA ត្រូវតែជ្រើសរើសអ្នកសម្រុះសម្រួលដោយផ្អែកលើមូលដ្ឋានមិនលំអៀង ដោយចៃដន្យ ឬការជ្រើសរើសផ្លាស់គ្នាផ្សេងទៀត ។
5. រដ្ឋមានតួនាទីលើថ្លៃឈ្នួលសំរាប់ការដោះស្រាយសម្រុះសម្រួល រួមទាំងថ្លៃឈ្នួលនៃការប្រជុំ ។
6. រាល់ម៉ោងក្នុងនីតិវិធីសម្រុះសម្រួលត្រូវតែបានរៀបចំឡើងទៅតាមរបៀបនៃពេលវេលា និងត្រូវបានធ្វើឡើងនៅកន្លែងមួយដែលមានភាពងាយស្រួលសំរាប់អ្នក និង LEA.
7. **ប្រសិនបើអ្នក និង LEA ដោះស្រាយជម្លោះតាមនីតិវិធីសម្រុះសម្រួល ភាគីទាំងសងខាងត្រូវតែចងភ្ជាប់គ្នាតាមរយៈកិច្ចព្រមព្រៀង ស្របតាមផ្លូវច្បាប់ ដែលបានសំរេចពីដំណោះស្រាយហើយ ដែល:**
    a. បញ្ជាក់ថារាល់ការពិភាក្សាទាំងអស់ដែលបានកើតឡើងនៅក្នុងអំឡុងពេលនីតិវិធីសម្រុះសម្រួល នឹងនៅតែជាអាថ៌កំបាំង និងមិនអាចត្រូវបានប្រើជាភស្តុតាងនៅ ក្នុងនីតិវិធីសវនាការ ក្រោយៗទៀត ឬ បណ្តឹងរដ្ឋប្បវេណី **និង**
    b. ត្រូវបានចុះហត្ថលេខាដោយអ្នក និង អ្នកតំណាងរបស់ LEA ដែលមានសិទ្ធិអំណាចក្នុងការតំណាងឱ្យ LEA ។
8. ការព្រមព្រៀងសម្រុះសម្រួលជាលាយលក្សណ៍អក្សរ និងបានចុះហត្ថលេខាមួយគឺអាចត្រូវអនុវត្តនៅក្នុងតុលាការរដ្ឋនៃសាលាក្តីដែលមានសមត្ថកិច្ច (តុលាការដែលមានអំណាចនៅក្រោមច្បាប់រដ្ឋដើម្បីមានសិទ្ធិស្តាប់រឿងក្តីប្រភេទនេះ) ឬ នៅក្នុងតុលាការសង្កាត់សហរដ្ឋអាមេរិក ។
9. ការពិភាក្សាដែលបានកើតឡើងក្នុងអំឡុងពេលនៃនីតិវិធីសម្រុះសម្រួលត្រូវតែរក្សាការសំងាត់ ។ ការពិភាក្សានោះមិនអាចត្រូវបានប្រើជាភស្តុតាងនៅក្នុងនីតិវិធីសវនាការ នៅពេលខាងមុខបានឡើយ ឬ ក្នុងបណ្តឹងរដ្ឋប្បវេណីនៃតុលាការសហព័ន្ធណា ឬ តុលាការរដ្ឋក្នុងការទទួលជំនួយរដ្ឋនៅក្រោមផ្នែក B នៃ IDEA ។

### C. **អ្នកសម្រុះសម្រួលមិនលំអៀង**

អ្នកសម្រុះសម្រួល:

1. អាចមិនមែនជាបុគ្គលិករបស់ SEA ឬ LEA ដែលត្រូវបានជាប់ទាក់ទងនៅក្នុងការអប់រំ ឬការថែទាំកូនរបស់អ្នក **ហើយ**
2. ត្រូវតែមិនមានផលប្រយោជន៍ផ្នែកជំនាញ ឬផ្ទាល់ខ្លួនដែលប្រឆាំងជាមួយនិងកម្មវត្ថុរបស់អ្នកសម្រុះសម្រួល ។ ម្យ៉ាងវិញទៀត បុគ្គលដែលមានសមត្ថភាពជាអ្នកសម្រុះសម្រួលគឺមិនងមែនជាបុគ្គលិករបស់ LEA ឬ SEA ទាំងស្រុងនោះទេព្រោះ គាត់ត្រូវបានបង់ប្រាក់ឱ្យដោយភ្នាក់ងារដើម្បីបំរើការជាអ្នកសម្រុះសម្រួល ។

## VII. ទីកន្លែងសិក្សារបស់កុមារអំឡុងពេលរងចាំការសម្រុះសម្រួល និង នីតិវិធីតាមផ្លូវច្បាប់ (34 CFR §300.518)

### A. <u>ជាទូទៅ</u>

**ទីកន្លែងសិក្សារបស់កុមារអំឡុងពេលរងចាំការសម្រុះសម្រួល និង នីតិវិធីតាមផ្លូវច្បាប់** (34 CFR §300.518)

លើកលែងដូចដែលបានផ្តល់ឱ្យខាងក្រោមចំណងជើង **នីតិវិធីនៅពេលអនុវត្តវិន័យចំពោះកុមារមានពិការភាព** នៅពេលដែលពាក្យបណ្តឹងតាមផ្លូវច្បាប់មួយត្រូវបានផ្ញើទៅកាន់ភាគីផ្សេងម្ខាងទៀត ក្នុងអំឡុងពេលដំណើរការវិធីដោះស្រាយ <u>អំឡុងពេលការសម្រុះសម្រួល</u> ហើយនៅ ពេលកំពុងរង់ចាំសេចក្តីសំរេចនៃសវនាការតាមផ្លូវច្បាប់ដែលមិនលំអៀង ឬ នីតិវិធីតុលាការ លុះត្រាតែ អ្នកនិងរដ្ឋ ឬ LEA យល់ស្របផ្សេងពីនេះ កូនរបស់អ្នកត្រូវតែស្ថិតនៅក្នុងកន្លែងអប់រំបច្ចុប្បន្នដដែល ។

ប្រសិនបើពាក្យប្តឹងតាមផ្លូវច្បាប់ មានជាប់ទាក់ទងនឹងការដាក់ពាក្យសុំចូលរៀនជាដំបូងនៅសាលារដ្ឋ កូនរបស់អ្នក ជាមួយការយល់ព្រមរបស់អ្នក ត្រូវតែដាក់ឱ្យរៀននៅក្នុងកម្មវិធីសាលារដ្ឋធម្មតា លុះត្រាតែការបញ្ចប់នៃនីតិវិធីទាំងអស់នោះ ។

ប្រសិនពាក្យបណ្តឹងតាមផ្លូវច្បាប់ មានជាប់ទាក់ទងនឹងការដាក់ពាក្យសុំសេវាកម្មជាដំបូង នៅក្រោមផ្នែក B នៃ IDEA សំរាប់កុមារម្នាក់ដែលកំពុងផ្លាស់ប្តូរពីនៅក្នុងផ្នែក C នៃ IDEA ទៅផ្នែក B នៃ IDEA ហើយជាកុមារនោះមិនមានសិទ្ធិសំរាប់សេវាក្នុងផ្នែក C ព្រោះក្មេងនៅបានឈានដល់អាយុបីឆ្នាំ LEAអាចស្នើសុំឱ្យផ្តល់សេវាផ្នែក C ដែលកុមារនេះបាននឹងកំពុងទទួលយក ។ កុមារត្រូវបានអនុញ្ញាតឱ្យរង់ចាំទទួលការសំរេច - ដែលជាការបន្តសេវាកម្ម ដែលបានកំនត់នៅក្នុង IFSP របស់ពួកគេ - នៅពេលដែលបញ្ហាកើតឡើង នៅពេលដែលពួកគេកំពុងផ្លាស់ប្តូរទៅក្នុងកម្មវិធីអន្តរាគមន៍មុនពេលចូលរៀនសាលា នៅអាយុបីឆ្នាំ (3) ហើយគ្រួសាររបស់ពួកគេស្នើសុំសវនាការស្របច្បាប់មួយដើម្បីដោះស្រាយបញ្ហា ។ ប្រសិនបើកុមារនេះត្រូវបានរកឃើញថាមានសិទ្ធិនៅក្រោមផ្នែក B នៃ IDEA ហើយអ្នកអនុញ្ញាតឱ្យកុមារនេះ ទទួលការអប់រំពិសេស និង សេវាពាក់ព័ន្ធជាគ្រាដំបូង បន្ទាប់មកទៀត រង់ចាំលទ្ធផលនៃនីតិវិធីតុលាការ LEA ត្រូវតែផ្តល់ការអប់រំពិសេស និងសេវាពាក់ព័ន្ធទាំងនោះ ដែលមិនមានជាបញ្ហា (អ្វីដែលអ្នក និង LEA យល់ស្របគ្នា ) ។

## VIII. តើមានអ្វីកើតឡើង ប្រសិនបើកូនរបស់ខ្ញុំត្រូវបានដកចេញពីសាលាដោយសារបញ្ហាវិន័យ?

### ផ្នែកនេះបង្ហាញពីនីតិវិធីសំរាប់ការដកចេញដោយបញ្ហាវិន័យចំពោះកុមារដែលមានពិការភាព។

មានវិធានច្បាប់ពិសេស១នៅក្នុងរដ្ឋ Pennsylvania សំរាប់ដកកុមារពិការដែលផ្តល់សេវាកម្មឱ្យដោយភ្នាក់ងារអប់រំក្នុងតំបន់ ដោយហេតុផលវិន័យ។ លើកលែងត្រូវបានបង្ហាញប្រាប់ផ្សេងពីនេះ បើមិនដូច្នេះទេកុមារដែលនៅក្នុងសាលាឈ្លួលត្រូវធ្វើតាមនីតិវិធីដូចគ្នានេះ :

### A. <u>**សិទ្ធិរបស់បុគ្គលិកសាលា** (34 CFR §300.530)</u>

1. **ការកំនត់តាមករណីនីមួយ១** (Case-by-case determination)

   បុគ្គលិកសាលាត្រូវតែពិចារណាទៅលើ កាលៈទេសៈដោយឡែក១គ្នា ផ្អែកលើមូលដ្ឋានពីករណីនីមួយ១ នៅពេលដែលធ្វើការកំណត់ថាតើការផ្លាស់ប្តូរទីកន្លែង (ដែលត្រូវបានធ្វើអនុលោមទៅតាមលក្ខខណ្ឌតំរូវឱ្យខាងក្រោម ដែលទាក់ទងទៅនឹងវិន័យ) មានលក្ខណៈសមស្របសំរាប់កុមារពិការម្នាក់ដែលបំពានក្រមសីលធមិជាសិស្សក្នុងសាលាដែរឬទេ។

2. **ជាទូទៅ** (General)

   ស្ថិតនៅក៏វិត ដែលពួកគេចាត់វិធានការដូចគ្នានេះចំពោះកុមារដែលមិនពិការ បុគ្គលិកសាលាអាចនឹង (សំរាប់រយៈពេលមិនលើសពី **១0ថ្ងៃសិក្សា ជាប់១គ្នា**) ធ្វើការផ្លាស់កុមារដែលពិការ (លើកលែងកុមារដែលមានការអភិវឌ្ឍន៏យឺតផ្នែកសតិបញ្ញា) ដែលប្រព្រឹត្តល្មើសនឹងក្រមសីលធមិជាសិស្ស ចេញពីកន្លែងសិក្សាបច្ចុប្បន្នរបស់គេ ទៅកន្លែងសិក្សាដែលជាជំរើសបណ្តោះអាសន្នមួយសមរម្យ ឬមានការរៀបចំកន្លែងផ្សេងទៀត ឬព្យួរការសិក្សា។ បុគ្គលិកសាលាក៏អាចនឹងដាក់ការផ្លាស់ចេញជាបន្ថែមចំពោះកុមារនោះ ដោយមិនលើសពី **10ថ្ងៃសិក្សា ជាប់១គ្នា** នៅក្នុងឆ្នាំសិក្សាតែមួយ ចំពោះការកើតមានឡើងដាច់ដោយឡែកផ្សេងទៀតនៃការប្រព្រឹត្តខុសឆ្គង ដ៏រាបណាការផ្លាស់ចេញទាំងនោះ មិនរួមមានការផ្លាស់ប្តូរទីកន្លែង (សូមមើលការ ***ការផ្លាស់ប្តូរទីកន្លែងដោយសារការផ្លាស់ចេញតាមវិន័យ*** សំរាប់និយមន័យនេះ ខាងក្រោម) ឬក៏ លើសពី ១៥ថ្ងៃសិក្សាដែលបូកបន្ត ក្នុងឆ្នាំសិក្សាមួយ។ នៅពេលដែលកុមារដែលពិការម្នាក់ ត្រូវបានផ្លាស់ចេញពីទីកន្លែងបច្ចុប្បន្នរបស់គេ ក្នុងរយៈពេលសរុប **១0ថ្ងៃសិក្សា** ក្នុងឆ្នាំសិក្សាដូចគ្នា ភ្នាក់ងារអប់រំក្នុងតំបន់ ត្រូវតែ (អំឡុងពេលថ្ងៃបន្ទាប់១នៃការផ្លាស់ចេញក្នុងឆ្នាំសិក្សានោះ) ផ្តល់សេវាកម្មនានា ក្នុងក៏វិតដែលតំរូវឱ្យមានដូចខាងក្រោម ស្ថិតក្រោមអនុ-ចំណងជើង ***សេវាកម្មនានា (Serivces)*** ។

3. **សិទ្ធិបន្ថែម** (Additional Authority)

   ប្រសិនបើអាកប្បកិរិយាដែលបានបំពានលើក្រមសីលធមិជាសិស្ស គឺមិនមែនជាសញ្ញាណ របស់កុមារមានពិការភាព (សូមមើល ***ការកំណត់ពីសញ្ញាណ (manifestation determination)*** ខាងក្រោម) ហើយនិង ការផ្លាស់ប្តូរតាមវិន័យចំពោះទីកន្លែង អាចនឹងលើសពី **១0ថ្ងៃសិក្សា ជាប់១គ្នា** នោះ បុគ្គលិកសាលាអាចប្រើប្រាស់នីតិវិធីវិន័យលើ កុមារដែលមានពិការភាពនោះ តាមរបៀបដូចគ្នា និង សំរាប់រយៈពេលដូចគ្នា ដូចដែលគេអាចនឹងធ្វើ ទៅលើកុមារដែលមិនពិការ លើកលែងតែថា សាលានោះត្រូវតែផ្តល់សេវាកម្មនានាទៅឱ្យកុមារនោះ ដូចដែលបានពិពណ៌នាខាងក្រោម នៅក្រោមចំណងជើង ***សេវាកម្មនានា***។ ក្រុម IEP របស់កុមារ កំណត់ពីកន្លែងអប់រំដែលជាជំរើសបណ្តោះអាសន្នសំរាប់សេវាកម្មទាំងនោះ។ ស្ថិតក្រោម ច្បាប់បញ្ញត្តិស្តីពីការអប់រំពិសេសរបស់ PA (22Pa. Code Sec. 14.143) ការដកចេញតាមវិន័យចំពោះសិស្សពិការ សំរាប់រយៈពេលច្រើនជាង ១៥ថ្ងៃសិក្សាដែលបូកបន្ត ក្នុងឆ្នាំសិក្សាមួយ នឹងត្រូវចាត់ទុកថាជាគន្លងក្នុងបំណងគិតថាជាការផ្លាស់ប្តូរកន្លែងអប់រំ (ដែលបានពន្យល់នៅក្រោម ការផ្លាស់ប្តូរទីកន្លែងដោយសារការផ្លាស់ចេញតាមវិន័យ (Change of Placement Because of Disciplinary Removals))។ ភ្នាក់ងារអប់រំក្នុងតំបន់ តំរូវឱ្យចេញ NOREP/ សេចក្តីប្រកាសជាលាយល័ក្ខអក្សរជាមុន ទៅឱ្យឪពុកម្តាយ មុនពេលមានការផ្លាស់ចេញណាមួយ ដែលរួមមានការផ្លាស់ប្តូរទីកន្លែង (ការផ្លាស់ចេញច្រើនជាង ១០ថ្ងៃជាប់១គ្នា ឬ ១៥ថ្ងៃបូកបន្ត)។

4. **សេវាកម្មនានា** (Services)

   សេវាកម្មនានាដែលត្រូវតែផ្តល់ដល់កុមារពិការដែលត្រូវបានគេផ្លាស់ពីកន្លែងបច្ចុប្បន្នរបស់គេ អាចនឹងត្រូវបានផ្តល់នៅកន្លែងអប់រំជាជំរើសបណ្តោះអាសន្នមួយ។ ភ្នាក់ងារអប់រំក្នុងតំបន់ គឺគ្រាន់តែតំរូវឱ្យផ្តល់សេវាកម្មទៅកុមារពិការដែលត្រូវបានផ្លាស់ពីទីកន្លែងបច្ចុប្បន្នរបស់គេ អស់រយៈពេល **១0ថ្ងៃសិក្សា ឬ តិចជាងនេះ** នៅក្នុងឆ្នាំសិក្សានោះ ប្រសិនបើភ្នាក់ងារអប់រំក្នុងតំបន់នេះ ផ្តល់សេវាកម្មនានាទៅកុមារដែលមិនពិការដែលត្រូវបានធ្វើការផ្លាស់ចេញប្រហាក់ប្រហែលគ្នា។ សិស្សទាំងឡាយអាចនឹងត្រូវប្រឡងសង និង កិច្ចការងារដែលមិនបានធ្វើនៅអំឡុងពេលដែលត្រូវដាក់ពិន័យតាមវិន័យដោយការព្យួរការសិក្សា ហើយអាចត្រូវបានអនុញ្ញាតឱ្យបំពេញការងារដែលគ្រូដាក់ឱ្យទាំងនេះ ដោយមានការណែនាំដែលបង្កើតឡើងដោយភ្នាក់ងារអប់រំក្នុងតំបន់របស់ពួកគេ។

កុមារពិការដែលត្រូវបានគេផ្លាស់ចេញពីទីតាំងបច្ចុប្បន្នរបស់គេ អស់រយៈពេល**លើសពី ១០ថ្ងៃសិក្សាជាប់ៗគ្នា** ត្រូវតែ:

a. បន្តទទួលសេវាកម្មអប់រំនានា ដើម្បីឱ្យកុមារអាចបន្តការចូលរួមក្នុងកម្មវិធីសិក្សាទូទៅ ទោះជានៅក្នុងស្ថានភាពផ្សេងៗក៏ដោយ ហើយអាចបន្តធ្វើឱ្យមានការរីកចំរើនដើម្បីឆ្ពោះទៅកាន់គោលដៅដែលបានរៀបចំឡើងនៅក្នុង IEP របស់កុមារ **និង**

b. ទទួល (តាមការគួរ) ការវាយតំលៃឥរិយាបទបំពេញការងារ និង សេវាកម្មអន្តរាគមន៍ផ្នែកឥរិយាបថ និង ការកែសំរួលដែលរៀបចំឡើងដើម្បីដោះស្រាយអាកប្បកិរិយាបំពាន ដូច្នេះទង្វើនេះនឹងមិនកើតឡើងម្តងទៀត។

បន្ទាប់ពីកុមារពិការម្នាក់ ត្រូវបានគេផ្លាស់ចេញពីកន្លែងបច្ចុប្បន្នរបស់គេ អស់រយៈពេល **១០ថ្ងៃសិក្សា** អំឡុងពេលមួយឆ្នាំសិក្សា ឬក៏ **ប្រសិនបើ**ការផ្លាស់ចេញបច្ចុប្បន្ន គឺសំរាប់រយៈពេល **១០ថ្ងៃសិក្សាជាប់ៗគ្នា** ឬ តិចជាងនេះ **ហើយ**ប្រសិនបើការផ្លាស់ចេញនោះ មិនមែនជាផ្លាស់ប្តូរទីកន្លែង (សូមមើលនិយមន័យខាងក្រោម) **បន្ទាប់មក** បុគ្គលិកសាលា (ដោយពិភាក្សាជាមួយគ្រូរបស់ក្មេងយ៉ាងហោចណាស់ម្នាក់) ដើម្បីកំនត់នូវកំរិតត្រូវការឱ្យមានសេវាកម្មនានា ដើម្បីជួយកុមារឱ្យបន្តចូលរួមក្នុងកម្មវិធីអប់រំទូទៅ ទោះបីបើក្នុងស្ថានភាពមួយទៀត ហើយអាចបន្តរីកចំរើនឈានទៅសំរេចគោលដៅកំនត់ក្នុង IEP របស់កុមារ។

ប្រសិនបើការផ្លាស់ចេញ ជាការផ្លាស់ប្តូរទីកន្លែង (សូមមើលនិយមន័យខាងក្រោម) ក្រុម IEP របស់កុមារ កំនត់យកសេវាកម្មសមស្របនានា ដើម្បីជួយកុមារឱ្យបន្តចូលរួមក្នុងកម្មវិធីអប់រំទូទៅ ទោះក្នុងស្ថានភាពមួយទៀត និងអាចបន្តរីកចំរើនឈានទៅសំរេចគោលដៅដែលកំនត់ក្នុង IEP របស់កុមារ។

## 5. ការកំណត់សញ្ញាណ (Meanifestation determination)

**ក្នុងរយៈពេល** ១០ថ្ងៃសិក្សា **នៃការសំរេចចិត្តណាមួយក្នុងផ្លាស់ប្តូរទីកន្លែងរបស់កុមារពិការ ដោយសារការបំពានក្រមសីលធម៌ជាសិស្ស (លើកលែងចំពោះ ការផ្លាស់ចេញណាមួយដែលមិនរួមមានការផ្លាស់ប្តូរទីកន្លែងអប់រំ ជាឧទាហរណ៍ គឺសំរាប់រយៈពេល** ១០ថ្ងៃសិក្សាជាប់ៗគ្នា **ឬក៏ តិចជាងនេះ ហើយមិនមែនជាការផ្លាស់ប្តូរទីកន្លែង) ភ្នាក់ងារអប់រំក្នុងតំបន់ ឪពុកម្តាយ និងសមាជិកពាក់ព័ន្ធ នៃក្រុម IEP (ដូចដែលបានកំនត់ដោយ ឪពុកម្តាយ និង ភ្នាក់ងារអប់រំក្នុងតំបន់) ត្រូវតែពិនិត្យឡើងវិញរាល់ពត៌មានដែលជាប់ទាក់ទងទាំងអស់ នៅក្នុងសំនុំឯកសាររបស់សិស្ស រួមបញ្ចូលទាំង IEP របស់កុមារ ការសង្កេតនានារបស់គ្រូ និងពត៌មានទាក់ទងដទៃទៀត ដែលផ្តល់ដោយឪពុកម្តាយ ដើម្បីកំនត់:**

a. ថាតើការប្រព្រឹត្តដែលចោទសួរនោះ បណ្តាលមកពី ឬ មានទំនាក់ទំនងផ្ទាល់ និង ជាសំខាន់ទៅនឹង ពិការភាពរបស់កុមារ **ឬ**

b. ថាតើការប្រព្រឹត្តដែលចោទសួរនោះ ជាលទ្ធផលផ្ទាល់នៃភាពបរាជ័យរបស់ភ្នាក់ងារអប់រំក្នុងតំបន់ ក្នុងការអនុវត្ត IEP របស់កុមារឬយ៉ាងណា។

ប្រសិនបើភ្នាក់ងារអប់រំក្នុងតំបន់ ឪពុកម្តាយ និង សមាជិកពាក់ព័ន្ធនៃក្រុម IEP របស់កុមារ កំណត់ថាលក្ខខណ្ឌណាមួយខាងលើត្រូវបានរកឃើញការប្រព្រឹត្តនោះ ត្រូវតែកំនត់ថាជាសញ្ញាណរបស់កុមារដែលមានពិការភាពនោះ។

ប្រសិនបើភ្នាក់ងារអប់រំក្នុងតំបន់ ឪពុកម្តាយ និង សមាជិកពាក់ព័ន្ធនៃក្រុម IEP របស់កុមារ កំណត់ថាការប្រព្រឹត្តដែលចោទសួរនោះ គឺជាលទ្ធផលផ្ទាល់នៃភាពបរាជ័យរបស់ភ្នាក់ងារអប់រំក្នុងតំបន់ ក្នុងការអនុវត្ត IEP នោះ ភ្នាក់ងារអប់រំក្នុងតំបន់ត្រូវតែចាត់វិធានការជាបន្ទាន់ដើម្បីដោះស្រាយកង្វះខាតទាំងនោះ។

## 6. ការកំនត់ដែលថាឥរិយាបថនោះគឺជាសញ្ញាណរបស់កុមារដែលមានពិការភាព (Determination that behavior was a manifestation of the child's disability)

ប្រសិនបើភ្នាក់ងារអប់រំក្នុងតំបន់ ឪពុកម្តាយ និង សមាជិកពាក់ព័ន្ធនៃក្រុម IEP កំនត់ថា ការប្រព្រឹត្តនោះជាសញ្ញាណនៃពិការភាពរបស់កុមារ ក្រុមIEP ត្រូវតែ:

a. ធ្វើការវាយតំលៃលើឥរិយាបថបំពេញការងារ លើកលែងតែភ្នាក់ងារអប់រំក្នុងតំបន់ បានធ្វើការវាយតំលៃលើឥរិយាបថបំពេញការងារមុនកើតមានឥរិយាបថនោះ ដែលផ្តល់លទ្ធផលជាការផ្លាស់ប្តូរទីកន្លែងបានកើតឡើង និងការអនុវត្តផែនការអន្តរាគមន៍លើឥរិយាបទ ចំពោះកុមារនេះ **ឬ**

b. ធ្វើការពិនិត្យឡើងវិញចំពោះផែនការអន្តរាគមន៍លើឥរិយាបទ ហើយកែលំអវា តាមភាពចាំបាច់ ដើម្បីដោះស្រាយឥរិយាបទនោះ ប្រសិនបើផែនការអន្តរាគមន៍លើឥរិយាបទ ត្រូវបានបង្កើតរួចហើយ។

លើកលែងតែ (ដូចពិពណ៌នាខាងក្រោម នៅក្រោមអនុចំណងជើង **កាលៈទេសៈពិសេស**) ភ្នាក់ងារអប់រំក្នុងតំបន់ ត្រូវតែនាំកុមារនោះទៅកាន់កន្លែងដែលគេត្រូវបានផ្លាស់ចេញនោះ ប្រសិនបើឪពុកម្តាយ និង អាជ្ញាធរស្រុក មិនព្រមឱ្យមានផ្លាស់ប្តូរទីកន្លែង ជាផ្នែកមួយនៃការកែតម្រូវនៃផែនការអន្តរាគមន៍ឥរិយាបថ។

## 7. កាលៈទេសៈពិសេស (Special circumstances)

មិនថា អាកប្បកិរិយានេះមែន ឬមិនមែនជាសញ្ញាណមួយនៃពិការភាពរបស់កុមារក៏ដោយ បុគ្គលិកសាលាអាចផ្លាស់សិស្សម្នាក់នេះ ទៅកន្លែងអប់រំជាជំរើសបណ្តោះអាសន្នមួយ (ដែលបានកំនត់ដោយក្រុម IEP របស់កុមារនេះ) រហូតទៅដល់រយៈពេល ៤៥ថ្ងៃសិក្សា ប្រសិនបើកុមារនេះ :

a. កាន់អាវុធ (សូមមើល**និយមន័យ**ខាងក្រោម) ទៅសាលា ឬ មានអាវុធនៅសាលា ឬ ក្នុងបរិវេណសាលា ឬ ក្នុងកម្មវិធីរបស់សាលា ដែលស្ថិតនៅក្រោមការកាត់សេចក្តីរបស់ភ្នាក់ងារអប់រំក្នុងតំបន់:

b. ត្រូវបានគេដឹងថាមាន ឬ ប្រើប្រាស់គ្រឿងថ្នាំខុសច្បាស់ (សូមមើល**និយមន័យ**ខាងក្រោម) ឬក៏ បញ្ចុះបញ្ចូលដើម្បីលក់ ឬក៏ លក់ សារធាតុហាមខាត់ (សូមមើល**និយមន័យ**ខាងក្រោម) ខណៈពេលនៅសាលា ក្នុងបរិវេណសាលា ឬក៏ នៅក្នុងកម្មវិធីរបស់សាលា ដែលស្ថិតនៅ ក្រោមការកាត់សេចក្តីរបស់ភ្នាក់ងារអប់រំក្នុងតំបន់ ឬ

c. បានបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរលើរាងកាយ (សូមមើល**និយមន័យ**ខាងក្រោម) ចំពោះអ្នកដទៃ ខណៈពេលនៅឯសាលា ក្នុងបរិវេណសាលា ឬក៏នៅក្នុងកម្មវិធីរបស់សាលា ក្រោមការកាត់សេចក្តីរបស់ភ្នាក់ងារអប់រំរដ្ឋ ឬក៏ ភ្នាក់ងារអប់រំក្នុងតំបន់ណាមួយ។

8. **និយមន័យ (Definitions)**

a. *សារធាតុហាមឃាត់ (Controlled substance)* សំដៅដល់ ថ្នាំ ឬ សារធាតុដទៃទៀត ដែលបញ្ជាក់នៅក្រោមបញ្ជី I, II, III, IV, or V ក្នុងផ្នែក 202 (c) នៃច្បាប់ស្តីអំពីសារធាតុហាមឃាត់ (21 U.S.C. 812(c))។

b. *ថ្នាំខុសច្បាស់ (Illegal drug)* សំដៅដល់ សារធាតុហាមឃាត់ ប៉ុន្តែមិនរួមបញ្ចូលនូវ សារធាតុហាមឃាត់ ដែលមានជាកម្មសិទ្ធិស្របច្បាប់ ឬ ត្រូវបានប្រើប្រាស់ក្រោមការគ្រប់គ្រង របស់អ្នកជំនាញផ្នែកថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ ឬ ដែលមានជាកម្មសិទ្ធិស្របច្បាប់ ឬ ត្រូវបានប្រើប្រាស់ដោយសមត្ថកិច្ចផ្សេងៗ ក្រោមច្បាប់នោះ ឬស្ថិតក្រោម ខ ផ្សេងទៀតដែលមានចែងក្នុងច្បាប់សហព័ន្ធ។

c. ការរងរបួស *ផ្នែករាងកាយធ្ងន់ធ្ងរ (Serious bodily)* មានអត្ថន័យដូចពាក្យ "ការរងរបួសផ្នែករាងកាយធ្ងន់ធ្ងរ" ក្រោមកថាខណ្ឌ (3) នៃអនុផ្នែក (h) នៃផ្នែក 1365 នៃចំណងជើង 18, ក្រមសហរដ្ឋអាមេរិក (United States Code)។

d. *អាវុធ (Weapon)* មានអត្ថន័យដូចពាក្យ "អាវុធមានគ្រោះថ្នាក់" ក្រោមកថាខណ្ឌ (2) នៃអនុផ្នែកទីមួយ (g) នៃផ្នែក 930 នៃចំណងជើង 18 ក្រមសហរដ្ឋអាមេរិក (United States Code)។

9. **ការជូនដំណឹង (Notification)**

នៅកាលបរិច្ឆេទដែលភ្នាក់ងារអប់រំក្នុងតំបន់ ធ្វើការសំរេចចិត្តក្នុងការផ្លាស់ចេញដែលជាការផ្លាស់ប្តូរកន្លែងរបស់កុមារ ដោយសារការបំពានក្រមសីលធម៌សិស្ស ភ្នាក់ងារនេះត្រូវតែជូនដំណឹងដល់ឪពុកម្តាយ ពីសេចក្តីសំរេចនោះ ហើយផ្តល់ដល់ឪពុកម្តាយទាំងនេះនូវ សេចក្តីប្រកាសស្តីពីនីតិវិធីទទួលបានការការពារ។

## B. ការផ្លាស់ប្តូរទីកន្លែងដោយសារការផ្លាស់ចេញតាមវិន័យ (34 CFR §300.536)

ការផ្លាស់កុមារដែលមានពិការភាព ចេញពីកន្លែងអប់រំបច្ចុប្បន្នរបស់គេ គឺជា**ការផ្លាស់ប្តូរទីកន្លែង** ដែលតំរូវឱ្យមាន NOREP/ សេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរជាមុន ប្រសិនបើ:

1. ការផ្លាស់ចេញនេះ គឺសំរាប់រយៈពេលច្រើនជាង ១០ថ្ងៃសិក្សាជាប់ៗគ្នា (10 consecutive school days) **ឬ**
2. ការផ្លាស់ចេញនេះ គឺសំរាប់រយៈពេល ១៥ថ្ងៃសិក្សាបូកបន្តគ្នា (15 cumulative school days) ជាសរុបនៅក្នុងឆ្នាំសិក្សាណាមួយ;
3. កុមារនេះត្រូវប្រឈមនឹងការផ្លាស់ចេញជាច្រើនបន្តបន្ទាប់ ដែលរួមគ្នាជាទំរង់មួយ ដោយសារ:

a. ការផ្លាស់ចេញជាច្រើនបន្តបន្ទាប់នេះ សរុបមានរយៈពេលច្រើនជាង ១០ថ្ងៃសិក្សា ក្នុងមួយឆ្នាំសិក្សា;

b. អាកប្បកិរិយារបស់កុមារមានភាពស្រដៀងគ្នាជាខ្លាំង ទៅនឹង អាកប្បកិរិយារបស់គេ ក្នុងឧប្បត្តិហេតុមុនៗដែលនាំឱ្យមានការផ្លាស់ចេញជាច្រើនបន្តបន្ទាប់នេះ;

c. កត្តាបន្ថែមមួយចំនួនទៀត ដូចជារយៈពេលនៃការផ្លាស់ចេញនីមួយៗ រយៈពេលសរុបដែលកុមារត្រូវបានផ្លាស់ចេញ និងភាពជិតគ្នានៃការផ្លាស់ចេញពីមួយទៅមួយ **និង**

ថាតើទំរង់នៃការផ្លាស់ចេញទាំងនេះ រួមមានទាំងការផ្លាស់ប្តូរទីកន្លែង ត្រូវបានកំនត់ផ្អែកតាមមូលដ្ឋានករណីនីមួយៗ (case-by-case basis) ដោយភ្នាក់ងារអប់រំក្នុងតំបន់ ហើយ (ប្រសិនបើមានការតវ៉ា) គឺជាប្រធានបទដែលត្រូវធ្វើការពិនិត្យឡើងវិញ តាមរយៈនីតិវិធីផ្លូវច្បាប់ និង នីតិវិធីតុលាការ ដែរឬយ៉ាងណា។

## C. ការកំនត់ពីទីកន្លែង (34 CFR §300.531)

IEP ត្រូវតែកំនត់ទីកន្លែងការអប់រំដែលជាជំរើសបណ្តោះអាសន្ន សំរាប់ការផ្លាស់ចេញទាំងឡាយ ដែលជា**ការផ្លាស់ប្តូរទីតាំង** និងការផ្លាស់ចេញ ក្រោយចំណងជើង **សិទ្ធិបន្ថែម** និង **កាលៈទេសៈពិសេស** ខាងលើ។

## D. ឧទ្ធរណ៍ (34 CFR §300.532)

### 1. ជាទូទៅ (General)

ឳពុកម្តាយរបស់កុមារដែលមានពិការភាព អាចនឹងដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ (សូមមើលខាងលើ) ដើម្បីស្នើសុំឱ្យមានសវនាការតាមផ្លូវច្បាប់ ប្រសិនបើគាត់ពុំយល់ស្របជាមួយនឹង :

a. សេចក្តីសំរេចណាមួយទាក់ទងទៅនឹងការផ្លាស់ទីកន្លែង ដែលធ្វើឡើងតាម ខ វិន័យទាំងនេះ **ឬ**

b. ការកំនត់សញ្ញាណ ដែលបានពិពណ៌នាខាងលើ ។

ភ្នាក់ងារអប់រំក្នុងតំបន់ អាចដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ (សូមមើលខាងលើ) ដើម្បីស្នើសុំឱ្យមានសវនាការតាមផ្លូវច្បាប់ ប្រសិនបើភ្នាក់ងារជឿថា ការរក្សាកន្លែងបច្ចុប្បន្នរបស់កុមារ ទំនងណាស់ដែលនាំឱ្យ មានការរងរបួសដល់កុមារ ឬ អ្នកដទៃទៀត ។

### 2. សិទ្ធិរបស់មន្ត្រីសវនាការ (Authority of hearing officer)

មន្ត្រីសវនាការដែលបំពេញនូវលក្ខខណ្ឌ ដូចបានរៀបរាប់ក្នុងអនុចំនងជើង ***មន្ត្រីសវនាការដែលមិនលំអៀង*** ត្រូវរៀបចំសវនាការតាមផ្លូវច្បាប់ និង ធ្វើការសំរេចចិត្ត ។ មន្ត្រីសវនាការ អាចនឹង :

a. បញ្ជូនកុមារពិការទៅកាន់កន្លែងដែលគេត្រូវបានផ្លាស់ចេញនោះវិញ ប្រសិនបើមន្ត្រីសវនាការកំនត់ថា ការផ្លាស់ចេញនេះគឺ ជាការបំពានលើលក្ខខណ្ឌ ដែលបានរៀបរាប់ក្នុងចំណងជើង **សិទ្ធិរបស់បុគ្គលសាលា** ឬក៏ថា ឥរិយាបទរបស់កុមារ គឺជាសញ្ញាណនៃពិការភាពរបស់កុមារ ឬ

b. បញ្ជាឱ្យមានការផ្លាស់ប្តូរទីកន្លែងរបស់កុមារពិការ ទៅកាន់ទីកន្លែងអប់រំដែលជាជំរើសបណ្តោះអាសន្ន ក្នុងរយៈពេលមិនយូរជាង ៤៥ថ្ងៃសិក្សា ប្រសិនបើមន្ត្រីសវនាការកំនត់ថា ការរក្សាទីកន្លែងបច្ចុប្បន្នរបស់កុមារ ទំនងណាស់ជាបង្កឱ្យមានការរងរបួសដល់កុមារ ឬ អ្នកដទៃទៀត ។

នីតិវិធីសវនាការទាំងនេះ អាចនឹងធ្វើឡើងម្តងហើយម្តងទៀត ប្រសិនបើភ្នាក់ងារអប់រំក្នុងតំបន់ ជឿថាការបញ្ជូនកុមារទៅកាន់ទីកន្លែងដើមនោះ អាចបង្កឱ្យ មានការរងរបួសដល់កុមារ ឬ អ្នកដទៃទៀត ។

នៅពេលណាក៏ដោយដែលឳពុកម្តាយ ឬក៏ ភ្នាក់ងារអប់រំក្នុងតំបន់ ដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ដើម្បីស្នើសុំសវនាការមួយបែបនេះ សវនាការមួយត្រូវតែបាន ធ្វើឡើងដោយបំពេញទៅតាមលក្ខខណ្ឌ ដែលបានពិពិណនាក្រោមចំណងជើង នីតិវិធីនៃបណ្តឹងតាមផ្លូវច្បាប់ សវនាការលើពាក្យបណ្តឹងតាមផ្លូវច្បាប់ លើកលែង ដូចខាងក្រោម:

1. SEA ត្រូវតែរៀបចំសំរាប់សវនាការតាមផ្លូវច្បាប់មួយដែលឆាប់រហ័ស ដែលត្រូវតែកើតឡើងក្នុងអំឡុងពេល **២០**ថ្ងៃសិក្សា ចាប់ពីកាលបរិច្ឆេទ ដែលសវនាការត្រូវបានដាក់បណ្តឹងស្នើសុំ និង ត្រូវតែផ្តល់លទ្ធផលជាការកំណត់មួយ ក្នុងរយៈពេល **១០**ថ្ងៃសិក្សា បន្ទាប់ពីសវនាការនោះ ។

2. លុះត្រាតែឳពុកម្តាយ និង LEA យល់ព្រមជាលាយល័ក្ខអក្សរក្នុងការបោះបង់ការប្រជុំ ឬ យល់ព្រមប្រើប្រាស់ការសំរុះសំរួល ឬការប្រជុំរកដំណោះ ស្រាយត្រូវតែធ្វើឡើងក្នុងកំឡុងពេល **៧** ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងពីពាក្យបណ្តឹងតាមផ្លូវច្បាប់នោះ ។ សវនាការអាចបន្តទៅមុខបាន លុះត្រាតែបញ្ហានោះត្រូវបានដោះស្រាយដោយធ្វើឱ្យពេញចិត្តដល់ភាគីទាំងពីរក្នុងរយៈពេល **១៥**ថ្ងៃ ចាប់ពីទទួលបានពាក្យបណ្តឹងតាមផ្លូវច្បាប់នេះ ។

ភាគីម្ខាង អាចប្តឹងឧទ្ធរណ៍ លើសេចក្តីសំរេចក្នុងសវនាការតាមផ្លូវច្បាប់ដែលឆាប់រហ័ស តាមវិធីដូចគ្នាដូចដែលពួកគេអាចនឹងធ្វើ ចំពោះសេចក្តីសំរេចនានា នៅក្នុងសវនាការតាមផ្លូវច្បាប់ដទៃទៀត (សូមមើល ***ឧទ្ធរណ៍*** ខាងលើ) ។

## E. ទីកន្លែងអំឡុងពេលប្តឹងឧទ្ធរណ៍ (34 CFR §300.533)

ដូចបានពិពណ៌នាខាងលើ នៅពេលឳពុកម្តាយ ឬ ភ្នាក់ងារអប់រំក្នុងតំបន់ បានដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ ដែលទាក់ទងទៅនឹងបញ្ហាវិន័យ កុមារត្រូវតែ (លុះត្រាតែឳពុកម្តាយ និង ភ្នាក់ងារអប់រំរដ្ឋ ឬ ភ្នាក់ងារអប់រំក្នុងតំបន់ យល់ព្រម ផ្សេងពីនេះ) ស្ថិតនៅជាបន្តក្នុងកន្លែងអប់រំដែលជាជំរើសបណ្តោះអាសន្ន រង់ចាំការសំរេចចិត្តរបស់មន្ត្រីសវនាការ ឬក៏ រហូតដល់ផុតរយៈពេលត្រូវផ្លាស់ចេញ ដូចបានផ្តល់សំរាប់ និង ពិពណ៌នានៅក្រោមចំណងជើង ***សិទ្ធិរបស់បុគ្គលិកសាលា*** មួយណាកើតមុនក៏ដោយ ។

**<u>វិធានច្បាប់ពិសេសសំរាប់សិស្សមានការវិវឌ្ឍន៍យឺតផ្នែកសតិបញ្ញា</u> (Special Rules for Students with Mental Retardation)**

ការផ្លាស់ចេញតាមវិន័យ ចំពោះកុមារដែលមានការវិវឌ្ឍន៍យឺតផ្នែកសតិបញ្ញា ដែលចូលសិក្សាតាមភ្នាក់ងារអប់រំក្នុងតំបន់ (LEA) ឬក៏ សាលាឈ្នួល (charter school) និង សាលាឈ្នួលសាយប៊ឺ (cyber charter school) សំរាប់រយៈពេលមួយ គឺចាត់ទុកថាជាការផ្លាស់ប្តូរទីកន្លែង នៅក្រោម 22 Pa. Code Sec. 14.143 និងតំរូវឱ្យមានជា NOREP/ សេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរជាមុន (ប្រសិនបើហេតុការណ៍ល្មើសវិន័យនោះ <u>មិនមាន</u> ជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ ថ្នាំ អាវុធ និង/ ឬ របួសផ្នែករាងកាយធ្ងន់ធ្ងរ)។ ការផ្លាស់ចេញពីសាលា ពុំមែនជាការផ្លាស់ប្តូរទីកន្លែង សំរាប់កុមារដែលត្រូវបានបញ្ជាក់ថាមានការវិវឌ្ឍន៍យឺតផ្នែកសតិបញ្ញា នៅពេលដែលហេតុការណ៍ល្មើសវិន័យទាក់ទងនឹងការប្រើប្រាស់ អាវុធ ថ្នាំ និង/ ឬ របួសផ្នែករាងកាយធ្ងន់ធ្ងរ។

យោងទៅតាមការអះអាងមួយចំនួន អង្គការ Commonwelth បានចូលរួមទាក់ទងក្នុង អនុក្រឹតអនុញ្ញាតិ PARC ភ្នាក់ងារអប់រំក្នុងតំបន់ អាចនឹងព្យួរ ផ្អែកលើមូលដ្ឋានកំណត់មួយ ចំពោះកុមារពិការមានការវិវឌ្ឍន៍យឺតផ្នែកសតិបញ្ញា ដែលបង្ហាញសញ្ញាគ្រោះថ្នាក់ចំពោះខ្លួនឯង ឬក៏អ្នកដទៃ នៅពេលការដាក់សំនើរ និង ការអនុម័ត ដោយការិយាល័យនៃការអប់រំពិសេស ហើយស្ថិតក្នុងកំរិតដែលសិស្សពិការដទៃទៀត ក្រៅពីផ្នែកសតិបញ្ញា អាចត្រូវគេព្យួរការសិក្សា។

## F. <u>ការការពារកុមារមិនទាន់ទទួលស្គាល់សំរាប់ ការអប់រំពិសេស និង សេវាកម្មទាក់ទង (34 CFR §300.534)</u>

### 1. ជាទូទៅ

ប្រសិនបើកុមារម្នាក់មិនត្រូវបានកំណត់ថាមានសិទ្ធិទទួលការអប់រំពិសេស និង សេវាកម្មទាក់ទងផ្សេងៗនោះ ហើយបំពានលើក្រមសីលធម៌ជាសិស្ស ប៉ុន្តែ ភ្នាក់ងារអប់រំក្នុងតំបន់បានដឹង (ដូចកំណត់ខាងក្រោម) មុនពេលអាកប្បកិរិយាដែលបណ្តាលឱ្យមានសកម្មភាពល្មើសវិន័យបានកើតឡើង ថាកុមារនោះ ជាកុមារពិការ ដូចនេះ កុមារអាចនឹងបញ្ចូលបន្ថែមការការពារដែលបានពិពណ៌នា ក្នុងសេចក្តីប្រកាសនេះ។

### 2. មូលដ្ឋាននៃចំណេះដឹងសំរាប់បញ្ហាវិន័យ

**<u>ភ្នាក់ងារអប់រំក្នុងតំបន់ត្រូវតែយល់ដឹងថា កុមារគឺជាកុមារពិការ ប្រសិនបើមុនពេលអាកប្បកិរិយាដែលបណ្តាលឱ្យសកម្មភាពល្មើសវិន័យបានកើតឡើង:</u>**

a. ឪពុកម្តាយរបស់កុមារបង្ហាញពីកង្វល់ជាលាយល័ក្ខអក្សរថា កុមារចាំបាច់ត្រូវការការអប់រំពិសេស និងសេវាកម្មទាក់ទងនានា ទៅកាន់ថ្នាក់គ្រប់គ្រង និង បុគ្គលិករដ្ឋបាលនៃភ្នាក់ងារអប់រំសមរម្យណាមួយ ឬក៏ គ្រូរបស់កុមារនោះ;

b. ឪពុកម្តាយ ស្នើសុំការវាយតំលៃ ទាក់ទងនឹងភាពមានសិទ្ធិសំរាប់ការអប់រំពិសេស និង សេវាកម្មទាក់ទង ក្រោមផ្នែក B នៃ IDEA **ឬ**

c. គ្រូរបស់សិស្ស ឬ បុគ្គលិកភ្នាក់ងារអប់រំក្នុងតំបន់ដទៃទៀតបានបង្ហាញ ពីក្តីព្រួយបារម្ភពីទំរង់ នៃអាកប្បកិរិយាដែលបង្ហាញឡើងដោយកុមារផ្ទាល់ ទៅកាន់នាយកនៃភ្នាក់ងារអប់រំក្នុងតំបន់ ផ្នែកការអប់រំពិសេស ឬ ទៅកាន់បុគ្គលិកផ្នែកគ្រប់គ្រងដទៃទៀតរបស់ភ្នាក់ងារអប់រំក្នុងតំបន់។

### 3. ករណីលើកលែង

**<u>ភ្នាក់ងារអប់រំក្នុងតំបន់ និងមិនចាត់ទុកថាមានការយល់ដឹងដូចនេះឡើយ ប្រសិនបើ:</u>**

a. ឪពុកម្តាយសិស្សពុំអនុញ្ញាត ឱ្យវាយតំលៃកុមារ ឬ បដិសេធសេវាកម្មអប់រំពិសេស **ឬ**

b. កុមារត្រូវបានទទួលការវាយតំលៃ និង កំណត់ថា មិនមែនជាកុមារពិការ ក្រោមផ្នែក B នៃ IDEA។

### 4. លក្ខខណ្ឌដែលអនុវត្ត ប្រសិនបើពុំមានមូលដ្ឋាននៃចំនេះដឹង

ប្រសិនបើ មុនពេលចាត់វិធានការវិន័យប្រឆាំងនឹងកុមារ ភ្នាក់ងារអប់រំក្នុងតំបន់ពុំមានចំនេះដឹងដែលថាកុមារគឺជាកុមារពិការ ដូចដែលបានពិពណ៌នាខាងលើ ក្រោមអនុចំណងជើង ***មូលដ្ឋាននៃចំនេះដឹងសំរាប់បញ្ហាវិន័យ*** និង ***ករណីលើកលែង*** នោះ កុមារអាចនឹងត្រូវប្រឈមចំពោះវិធានការវិន័យដែលត្រូវបានអនុវត្ត ចំពោះកុមារនានាដែលមិនមានពិការភាព ដែលពួកគេជាប់ទាក់ទងនឹងអាកប្បកិរិយាស្រដៀងគ្នានេះ។

ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើសំណើមួយត្រូវបានធ្វើឡើងសំរាប់វាយតំលៃចំពោះកុមារក្នុងអំឡុងពេលដែល កុមារប្រឈមនឹងវិធានការវិន័យ ការវាយតំលៃត្រូវតែធ្វើឡើងក្នុងលក្ខណៈរហ័ស។

រហូតដល់ការវាយតំលៃត្រូវបានបញ្ចប់ កុមារនៅតែស្ថិតក្នុងទីកន្លែងអប់រំ ដែលបានកំណត់ដោយអាជ្ញាធរសាលា ដែលអាចរួមមានការព្យួរ ឬ បណ្តេញចេញដោយគ្មានសេវាកម្មអប់រំ ។ ប្រសិនបើកុមារត្រូវកំនត់ថាជាកុមារពិការ សូមពិចារណាលើពត៌មានពីការវាយតំលៃ ដែលធ្វើឡើងដោយភ្នាក់ងារអប់រំក្នុងតំបន់ និង ពត៌មានផ្តល់ឱ្យដោយឪពុកម្តាយ ភ្នាក់ងារអប់រំក្នុងតំបន់ត្រូវតែផ្តល់ការអប់រំពិសេស និង សេវាកម្មពាក់ព័ន្ធ យោងតាមផ្នែក B នៃ IDEA រួមបញ្ចូលទាំងលក្ខខណ្ឌតំរូវផ្នែកវិន័យដែលបានពិពណ៌នាខាងលើ ។

## G. <u>ការសំអាងទៅលើ និង សកម្មភាពដោយការពង្រឹងច្បាប់ និង អំណាចតុលាការ</u> (34 CFR §300.535)

### 1. ច្បាប់បញ្ញត្តិសហព័ន្ធ និង រដ្ឋ មិនបាន:

a. ហាមឃាត់ ភ្នាក់ងារណាមួយពីការរាយការណ៍បទឧក្រិដ្ឋ ដែលបានប្រព្រឹត្តដោយកុមារពិការ ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនោះឡើយ **ឬ**

b. រារាំងការពង្រឹងច្បាប់រដ្ឋ និង អំណាចតុលាការ ពីការអនុវត្តទំនួលខុសត្រូវរបស់ពួកគេ យោងតាមការអនុវត្តនៃច្បាប់សហព័ន្ធ និង រដ្ឋ ចំពោះបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តដោយកុមារពិការ ។

បន្ទាប់ពីការសំអាងលើការពង្រឹងច្បាប់ ការវាយតំលៃឥរិយាបទបំពេញមុខងារដែលត្រូវបានទទួលលើកចុងក្រោយបង្អស់ និងផែនការគាំទ្រឥរិយាបទវិជ្ជមាន គឺតំរូវឱ្យមាន ។

### 2. ការចំលងបញ្ជូននៃឯកសារកំនត់ត្រា

ប្រសិនបើភ្នាក់ងារអប់រំក្នុងតំបន់ រាយការណ៍ពីបទឧក្រិដ្ឋ ប្រព្រឹត្តឡើងដោយកុមារពិការ ភ្នាក់ងារអប់រំក្នុងតំបន់:

a. ត្រូវតែធ្វើឱ្យប្រាកដថា ច្បាប់ចំលងនៃកំនត់ត្រាអំពីការអប់រំពិសេសរបស់កុមារ និង កំនត់ត្រាខាងវិន័យរបស់កុមារ ត្រូវបានបញ្ជូន សំរាប់ការពិចារណាដោយអាជ្ញាធរ ដែលភ្នាក់ងារនេះ រាយការណ៍ពីបទឧក្រិដ្ឋទៅកាន់ **<u>និង</u>**

b. អាចនឹងបញ្ជូនឯកសារចំលងនៃកំនត់ត្រាការអប់រំពិសេស និង កំនត់ត្រាខាងវិន័យរបស់កុមារ ក្នុងកំរិតដែលអនុញ្ញាតដោយ FERPA តែប៉ុណ្ណោះ ។

## IX. តើសេវាកម្មអប់រំពិសេសអ្វីខ្លះដែលមានសំរាប់កូនរបស់ខ្ញុំ ប្រសិនបើឪពុកម្តាយបានឱ្យចូលរៀនក្នុងសាលាឯកជនមួយ ?

**ផ្នែកនេះបង្ហាញពីសេវាកម្មការអប់រំពិសេសដែលមានសំរាប់កុមារដែលត្រូវបានឱ្យចូលរៀនដោយឪពុកម្តាយ ក្នុងសាលាឯកជន។**

### A. <u>វិធានច្បាប់ទូទៅ (34 CFR §300.148)</u>

ផ្នែក B នៃ IDEA មិនតម្រូវឱ្យភ្នាក់ងារអប់រំក្នុងតំបន់ (LEA) បង់ថ្លៃការសិក្សា រួមទាំងការអប់រំពិសេស និង សេវាកម្មទាក់ទងរបស់កុមារដែលមានពិការភាពនៅសាលាឯកជន ឬ កន្លែងផ្សេងទៀត ប្រសិនបើ LEA បានផ្តល់ឱ្យ FAPE មានសំរាប់កូនអ្នក ហើយអ្នកជ្រើសរើសឱ្យកូនអ្នកចូលរៀនសាលា ឬ កន្លែងឯកជន។ ម៉្យាងវិញទៀត IU ដែលជាកន្លែងសាលាឯកជននោះស្ថិតនៅ ត្រូវតែរួមបញ្ចូលកូនរបស់អ្នកជាប្រជាជនដែលតម្រូវការរបស់ពួកគេត្រូវបានបង្ហាញនៅក្រោម ខ នានាដែលមានចែងក្នុងផ្នែក B ដែលទាក់ទងនឹងកុមារដែលត្រូវបានឱ្យចូលរៀនក្នុងសាលាឯកជនមួយ ដោយឪពុកម្តាយរបស់ពួកគេក្រោម 34 CFR §§300.131 ដល់ 300.144.

### B. <u>ការលើកលែង</u>

#### 1. ការទូទាត់ជូនវិញសំរាប់ការចូលរៀននៅសាលាឯកជន

ប្រសិនបើ កូនរបស់អ្នកធ្លាប់ទទួលការអប់រំពិសេស និង សេវាកម្មទាក់ទងពីមុនក្រោមអំណាចរបស់ LEA ហើយអ្នកជ្រើសរើសឱ្យកូនរបស់អ្នកចូលរៀនក្នុងសាលាមត្តេយ្យឯកជន បឋមសិក្សាឯកជន ឬ មធ្យមសិក្សាឯកជន ដោយគ្មានការយល់ព្រមពី ឬ ការអះអាងពី LEA នោះ តុលាការ ឬ មន្ត្រីសវនាការប្រហែលនឹងតម្រូវឱ្យភ្នាក់ងារនោះ ទូទាត់សងអ្នកវិញនូវតំលៃនៃការចុះឈ្មោះនោះ ប្រសិនបើតុលាការ ឬ មន្ត្រីសវនាការកឃើញថាភ្នាក់ងារនោះ មិនបានធ្វើឱ្យ FAPE មានសំរាប់កូនអ្នកក្នុងរបៀបទាន់ពេលវេលាមួយ មុនពេលការចុះឈ្មោះ និង រកឃើញថាការចូលរៀនក្នុងសាលាឯកជននោះគឺសមស្រប។ តុលាការ ឬ មន្ត្រីសវនាកា អាចនឹងរកឃើញថាការឱ្យចូលរៀននោះសមរម្យ ទោះជាការចូលរៀននោះមិនបំពេញតាមស្តង់ដាររដ្ឋ ដែលប្រើសំរាប់ការអប់រំ ដែលត្រូវបានផ្តល់ឱ្យដោយភ្នាក់ងារអប់រំរដ្ឋ និង LEAs។

#### 2. ការកំណត់លើការទូទាត់សងវិញ

តំលៃនៃការទូទាត់សងវិញដែលបានពិពណ៌នានៅក្នុងកថាខណ្ឌខាងលើប្រហែលនឹងត្រូវបានកាត់បន្ថយ ឬ បដិសេធ:

a. ប្រសិនបើ: (a) នៅការប្រជុំ IEP ថ្មីបំផុតដែលអ្នកបានចូលរួម មុនពេលការផ្លាស់កូនរបស់អ្នកពីសាលារដ្ឋ អ្នកមិនបានផ្តល់ពតិមានឱ្យក្រុម IEP ថាអ្នកបានកំពុងបដិសេធការដាក់ឱ្យចូលរៀនដែលបានស្នើដោយ LEA ដើម្បីផ្តល់ FAPE ទៅឱ្យកូនរបស់អ្នក រួមមាន ការបង្ហាញពីការយកចិត្តទុកដាក់ និង បំណងរបស់អ្នកដើម្បីចុះឈ្មោះឱ្យកូនអ្នកចូលរៀនក្នុងសាលាឯកជនដោយការចំណាយជាររបស់រដ្ឋ។ ឬ(b) យ៉ាងតិចណាស់ ១០ថ្ងៃ (រួមទាំង ថ្ងៃឈប់សំរាកដែលកើតមាននៅថ្ងៃធ្វើការ) មុនពេលការផ្លាស់កូនរបស់អ្នកពីសាលារដ្ឋ អ្នកមិនបានជូនដំណឹងជាលាយលក្សណ៍អក្សរពីពតិមាននោះទៅកាន់ LEA។

b. ប្រសិនបើ មុនពេលការផ្លាស់កូនរបស់អ្នកពីសាលារដ្ឋ LEA បានផ្តល់ការជូនដំណឹងជាលាយលក្សណ៍អក្សរជាមុន អំពីគោលបំណងរបស់ខ្លួនក្នុងការវាយតំលៃកូនរបស់អ្នកទៅអ្នកជាមុន (រួមទាំង សេចក្តីថ្លែងដែលបញ្ជាក់ពីគោលបំណងក្នុងការវាយតំលៃដែលសមរម្យ និង សមហេតុផល) ប៉ុន្តែអ្នកមិនបានធ្វើឱ្យកូនរបស់អ្នកទទួលការវាយតំលៃបាន។ **ឬ**

c. យោងតាមការរកឃើញរបស់តុលាការដែលថាសកម្មភាពរបស់មិនសមហេតុផល។

#### 3. ការលើកលែងចំពោះការកំណត់លើការទូទាត់សងវិញ

តំលៃនៃការទូទាត់សងវិញ:

a. មិនត្រូវបន្ថយ ឬ បដិសេធសំរាប់ការដែលមិនបានផ្តល់ការជូនដំណឹង ប្រសិនបើ: (a) សាលាហាមឃាត់អ្នកមិនឱ្យផ្តល់ការជូនដំណឹង (b) អ្នកមិនបានទទួលការជូនដំណឹងពីការទទួលខុសត្រូវរបស់អ្នកក្នុងការផ្តល់ការជូនដំណឹងដែលពិពណ៌នាខាងលើ ឬ (c) ការគោរពតាមលក្ខខណ្ឌតម្រូវការខាងលើអាចនឹងមានលទ្ធផលអាក្រក់លើរាងកាយរបស់កូនអ្នក <u>**និង**</u>

b. ប្រហែលនឹង (យោងតាមការសំរេចចិត្តរបស់តុលាការ ឬ មន្ត្រីសវនាកា) មិនត្រូវបានកាត់បន្ថយ ឬ បដិសេធ សំរាប់ការដែលឪពុកម្តាយមិនបានផ្តល់ការជូនដំណឹងដែលតម្រូវ ប្រសិនបើ: (a) ឪពុកម្តាយមិនមានចំណេះដឹង ឬ មិនអាចសរសេរជាភាសាអង់គ្លេសបាន ឬ (b) ការគោរពតាមលក្ខខណ្ឌតម្រូវការខាងលើអាចនឹងមានលទ្ធផលអាក្រក់ខ្លាំងលើសតិអារម្មណ៍របស់កុមារ។

## C. ការចូលរួមដោយស្មើភាព (34 CFR §300.138)

វាគឺជាគោលនយោបាយរបស់ក្រសួងអប់រំនៃរដ្ឋ Pennsylvania ដែលអង្គភាពអន្តរការី (Intermediate Unit (IU)) ត្រូវតែរកទីកន្លែង បញ្ជាក់អត្តសញ្ញាណ និង វាយតំលៃគ្រប់កុមារទាំងអស់ដែលមានពិការភាពដែលឪពុកម្ដាយរបស់ពួកគេបានចុះឈ្មោះឱ្យចូលរៀននៅសាលាឯកជន រួមទាំង សាលាបឋមសិក្សា និង មធ្យមសិក្សាខាងសាសនាដែលស្ថិតនៅក្នុងតំបន់សេវាកម្មរបស់ IU ។

ក្នុងកាលៈទេសៈ ពេលដែលឪពុកម្ដាយឱ្យកូនរបស់គាត់ចូលរៀនក្នុងសាលាឯកជន (នៅពេល FAPE មិនមែនជាបញ្ហា) IUs ត្រូវតែបង្កើតជាបទបញ្ញត្តិដែលស្ថិតក្នុង ក៏រិតដែលសមស្របនឹងចំនួន និង ទីកន្លែងរបស់សិស្សមានពិការភាព ដែលត្រូវបានចុះឈ្មោះដោយឪពុកម្ដាយរបស់គេក្នុងសាលាឯកជនក្នុងតំបន់សេវាកម្មរបស់ IU សំរាប់ការចូលរួមរបស់កុមារទាំងអស់នោះក្នុងកម្មវិធីដែលជួយ ឬ ដំណើរការក្រោមគំរោងរបស់ IU ដោយផ្ដល់ឱ្យពួកគេនូវការអប់រំពិសេស និង សេវាកម្មទាក់ទង រួមមាន សេវាកម្មផ្ទាល់ដែលបានកំណត់ដោយយោងទៅតាមកិច្ចព្រមព្រៀងការចូលរួមដោយស្មើភាព (EP) រវាង សាលាឯកជន និង IUs ។ គំរោងសេវាកម្មត្រូវតែ បង្កើត និង ដំណើរការ សំរាប់កុមារមានពិការភាពនៅសាលាឯកជននិមួយៗដែលបានកំណត់ដោយ IU ដែលសាលាឯកជននោះស្ថិតនៅ ដើម្បីទទួលការអប់រំពិសេស និង សេវាកម្មទាក់ទងដូចបានកំណត់ដោយ កិច្ចព្រមព្រៀង EP ។

មិនមានកុមារមានពិការភាពដែលបានដាក់ឱ្យចូលរៀនក្នុងសាលាឯកជនដោយឪពុកម្ដាយ មានសិទ្ធិបុគ្គលដើម្បីទទួលផ្នែកខ្លះ ឬផ្នែកទាំងអស់នៃ ការអប់រំពិសេស និង សេវាកម្មទាក់ទង ដែលកុមារនោះនឹងទទួលប្រសិនបើ បានចុះឈ្មោះក្នុងសាលារដ្ឋ។ ដំណើរការប្ដឹងតវ៉ាដែលសមរម្យតាម ផ្លូវច្បាប់ និង ពាក្យបណ្ដឹងតវ៉ាទៅរដ្ឋ មិនមានធ្វើទៅបានឡើយ លើកលែងតែកំហុសដែលសង្ស័យដោយ IU ដើម្បីបំពេញនូវតម្រូវការរបស់កុមារ ។

## <u>ធនធាន</u>

**THE ARC នៃរដ្ឋ PENNSYLVANIA**
301 Chestnut Street, Suite 403
Harrisburg, PA 17101
800-692-7258
គេហទំព័រ www.thearcpa.org

**ការិយាល័យបណ្តាញប្រឹក្សាអប់រំពិសេស, លេខទូរស័ព្ទសុំជំនួយសម្រាប់អាណាព្យាបាល**
800-879-2301
បណ្តាញប្រឹក្សាបុគ្គលអាចមានសម្រាប់អាណាព្យាបាល និងអ្នកតស៊ូមតិសម្រាប់ក្មេងពិការ ឬក្មេងត្រូវបានចាត់ទុកថាពិការដើម្បីពន្យល់អំពីច្បាប់រដ្ឋ និងរដ្ឋសហព័ន្ធទាក់ទងទៅនឹងការអប់រំពិសេស ដែលពិពណ៌នាអំពីជម្រើសដែលមានចំពោះអាណាព្យាបាលដោយការជូនដំណឹងអាណាព្យាបាលអំពីនីតិវិធីសុវត្ថិភាព កំណត់អំពីអត្តសញ្ញាណភ្នាក់ងារ និងការគាំទ្រសេវាកម្មផ្សេងទៀត និងរៀបរាប់អំពីការដោះស្រាយដែលមាន និងរបៀបដែលអាណាព្យាបាលអាចដំណើរការបាន។

**បណ្តាញសិទ្ធិរបស់ជនពិការ**
1414 North Cameron Street
Suite C
Harrisburg, PA 17103
800-692-7443 (សំឡេងមិនគិតថ្លៃ)
877-375-7139 (TDD)
717-236-8110 (សំឡេង)
717-346-0293 (TDD)
717-236-0192 (ទូរសារ)
គេហទំព័រ www.drnpa.org

**HISPANOS UNIDOS PARA NIÑOS EXCEPCIONALES (ក្រុមហ៊ុន PHILADELPHIA HUNE)**
2215 North American Street
Philadelphia, PA 19133
215-425-6203
215-425-6204 (ទូរសារ)
អាស័យដ្ឋានអេឡិចត្រូនិក huneinc@aol.com
គេហទំព័រ www.huneinc.org

**ការផ្តល់អំណាចបេសកកម្ម**
1611 Peach Street, Suite 120
Erie, PA 16501
814-825-0788
អាស័យដ្ឋានអេឡិចត្រូនិកadvocate@missionempower.org
គេហទំព័រ www.missionempower.org

**ការិយាល័យដោះស្រាយវិវាទ**
6340 Flank Drive
Harrisburg, PA 17112-2764
717-901-2145 (ទូរស័ព្ទ)
800-222-3353 (មិនគិតថ្លៃតែនៅ PA ប៉ុណ្ណោះ
**អ្នកប្រើប្រាស់** TTY: PA Relay 711
717-657-5983 (ទូរសារ)
គេហទំព័រ www.odr-pa.org
ការិយាល័យដោះស្រាយវិវាទគ្រប់គ្រងប្រព័ន្ធការផ្សះផ្សា និងនីតិវិធីនៅទូទាំងរដ្ឋទាំងមូល និងផ្តល់ការបណ្តុះបណ្តាល និងសេវាកម្មទាក់ទងវិធីសាស្រ្តដោះស្រាយវិវាទផ្សេងៗ។

**មជ្ឈមណ្ឌលសម្រាប់ការដឹកនាំការតស៊ូមតិ និងអប់រំអាណាព្យាបាល (PEAL)**

1119 Penn Avenue, Suite 400

Pittsburgh, PA 15222

412-281-4404

866-950-1040 (មិនគិតថ្លៃ)

412-281-4409 (TTY)

412-281-4408 (ទូរសារ)

គេហទំព័រ www.pealcenter.org

**មជ្ឈមណ្ឌលច្បាប់សម្រាប់ប្រយោជន៍សាធារណៈនៃរដ្ឋ PHILADELPHIA**

អាគារ United Way

វិថី 1709 Benjamin Franklin ជាន់ទី ២

Philadelphia, PA  19103

215-627-7100

215-627-3183 (ទូរសារ)

គេហទំព័រ www.pilcop.org

**គណៈមេធាវីនៃរដ្ឋ PENNSYLVANIA**

100 South Street

Harrisburg, PA 17101

800-932-0311

គេហទំព័រ www.pabar.org

**បណ្តាញផ្តល់ជំនួយបច្ចេកទេស និងបណ្តុះបណ្តាលនៃរដ្ឋ PENNSYLVANIA (PaTTAN)**

Harrisburg 800-360-7282

King of Prussia 800-441-3215

Pittsburgh 800-446-5607

គេហទំព័រ www.pattan.net

**ក្រុមការងាររដ្ឋសម្រាប់សិទ្ធិទទួលបានការអប់រំ**

3190 William Pitt Way

Pittsburgh, PA 15238

1-800-446-5607 ext. 6828

OFFICE FOR DISPUTE
RESOLUTION

## ទម្រង់ពាក្យស្នើសុំសម្រាប់
## ការសម្របសម្រួលផ្សះផ្សា
## IEP/IFSP
## ការប្រជុំសម្របសម្រួលវាយតម្លៃ

.

| | | |
|---|---|---|
| កាលបរិច្ឆេទថ្ងៃនេះ: | ស្នើសុំដោយ: ☐ ឪពុកម្ដាយ/អាណាព្យាបាល ☐ LEA (សាលាស្រុក, ធម្មនុញ្ញ ឬ IU) | |
| ឈ្មោះរបស់អ្នកបំពេញទម្រង់បែបបទនេះ : | ទំនាក់ទំនងជាមួយសិស្ស: | លេខទូរស័ព្ទ: |

ចូរគូសប្រភេទសេវាកម្មដែលបានស្នើសុំ:
☐ ការសម្របសម្រួល IEP
☐ ការផ្សះផ្សា
☐ ការប្រជុំសម្របសម្រួលវាយតម្លៃ ECC

☐ សម្រាប់អាណាព្យាបាល ចូរគូសនៅទីនេះ ប្រសិនអ្នកចង់ពិភាក្សាជាមួយអ្នកជំនាញបណ្ដាញប្រឹក្សាអំពីការបារម្ភ ឬសំណួរនៃសេវាកម្មទាំងនេះ។

| ព័ត៌មានអំពីសិស្ស | |
|---|---|
| នាមត្រកូល: | នាមខ្លួន: |
| ថ្ងៃខែឆ្នាំកំនើត: | ករណីលើកលែង: |

| ព័ត៌អំពីអាណាព្យាបាល/អ្នកថែរក្សា | |
|---|---|
| ឈ្មោះរបស់អាណាព្យាបាល/អ្នកថែរក្សា:<br>នាមត្រកូល:<br>នាមខ្លួន : | អាណាព្យាបាលទីពីរ ឬអាណាព្យាបាលដែលមិនបានរស់នៅជាមួយសិស្ស:<br>នាមត្រកូល:<br>នាមខ្លួន : |
| អាស័យដ្ឋាន: | អាស័យដ្ឋាន: |
| ទូរស័ព្ទនៅផ្ទះ: | ទូរស័ព្ទនៅផ្ទះ: |
| ទូរស័ព្ទនៅកន្លែងធ្វើការ: | ទូរស័ព្ទនៅកន្លែងធ្វើការ: |

| ទូរស័ព្ទចល័ត: | ទូរស័ព្ទចល័ត: |
|---|---|

| ព័តមានអំពី LEA | |
|---|---|
| ឈ្មោះ LEA : | |
| អាស័យដ្ឋាន: | |
| ឈ្មោះសម្រាប់ទំនាក់ទំនង: | មុខតំណែង: |
| ទូរស័ព្ទ: | |
| ទូរសារ: | |
| អ៊ីមែល: | |
| អ៊ីមែល: | អ៊ីមែល: |

សូមរៀបរាប់ដោយសង្ខេបនៃបញ្ហាជម្លោះ និងសំណើរដំណោះស្រាយចំពោះបញ្ហានេះ។

| |
|---|
| |

**សូមបំពេញផ្នែកនេះ ប្រសិនបើអ្នកស្នើសុំការសម្របសម្រួល IEP**

| |
|---|
| នៅពេលនេះ ការប្រជុំ IEP ត្រូវបានកំណត់រៀបចំឡើងសម្រាប់ _____(កាលបរិច្ឆេទ និងពេលវាលា)។ |

**សូមបំពេញផ្នែកនេះ ប្រសិនបើអ្នកស្នើសុំសន្និសីទការសម្របសម្រួលវាយតម្លៃ ECC**

| | |
|---|---|
| តើអ្នកត្រូវបានតំណាងដោយមេធាវី នៅពេលនេះឬទេ? ☐ បាទ/ចាស ☐ ទេ | |
| ប្រសិនអ្នកមិនត្រូវបានតំណាងដោយមេធាវីទេ តើអ្នកចង់ឲ្យ ODR ទាក់ទងភាគីផ្សេងដើម្បីស្នើការចូលរួមរបស់ពួកគេក្នុងសន្និសីទសម្របសម្រួលវាយតម្លៃ ECC ឬទេ? ☐ បាទ/ចាស ☐ ទេ | |
| សូមកំណត់បុគ្គលដែលត្រូវទាក់ទងសម្រាប់ការទំនាក់ទំនង ECC ទាំងអស់: | |
| ព័ត៌មានអំពីមេធាវីរបស់អាណាព្យាបាល: | ព័ត៌មានអំពីមេធាវីរបស់ LEA: |
| ឈ្មោះ: | ឈ្មោះ: |
| អ៊ីមែល: | អ៊ីមែល: |
| ទូរស័ព្ទ: | ទូរស័ព្ទ: |
| តើសវនាការប្រកបដោយនីតិវិធីត្រឹមត្រូវ ត្រូវបានស្នើសុំហើយឬនៅ? ☐ រួចហើយ ☐ នៅទេ | |

**សម្រាប់សំណើរទាំងអស់ បើមានការបន្ថែមព័ត៌មាន អ្នកគួរផ្តល់វា ហើយបញ្ចូលវានៅទីនេះ។**

| |
|---|
| |

- អាណាព្យាបាលដែលមានសំណួរអំពីសេវាកម្មទាំងនេះ ឬជម្រើសដំណោះស្រាយវិវាទផ្សេង អាចទាក់ទងមកកាន់បណ្ដាញប្រឹក្សាការអប់រំពិសេស តាមរយៈលេខ 800-879-2301។

- សំណួរទាក់ទងនឹង birth-3 គួរត្រូវបញ្ជូនទៅ OCDEL តាមរយៈលេខ 717-346-9320។
- ម្តងម្កាល បុគ្គលិករបស់ ODR អាចត្រូវបានស្នើឲ្យចូលរួមក្នុងការប្រជុំទាំងនេះក្នុងគោលបំណងធ្វើការវាយតម្លៃសេវាកម្មនេះ។ ភាគីនីមួយៗនឹងត្រូវបានជូនដំណឹងអំពីពេលវេលាជាមុន និងសំណួរដែលនឹងត្រូវដោះស្រាយនៅពេលនោះ។
- សូមរក្សាទុកទម្រង់ថតចម្លងនៃឯកសារនេះ និងត្រូវផ្ញើតាមប្រៃសណីយ៍ ទូរសារ ឬអ៊ីមែលនូវទម្រង់ត្រឹមត្រូវទៅការិយាល័យសម្រាប់ការដោះស្រាយវិវាទ នៅអាស័យដ្ឋាន:

6340 Flank Drive, Harrisburg, PA 17112-2764

717-901-2145• Toll Free 800-222-3353 (PA only)

Fax 717-657-5983 • TTY Users: PA Relay 711

odr@odr-pa.org

OFFICE FOR DISPUTE
RESOLUTION

# ពាក្យបណ្តឹងតាមនីតិវិធីត្រឹមត្រូវ

☐ IDEA ☐ IDEA & ការអប់រំដោយវិភាគ ☐ ការអប់រំដោយវិភាគ ☐ ផ្នែក 504

| | | |
|---|---|---|
| កាលបរិច្ឆេទថ្ងៃនេះ: - - | ស្នើសុំដោយ: ☐ អាណាព្យាបាល ☐ LEA | |
| ឈ្មោះបុគ្គលដែលបំពេញសំណើរនេះ: | ទំនាក់ទំនងជាមួយសិស្ស: | ទូរស័ព្ទ: - - Ext |

**សូមផ្ញើឯកសារថតចម្លងនៃពាក្យបណ្តឹងតាមនីតិវិធីច្បាប់ទៅភាគីវិវាទនៅពេលដំណាលគ្នា ដែលត្រូវបានដាក់ទៅកាន់ការិយាល័យសម្រាប់ដោះស្រាយវិវាទ។**

បើអ្នកចង់បានកន្លែងស្នាក់នៅពិសេសដើម្បីចូលរួមក្នុងសវនាការតាមនីតិវិធី អ្នកត្រូវជូនដំណឹងដល់ LEA។

## ព័ត៌មានអំពីសិស្ស

| | | | |
|---|---|---|---|
| នាមត្រកូល: | នាមខ្លួន: | ថ្ងៃខែឆ្នាំកំណើត: - - | ភេទ: ☐ ប្រុស ☐ ស្រី |

| | |
|---|---|
| ករណីលើកលែង: ចុច និងបន្ទាប់ជ្រើសយកមួយចេញពីបញ្ជី | ករណីលើកលែង: ចុច និងបន្ទាប់ជ្រើសយកមួយចេញពីបញ្ជី |
| LEA (ភ្នាក់ងារអប់រំមូលដ្ឋាន): ឧទាហរណ៍ សាលាស្រុក | អាគារសាលាដែលសិស្សចូល: ឧទាហរណ៍ សាលាបឋមសិក្សា ABC |

## អាណាព្យាបាលរស់នៅជាមួយសិស្ស

| | | | |
|---|---|---|---|
| នាមត្រកូល: នាមត្រកូលរបស់អាណាព្យាបាល | | នាមខ្លួន: នាមខ្លួនរបស់អាណាព្យាបាល | ទំនាក់ទំនង: ☐ ម្តាយ ☐ ឪពុក ☐ អ្នកថែរក្សា |
| ទូរស័ព្ទនៅផ្ទះ: - - | ទូរស័ព្ទចល័ត - - | ទូរស័ព្ទនៅកន្លែងធ្វើការ: - - Ext. | អ៊ីមែល: |

| | | | |
|---|---|---|---|
| | | | |
| វិធីសាស្ត្រដែលពេញចិត្តសម្រាប់ការសរសេរការឆ្លើយតប: ☐ អ៊ីមែល ☐ ប៉ុស្តិ៍ U.S. | | | |
| នាមត្រកូល:<br>អាណាព្យាបាលទី 2 នៅអាស័យដ្ឋានតែមួយ | | នាមខ្លួន: | ទំនាក់ទំនង:<br>☐ ម្តាយ ☐ ឪពុក ☐ អ្នកថែរក្សា |
| ទូរស័ព្ទនៅផ្ទះ:<br>- - | ទូរស័ព្ទចល័ត<br>- - | ទូរស័ព្ទនៅកន្លែងធ្វើការ:<br>- - Ext. | អ៊ីមែល: |
| វិធីសាស្ត្រដែលពេញចិត្តសម្រាប់ការសរសេរការឆ្លើយតប: ☐ អ៊ីមែល ☐ ប៉ុស្តិ៍ U.S. | | | |
| អាស័យដ្ឋានរបស់អាណាព្យាបាល/សិស្ស: ផ្លូវ PO Box, ជាន់ អាគារលេខ ។ល។ ទីក្រុង រដ្ឋ ZIP។ | | | |
| មេធាវីរបស់អាណាព្យាបាល (បើមាន): ឈ្មោះពេញ | | | ទូរស័ព្ទរបស់មេធាវី: - - Ext |
| អាស័យដ្ឋានរបស់មេធាវី: ផ្លូវ PO Box, ជាន់ បន្ទប់លេខ ល | | | អ៊ីមែលរបស់មេធាវី: |
| ទីក្រុង / រដ្ឋ / ZIP | | | |

**អាណាព្យាបាលមិនស្នាក់នៅជាមួយសិស្ស**

| | | | |
|---|---|---|---|
| នាមត្រកូ:<br>ម្តាយ / ឪពុកមិនស្នាក់នៅជាមួយសិស្ស | | នាមខ្លួន: | ទំនាក់ទំនង:<br>☐ ម្តាយ ☐ ឪពុក |
| ទូរស័ព្ទនៅផ្ទះ:<br>- - | ទូរស័ព្ទចល័ត:<br>- - | ទូរស័ព្ទកន្លែងធ្វើការ:<br>- - Ext | អ៊ីមែល: |
| វិធីសាស្ត្រដែលពេញចិត្តសម្រាប់ការសរសេរការឆ្លើយតប: ☐ អ៊ីមែល ☐ ប៉ុស្តិ៍ U.S. | | | |
| អាស័យដ្ឋានរបស់អាណាព្យាបាល: ផ្លូវ PO Box ជាន់ អាគារលេខ និងទីក្រុង/ រដ្ឋ /ZIP | | | |
| មេធាវីរបស់អាណាព្យាបាល (បើមាន): ឈ្មោះពេញ | | | ទូរស័ព្ទរបស់មេធាវី: - - Ext |
| អាស័យដ្ឋានរបស់មេធាវី: ផ្លូវ PO Box, ជាន់ បន្ទប់លេខ ល | | | អ៊ីមែលរបស់មេធាវី: |
| ទីក្រុង/ រដ្ឋ / ZIP | | | |

**ព័ត៌មានអំពីភ្នាក់ងារអប់រំមូលដ្ឋាន (LEA)**

I. ព័ត៌មានបុគ្គលទាក់ទងនឹង LEA

| | | |
|---|---|---|
| នាមត្រកូល: | នាមខ្លួន: | តួនាទី:<br>នាយកសាលា/ស្នងការ |
| ទូរស័ព្ទចល័ត:<br>- - | ទូរស័ព្ទកន្លែងធ្វើការ:<br>- - Ext | អ៊ីមែល: |

| |
|---|
| **អាស័យដ្ឋាន**<br>ផ្លូវ PO Box ជាន់ បន្ទប់ |
| ទីក្រុង / រដ្ឋ / Zip |
| II. **ស្នងការ/នាយកប្រតិបត្តិ:** |

| | | |
|---|---|---|
| នាមត្រកូល: | នាមខ្លួន: | តួនាទី:<br>ស្នងការ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង |

| | |
|---|---|
| **Address:**<br>Street, PO Box, Floor, Room, etc. | **Phone:**<br>- - Ext |
| ទីក្រុង / រដ្ឋ / Zip | |
| III. **មេធាវី LEA: ឈ្មោះពេញរបស់មេធាវី** | **ទូរស័ព្ទរបស់មេធាវី:** - - Ext |
| | **អ៊ីមែលរបស់មេធាវី:** |

| |
|---|
| **អាស័យដ្ឋានរបស់មេធាវី:** |
| ផ្លូវ, PO Box អាគារ បន្ទប់ |
| ទីក្រុង / រដ្ឋ / Zip |
| IV. **សវនាការតាមនីតិវិធីនឹងត្រូវប្រព្រឹត្តទៅនៅអាស័យដ្ឋានដូចខាងក្រោម:**<br>*(ឈ្មោះអាគារ ឈ្មោះ និងលេខអាស័យដ្ឋាននិងបន្ទប់ ត្រូវបំពេញដោយ LEA)*<br>ឈ្មោះអាគារ អាស័យដ្ឋានផ្លូវ បន្ទប់ |
| សម្គាល់: សវនាការនឹងត្រូវប្រព្រឹត្តទៅនៅពេលវាលា និងទីកន្លែងងាយស្រួលសម្រាប់អាណាព្យាបាល និងក្មេងដែលពាក់ព័ន្ធ។ សម្រាប់ករណីសិក្សាវិភាគ សវនាការនឹងត្រូវប្រព្រឹត្តនៅក្នុងសាលាស្រុកនៅទីកន្លែងដែលងាយស្រួលសម្រាប់អាណាព្យាបាល និងដោយសំណើរបស់អាណាព្យាបាល អាចត្រូវធ្វើនៅពេលល្ងាច។ |

| ព័ត៌មានអំពីបណ្តឹងនីតិវិធីត្រឹមត្រូវតាមច្បាប់ (សម្រាប់ករណី IDEA ប៉ុណ្ណោះ) | |
|---|---|
| A. តើបញ្ហារបស់អ្នកមានទាក់ទងនឹងការសម្រេចសេចក្តីរបស់មន្ត្រីសវនាការដែលមិនទាន់ត្រូវបានអនុវត្តឬទេ? | ☐ បាទ/ចាស<br>☐ ទេ |
| *(បើបាទ/ចាស ការិយាល័យអប់រំពិសេសនឹងត្រូវបានជូនដំណឹង និងធ្វើការស៊ើបអង្កេតមើលបញ្ហានេះ។ ដំណើការនីតិវិធីមិនដំណើរការនៅពេលដែលបញ្ហាទាក់ទងទៅការមិនអនុវត្តសេចក្តីសម្រេចនៃសវនាការ។)* | |
| B. **តើនេះជាសំណើរសម្រាប់សវនាការដោយហេតុមិនសុខចិត្តនឹង:**<br>☐ ការដាក់វិន័យ ☐ ESY (ការពន្យាឆ្នាំសិក្សា) | |
| **ចូរគូសនៅទីនេះ បើសិស្សស្ថិតក្នុងក្រុមគោលដៅ ESY។** ☐ | |

**ព័ត៌មានអំពីបណ្ដឹងនីតិវិធីត្រឹមត្រូវ (ករណីទាំងអស់)**
**អ្នកអាចប្រើទម្រង់នេះដើម្បីពន្យល់នូវប្រភេទនៃវិវាទរបស់អ្នក ឬអ្នកអាចភ្ជាប់ក្រដាសមានព័ត៌មានផ្សេងបាន។**

**តើវិវាទអំពីអ្វី? សូមបញ្ចូលរឿងហេតុទៅក្នុងការពណ៌នារបស់អ្នកផង។**

**តើអ្នកចង់ឃើញដំណោះស្រាយនេះយ៉ាងណា? តើអ្នកកំពុងតែស្វែងរកអ្វី?**

បើអ្នកដឹងអំពីជំហររបស់ភាគីម្ខាងទៀតអំពីបញ្ហានេះ សូមរៀបរាប់នៅត្រង់នេះ។

**កិច្ចប្រជុំដំណោះស្រាយ ( ករណី IDEA ប៉ុណ្ណោះ)**

មុនសវនាការនៃដំណើរការល្អត្រូវអនុវត្ត បើអាណាព្យាបាលបានដាក់ពាក្យបណ្ដឹងនៃដំណើរការល្អ នោះច្បាប់តម្រូវឲ្យភាគីទាំងពីរត្រូវចូលរួមក្នុងកិច្ចប្រជុំស្វែងរកដំណោះស្រាយ លើកលែងតែភាគីទាំងពីរយល់ព្រមជាលាយលក្ខណ៍អក្សរបោះបង់ចោលលក្ខខណ្ឌនេះ។ សូមបំពេញព័ត៌មានដូចខាងក្រោម:

1. កិច្ចប្រជុំស្វែងរកដំណោះស្រាយដើម្បីពិភាក្សាបញ្ហាទាំងនេះត្រូវបានកំណត់កាលបរិច្ឆេទនៅ: ខែ-ថថ-ឆ្ន (កាលបរិច្ឆេទ)
2. កិច្ចប្រជុំស្វែងរកដំណោះស្រាយធ្វើឡើងនៅ: ខខ-ថថ-ឆឆឆឆ (កាលបរិច្ឆេទ)
3. ការចូលរួមក្នុងកិច្ចប្រជុំស្វែងរកដំណោះស្រាយត្រូវបានបដិសេធដោយភាគីទាំងពី និង LEA ជាលាយលក្ខណ៍អក្សរនៅ: ខខ-ថថ-ឆឆឆ (កាលបរិច្ឆេទ)
4. ក្នុងកិច្ចប្រជុំស្វែងរកដំណោះស្រាយ ខ្ញុំស្នើសុំការផ្សះផ្សា*។ ☐

* **បើអ្នកគូសលេខ 4 អ្នកគ្រប់គ្រងសំណុំរឿងសម្រាប់ការផ្សះផ្សា ODR នឹងទាក់ទងទៅភាគី។**

សមាជិកបុគ្គលិក ODR នឹងបញ្ជាក់ពីការទទួលពាក្យបណ្ដឹង និងផ្ដល់ពាក្យបណ្ដឹងនេះទៅអ្នកគ្រប់គ្រងសំណុំរឿង និងមន្ត្រីព័ត៌មានសវនាការ។

ព័ត៌មានបន្ថែមអំពីនីតិវិធីត្រឹមត្រូវគឺអាចរកបាននៅលើគេហទំព័រ ODR, www.odr-pa.org ឬ ដោយហៅទូរស័ព្ទទៅកាន់បណ្ដាញប្រឹក្សាអប់រំជាន់ខ្ពស់ 800-879-2301។

6340 Flank Drive, Harrisburg, PA 17112-2764

717-901-2145 • Toll Free 800-222-3353 (PA only) • TTY Users: PA Relay 711

• www.odr-pa.org